# តេមិយជាតក



នេះកាលព្រះតេមិយសម្តែងព្រះធម៌ប្រោសព្រះញាតិវង្ស

ដឹកនាំការរៀបរៀងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ

**ភុល ផេខ**

**ព.ស. ២៥៦៣**

**តេមិយជាតកពិស្ដារ**

**អធិបតីក្នុងការរៀបរៀង**

**បណ្ឌិត គុល ផេង**

*ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*និងជាប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

**អ្នកបកប្រែពីអដ្ឋកថាភាសាបាលី**

*លោក* **គង់ សំអឿន** *និស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

**ក្រុមជំនុំពិនិត្យ**

*បណ្ឌិត* **គុល ផេង** *ប្រធាន*

*ព្រះភិក្ខុ វជិរប្បញ្ញោ* **គូ សុភាព**

*ព្រះភិក្ខុ កិត្តិបាលោ* **ពេញ វិបុល**

*បណ្ឌិត* **ប៉ក់ ថាវិន**

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*

*ព្រឹទ្ធាចារ្យ* **ដាំ គុយ**

*ឧបាសក* **ផូ សុធា**

*លោកគ្រូ* **លឹម លឿម**

*លោកគ្រូ* **ជុង សុភឿន**

*លោកគ្រូ* **និព្វ សៅ**

*លោកគ្រូ* **សំណាង សំណាក់**

*លោកគ្រូ* **ស៊ីន់ គីមឈន់**

*លោក* **ហាន សុខេមនុ** *លេខាធិការ*

## ក្រុមបច្ចេកទេស និងរចនា

*លោក* **អ៊ិន ស៊ីយ៉ុន្ណា** *ប្រធាន*

*លោក* **យុន សុវណ្ណរិទ្ធិ** *វិចិត្រករ សមាជិក*

*លោក* **ផុន សុគង់** *សមាជិក*

*លោក* **មម មានិត** *សមាជិក*

## រចនាសម្ពន្ធពុទ្ធិកបណ្ឌិតសភា
## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា
## ក្រុមប្រឹក្សាភិបាល និងស្ថាបនិក

*បណ្ឌិត* **ភុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **សុន្ទរ៍ សាម៉ឿន** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*បណ្ឌិត* **សំ សុខ** *សមាជិក*

*បណ្ឌិត* **ជា សានចាន់ថន** *សមាជិក*

*បណ្ឌិត* **ប៉ក់ ថាវិន** *សមាជិក*

*សាស្ត្រាចារ្យ* **ម៉ក់ វ៉ាន់** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ហេង គឹមហោ** *សមាជិក*

*សាស្ត្រាចារ្យ* **រស់ សាវេន** *សមាជិក*

*សាស្ត្រាចារ្យ* **ឌិត ជន** *សមាជិក*

*សាស្ត្រាចារ្យ* **ជា គ្រិស្នា** *សមាជិក*

*សាស្ត្រាចារ្យ* **អ៊ុំ សុវណ្ណា** *សមាជិក*

*សាស្ត្រាចារ្យ* **នួច ងឹម** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការ*

## ក្រុមជំនុំប្រតិបត្តិ

*បណ្ឌិត* **កុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះញាណវង្ស* **យឹម សន** *ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការ*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធានគណៈកម្មការត្រួតពិនិត្យ*

*ព្រះមហា* **គូ សុភាព** *ប្រធានគណៈកម្មការបច្ចេកទេស*

*លោកគ្រូ* **ហ៊ាត ណាហំ** *ប្រធានរដ្ឋបាល*

*លោក* **ហាន សុខេមនុ** *សមាជិកគណៈកម្មការបច្ចេកទេស*

## ក្រុមជំនុំអប់រំសីលធម៌ និងស្រាវជ្រាវអក្សរសិល្ប៍

*បណ្ឌិត* **កុល ផេង** *អធិបតីក្រុមជំនុំ*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *សមាជិក*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *សមាជិក*

*លោកគ្រូ* **ហ៊ាត ណាហំ** *សមាជិក*

*លោក* **គង់ សំអឿន** *សមាជិក*

## ក្រុមជំនុំផ្សាយព្រះធម៌ និងភាសាបាលី

*លោកគ្រូ ធម្មានន្ទ* **ទ៉ាន់ ចាន់សារ៉ែន** *ប្រធាន*

*ព្រះមហា សក្យមុនីបុត្តោ* **ជា សុមាលា** *សមាជិក*

*លោកគ្រូ* **ហ៊ាត ណាហំ** *សមាជិក*

*លោកគ្រូ* **ចាន់ ឃួរ** *សមាជិក*

*លោកគ្រូ* **ហួយ ទ៉ាន់ថន** *សមាជិក*

*លោក* **សំ សុផល** *សមាជិក*

## ក្រុមជំនុំពិនិត្យ និងបោះពុម្ពផ្សាយសៀវភៅធម៌

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធាន*

*ព្រះមហា* **គូ សុភាព** *អនុប្រធានទី ១*

*លោក* **គង់ សំអឿន** *អ្នកបកប្រែពីភាសាបាលី អនុប្រធានទី ២*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*លោកគ្រូធម្មានន្ទ* **ទ៉ាន់ ចាន់សារ៉ែន** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ** *សមាជិក*

*ធម្មាចារ្យ* **ហ៊ាត ណាហំ** *សមាជិក*

*លោក* **លឹម លឿម** *សមាជិក*

*លោក* **សំណាង សំណាក់**

*លោក* **ដុង សុភឿន** *សមាជិក*

*លោក* **រស់ សិរីវណ្ណាត** *សមាជិក*

## អារម្ភកថា

រឿងតេមិយនេះ គឺជាជាតកមួយក្នុងមហាទសជាតក៍ ដែលមានប្រភពដើមជាភាសាបាលីនៃគម្ពីរអដ្ឋកថា ។ យើងដឹងហើយថា នៅប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ មានអ្នកចេះភាសាបាលីជាស្ពានសម្រាប់ឆ្លងទៅស្វែងយល់នូវពុទ្ធវាទជាភាសាបាលីនេះមានចំនួនតិចតួច ។ បើទុករឿងក្នុងជាតកទាំងអស់ឲ្យនៅជាភាសាបាលីដូច្នេះ ជាឧបសគ្គដ៏ធំសម្រាប់អ្នកសិក្សាភាគច្រើន រួមទាំងសិស្ស និស្សិត និងបញ្ញវន្តទាំងអស់ដែលមិនបានសិក្សាភាសាបាលី ។ម្យ៉ាងវិញទៀតប្រទេសកម្ពុជាយើង ក៏ធ្លាប់មានសៀវភៅសង្ខេបទសជាតក ដែលប្រែនិងរៀបរៀងដោយលោក **ឈឹម ស៊ុម** កាលពីឆ្នាំ ១៩៥៩ មួយក្បាលគ្រប់ទាំង ១០ រឿងរួចមកហើយ ឃើញថា មានសេចក្ដីសមល្មមគ្រប់គ្រាន់សម្រាប់ពុទ្ធសាសនិកជនសម័យនោះសិក្សារៀនសូត្រ តែមកដល់សម័យបច្ចុប្បន្ននេះ រឿងសង្ខេបទសជាតកនោះ មិនទាន់ធួនល្មមដល់តម្រូវការនៃការស្រាវជ្រាវរបស់សិស្ស និស្សិត បញ្ញវន្ត និងពុទ្ធសាសនិកនៅឡើយ ។

សាកលវិទ្យាល័យបញ្ញាសាស្រ្ដកម្ពុជា មើលឃើញពីតម្រូវការនេះថាជាការចាំបាច់បំផុតក្នុងការចូលរួមចំណែកជួយអប់រំសង្គម ទើបខ្ញុំខ្មែរ ចាត់ចែង រៀបចំបកប្រែនិងរៀបរៀងតេមិយជាតកនេះម្ដងទៀតឲ្យមានសេចក្ដីពិស្ដារ តាមច្បាប់ដើមក្នុងអដ្ឋកថាជាភាសាបាលី

ក្នុងគោលបំណងជួយបំពេញបន្ថែមដល់ការសិក្សាស្រាវជ្រាវរបស់សិក្ខាកាមគ្រប់កម្រិតនិងដល់ពុទ្ធបរិស័ទគ្រប់រូប ។

ការរៀបរៀងសៀវភៅនេះ ដំបូងយើងប្រែពីភាសាបាលីមកជាភាសាខ្មែរ បន្ទាប់មក យើងចាប់ពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ ដោយប្រើសំនួនវោហារតាមវចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ **ជួន-ណាត ជោតញ្ញាណោ** ជាគោល ។ ខ្លឹមសារសេចក្ដី យើងប្រើពាក្យពាយសាមញ្ញ ងាយអាន ងាយស្ដាប់ ងាយយល់ ដល់អ្នកសិក្សាគ្រប់កម្រិត ។ ម្យ៉ាងទៀត ពាក្យពិបាកខ្លះដែលជាប់ដោយភាសាបាលី ដែលខ្មែរយកមកប្រើជារាជសព្ទ និងសង្ឃសព្ទ យើងមិនអាចចៀសវាងបាន ក៏ត្រូវរក្សាទុក ដោយដាក់លេខយោងពន្យល់នៅផ្នែកខាងក្រោមនៃទំព័រ ។

ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លា ល្បះ និងខ្លឹមសារសេចក្ដីក្នុងសៀវភៅនេះ ទោះបីយើងខំប្រឹងប្រែងពិនិត្យកែជាច្រើនលើកច្រើនសា ដោយផ្ចិតផ្ចង់ក៏ដោយ ក៏គង់មានចំណុចខ្វះចន្លោះផ្នែកអក្ខរាវិរុទ្ធ និងសេចក្ដីនៅមានផ្គាំផ្គង់ខ្វះ ៗ មិនខាន ។ សូមអស់លោកអ្នកអានឃើញខុសត្រង់ណា មេត្តាជួយកែតម្រូវក្នុងលក្ខណៈស្ថាបនាឲ្យបានរីកចម្រើន ដើម្បីបានជាក្បួនខ្នាតទុកសម្រាប់កុលបុត្រសិក្សាតទៅអនាគត ។

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សូមចែករំលែកនូវកង់ការមហាកុសលដែលកើតឡើងពីការបកប្រែរៀបរៀងសៀវភៅតេមិយជាតកពិស្ដារនេះ ថ្វាយ ប្រគេន ជូនដល់អស់លោកអ្នកដែលបានកាន់

*សៀវភៅនេះអាន និងដល់បុព្វការីជន ញាតិមិត្រ សាច់សាលោហិត ទាំងអស់ក្នុងសង្សារវដ្ដ សូមឲ្យលោកអ្នកមានគុណទាំងនោះបាន សម្រេចនូវសម្បត្តិ ៣ គឺសម្បត្តិមនុស្ស សម្បត្តិទេព្តា និងសម្បត្តិព្រះ និព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។*

*សូមសត្វលោកទាំងពួង បានប្រកបដោយសេចក្ដីសុខជានិរន្តរ៍តទៅ ។*

*រាជធានីភ្នំពេញ,*

*ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

កុល ផេង

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# មាតិកា

## ជំពូកទី ១

### អំពីកំណើតព្រះតេមិយ


និទានខាងដើម ...............................................................១
ពិធីបួងសួងសុំបុត្រ ............................................................២
កំណើតព្រះបរមពោធិសត្វនិងទេវបុត្រ ៥០០ អង្គ ................៥
មូលហេតុនៃព្រះរាជកុមារមានឈ្មោះថា តេមិយ................១១
ការជ្រើសរើសលក្ខណៈស្ត្រីមេដោះ ......................................៧
ព្រះរាជាកាត់ទោសចោរ ៤ នាក់ ........................................១៣
ទេវតារក្សាព្រះមហាស្វេតច្ឆត្រដាស់តឿនតេមិយកុមារ ......១៥


## ជំពូកទី ២

### អំពីការសាកល្បងព្រះរាជកុមារដោយវិធីផ្សេង ៗ


ពិសោធន៍ដោយបង្អត់ទឹកក្សីរដល់ព្រះកុមារ ......................១៩
ពិសោធន៍ដោយនំនិងបង្អែមក្នុងព្រះជន្ម ១ ឆ្នាំ ..................២០
ពិសោធន៍ដោយផ្លែឈើក្នុងព្រះជន្ម ២ ឆ្នាំ ........................២១
ពិសោធន៍ដោយគ្រឿងលេងក្នុងព្រះជន្ម ៣ ឆ្នាំ ..................២២

ពិសោធន៍ដោយភោជនក្នុងព្រះជន្ម ៤ ឆ្នាំ ……………………..២៣
ពិសោធន៍ដោយភ្លើងក្នុងព្រះជន្ម ៥ ឆ្នាំ ……………………...២៤
ពិសោធន៍ដោយដំរីក្នុងព្រះជន្ម ៦ ឆ្នាំ ………………………...២៥
ពិសោធន៍ដោយពស់ក្នុងព្រះជន្ម ៧ ឆ្នាំ ………………………..២៧
ពិសោធន៍ដោយរបាំមហោស្រពក្នុងព្រះជន្ម ៨ ឆ្នាំ …………..២៩
ពិសោធន៍ដោយមនុស្សគុនក្បាច់ដាវក្នុងព្រះជន្ម ៩ ឆ្នាំ ......៣០
ពិសោធន៍ដោយផ្ទុំស័ង្ខក្នុងព្រះជន្ម ១០ ឆ្នាំ …………………..៣២
ពិសោធន៍ដោយសូរស្គរក្នុងព្រះជន្ម ១១ ឆ្នាំ …………………៣៣
ពិសោធន៍ដោយពន្លឺប្រទីបក្នុងព្រះជន្ម ១២ ឆ្នាំ ……….....៣៣
ពិសោធន៍ដោយទឹកអំពៅក្នុងព្រះជន្ម ១៣ ឆ្នាំ ………………៣៤
ពិសោធន៍ដោយអាចម៍និងទឹកនោមក្នុងព្រះជន្ម ១៤ ឆ្នាំ ….៣៥
ពិសោធន៍ដោយរងើកភ្លើងក្នុងព្រះជន្ម ១៥ ឆ្នាំ ……………..៣៧
ពិសោធន៍ដោយកាមគុណក្នុងព្រះជន្ម ១៦ ឆ្នាំ ……………..៣៩

## ជំពូកទី ៣

### អំពីព្រះនាងចន្ទាទេវីទូលសុំពររាជសម្បត្តិ

បុរោហិតក្រាបទូលព្រះរាជាថាព្រះកុមារជាកាឡកណ្ណី......៤៣

ព្រះរាជាអនុញ្ញាតឲ្យព្រះតេមិយសោយរាជ្យ ៧ ថ្ងៃ ...........៤៥

## ជំពូកទី ៤

### សុនន្ទសារថីនិងព្រះតេមិយ

សុនន្ទសារថីដឹកព្រះតេមិយយកទៅកប់ ..........................៤៩
ព្រះតេមិយឈរត្រៃរថ ................................................៥៣
ព្រះតេមិយទ្រង់គ្រឿងប្រដាប់កាយដូចសក្កទេវរាជ ...........៥៨
នាយសារថីក្រាបទូលដំណឹងបុត្រដល់ព្រះនាងចន្ទាទេវី .....៧៥

## ជំពូកទី៥

### មហាជនសាងផ្នួសតាមព្រះតេមិយ

សក្កទេវរាជថ្វាយអាស្រមដល់ព្រះតេមិយ ..........................៧៩
ជីវិតសាងផ្នួសនៃព្រះតេមិយ..............................................៨១
ព្រះបាទកាសិរាជយាងទៅកាន់អាស្រមរបស់បុត្រ .............៨៣
ព្រះតេមិយសំណេះសំណាលជាមួយនឹងព្រះបិតា .............៨៦
ព្រះនាងចន្ទាទេវីសន្ទប់បាត់ស្មារតី ......................................៩០

ព្រះតេមិយតាបសសម្ដែងធម្មកថាបដិសេធរាជសម្បត្តិ ......៩៣
មហាជនសាងផ្នួស .........................................................១០០
ស្ដេចសាមន្តរាជ ៧ នគរ សាងផ្នួសតាមព្រះតេមិយ .........១០២
ព្រះសាស្ដាប្រជុំជាតក ...................................................១០៥

**គេមិយជាតកពិស្តារ**

**អធិបតីក្នុងការរៀបរៀង**

**បណ្ឌិត កុល ផេង**

*ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*និងជាប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

**អ្នកបកប្រែពីអដ្ឋកថាភាសាបាលី**

*លោក* **គង់ សំអឿន** *និស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

**ក្រុមជំនុំពិនិត្យ**

*បណ្ឌិត* **កុល ផេង** *ប្រធាន*

*ព្រះភិក្ខុ វជិរប្បញ្ញោ* **គូ សុភាព**

*ព្រះភិក្ខុ កិត្តិបាលោ* **ពេញ វិបុល**

*បណ្ឌិត* **ប៉ក់ ថាវិន**

*លោកគ្រូធម្មានន្ទ* **ម៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ**

*ឧបាសក* **ផូ សុធា**

*លោកគ្រូ* **លឹម លឿម**

*លោកគ្រូ* **ដុង សុភឿន**

*លោកគ្រូ* **ទិព្វ សៅ**

*លោកគ្រូ* **សំណាង សំណាក់**

*លោកគ្រូ* **ស៊ន់ គីមឈន់**

*លោក* **ហាន សុខេមនុ** *លេខាធិការ*

## ក្រុមបច្ចេកទេស និងរចនា

*លោក* **អ៊ិន ស៊ីយ៉ុន្ដា** *ប្រធាន*

*លោក* **យុន សុវណ្ណារិទ្ធិ** *វិចិត្រករ សមាជិក*

*លោក* **ផុន សុគង់** *សមាជិក*

*លោក* **មម មានិត** *សមាជិក*

## រចនាសម្ព័ន្ធពុទ្ធិកបណ្ឌិតសភា
## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា
## ក្រុមប្រឹក្សាភិបាល និងស្ថាបនិក

*បណ្ឌិត* **ភុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **សុន្ទរ៍ សារម៉ៀន** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*បណ្ឌិត* **សំ សុខ** *សមាជិក*

*បណ្ឌិត* **ជា សានចាន់ថន** *សមាជិក*

*បណ្ឌិត* **ប៉ក់ ថាវិន** *សមាជិក*

*សាស្ត្រាចារ្យ* **ម៉ក់ វ៉ាន់** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ហេង គឹមហោ** *សមាជិក*

*សាស្ត្រាចារ្យ* **រស់ សារេវ៉េន** *សមាជិក*

*សាស្ត្រាចារ្យ* **ឌិត ឌន** *សមាជិក*

*សាស្ត្រាចារ្យ* **ជា ក្រិស្នា** *សមាជិក*

*សាស្ត្រាចារ្យ* **អ៊ុំ សុវណ្ណ** *សមាជិក*

*សាស្ត្រាចារ្យ* **នួច ខឹម** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការ*

## ក្រុមជំនុំប្រតិបត្តិ

*បណ្ឌិត* **ភុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះញាណវង្ស* **ឃឹម សន** *ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *អគ្គលេខាធិការ*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធានគណៈកម្មការត្រួតពិនិត្យ*

*ព្រះមហា* **គូ សុភាព** *ប្រធានគណៈកម្មការបច្ចេកទេស*

*លោកគ្រូ* **ហ៊ាត ណាហំ** *ប្រធានរដ្ឋបាល*

*លោក* **ហាន សុខេមន្ត** *សមាជិកគណៈកម្មការបច្ចេកទេស*

## ក្រុមជំនុំអប់រំសីលធម៌ និងស្រាវជ្រាវអក្សរសិល្ប៍

*បណ្ឌិត* **ភុល ផេង** *អធិបតីក្រុមជំនុំ*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *សមាជិក*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *សមាជិក*

*លោកគ្រូ* **ហ៊ាត ណាហំ** *សមាជិក*

*លោក* **គង់ សំអឿន** *សមាជិក*

## ក្រុមជំនុំផ្សាយព្រះធម៌ និងភាសាបាលី

*លោកគ្រូ ធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *ប្រធាន*

*ព្រះមហា សក្យមុនីបុត្តោ* **ជា សុមាលា** *សមាជិក*

*លោកគ្រូ* **ហ៊ាត ណាហាំ** *សមាជិក*

*លោកគ្រូ* **ចាន់ ឃួរ** *សមាជិក*

*លោកគ្រូ* **ហួយ វ៉ាន់ថន** *សមាជិក*

*លោក* **សំ សុផល** *សមាជិក*

## ក្រុមជំនុំពិនិត្យ និងបោះពុម្ពផ្សាយសៀវភៅធម៌

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធាន*

*ព្រះមហា* **គូ សុភាព** *អនុប្រធានទី ១*

*លោក* **គង់ សំអឿន** *អ្នកបកប្រែពីភាសាបាលី អនុប្រធានទី ២*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ** *សមាជិក*

*ធម្មាចារ្យ* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **លឹម លឿម** *សមាជិក*

*លោក* **សំណាង សំណាក់**

*លោក* **ដុង សុភឿន** *សមាជិក*

*លោក* **រស់ សិរីវណ្ណាត** *សមាជិក*

## អារម្ភកថា

រឿងតេមិយនេះ គឺជាជាតកមួយក្នុងមហាទសជាតក៍ ដែលមានប្រភពដើមជាភាសាបាលីនៃគម្ពីរអដ្ឋកថា ។ យើងដឹងហើយថា នៅប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ មានអ្នកចេះភាសាបាលីជាស្ពានសម្រាប់ឆ្លងទៅស្វែងយល់នូវពុទ្ធវាទជាភាសាបាលីនេះមានចំនួនតិចតួច ។ បើទុករឿងក្នុងជាតកទាំងអស់ឲ្យនៅជាភាសាបាលីដូច្នេះ ជាឧបសគ្គដ៏ធំសម្រាប់អ្នកសិក្សាភាគច្រើន រួមទាំងសិស្ស និស្សិត និងបញ្ញវន្តទាំងអស់ដែលមិនបានសិក្សាភាសាបាលី ។ ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាយើង ក៏ធ្លាប់មានសៀវភៅសង្ខេបទសជាតក ដែលប្រែនិងរៀបរៀងដោយលោក **ឈឹម ស៊ុម** កាលពីឆ្នាំ ១៩៥៩ មួយក្បាលគ្រប់ទាំង ១០ រឿងរួចមកហើយ ឃើញថា មានសេចក្តីសមល្មមគ្រប់គ្រាន់សម្រាប់ពុទ្ធសាសនិកជនសម័យនោះសិក្សារៀនសូត្រ តែមកដល់សម័យបច្ចុប្បន្ននេះ រឿងសង្ខេបទសជាតកនោះ មិនទាន់ឆ្លួនល្មមដល់តម្រូវការនៃការស្រាវជ្រាវរបស់សិស្ស និស្សិត បញ្ញវន្ត និងពុទ្ធសាសនិកនៅឡើយ ។

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា មើលឃើញពីតម្រូវការនេះថាជាការចាំបាច់បំផុតក្នុងការចូលរួមចំណែកជួយអប់រំសង្គម ទើបខ្ញុំខ្មែង ចាត់ចែង រៀបចំបកប្រែនិងរៀបរៀងតេមិយជាតកនេះម្តងទៀតឲ្យមានសេចក្តីពិស្តារ តាមច្បាប់ដើមក្នុងអដ្ឋកថាជាភាសាបាលី

ក្នុងគោលបំណងជួយបំពេញបន្ថែមដល់ការសិក្សាស្រាវជ្រាវរបស់សិក្ខាកាមគ្រប់កម្រិតនិងដល់ពុទ្ធបរិស័ទគ្រប់រូប ។

ការរៀបរៀងសៀវភៅនេះ ដំបូងយើងប្រែពីភាសាបាលីមកជាភាសាខ្មែរ បន្ទាប់មក យើងចាប់ពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ ដោយប្រើសំនួនវោហារតាមវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ **ជួន-ណាត ជោតញ្ញាណោ** ជាគោល ។ ខ្លឹមសារសេចក្តី យើងប្រើពាក្យពាយសាមញ្ញ ងាយអាន ងាយស្តាប់ ងាយយល់ ដល់អ្នកសិក្សាគ្រប់កម្រិត ។ ម្យ៉ាងទៀត ពាក្យពិបាកខ្លះដែលជាប់ដោយភាសាបាលី ដែលខ្មែរយកមកប្រើជារាជសព្ទ និងសង្ឃសព្ទ យើងមិនអាចចៀសវាងបាន ក៏ត្រូវរក្សាទុក ដោយដាក់លេខយោងពន្យល់នៅផ្នែកខាងក្រោមនៃទំព័រ ។

ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លា ល្បះ និងខ្លឹមសារសេចក្តីក្នុងសៀវភៅនេះ ទោះបីយើងខំប្រឹងប្រែងពិនិត្យកែជាច្រើនលើកច្រើនសា ដោយផ្ចិតផ្ចង់ក៏ដោយ ក៏គង់មានចំណុចខ្វះចន្លោះផ្នែកអក្ខរាវិរុទ្ធ និងសេចក្តីនៅមានផ្គាំផ្គងខ្វះ ៗ មិនខាន ។ សូមអស់លោកអ្នកអានឃើញខុសត្រង់ណា មេត្តាជួយកែតម្រូវក្នុងលក្ខណៈស្ថាបនាឲ្យបានរីកចម្រើន ដើម្បីបានជាក្បួនខ្នាតទុកសម្រាប់កុលបុត្រសិក្សាតទៅអនាគត ។

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សូមចែករំលែកនូវកងការមហាកុសលដែលកើតឡើងពីការបកប្រែរៀបរៀងសៀវភៅតេមិយជាតកពិស្តារនេះ ថ្វាយ ប្រគេន ជូនដល់អស់លោកអ្នកដែលបានកាន់

*សៀវភៅនេះអាន និងដល់បុព្វការីជន ញាតិមិត្រ សាច់សាលោហិត ទាំងអស់ក្នុងសង្សារវដ្ត សូមឲ្យលោកអ្នកមានគុណទាំងនោះបាន សម្រេចនូវសម្បត្តិ ៣ គឺសម្បត្តិមនុស្ស សម្បត្តិទេព្តា និងសម្បត្តិព្រះ និព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។*

*សូមសត្វលោកទាំងពួង បានប្រកបដោយសេចក្តីសុខជានិរន្តរ៍តទៅ ។*

*រាជធានីភ្នំពេញ,*

*ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

កាុល ដេង៍

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# មាតិកា

## ជំពូកទី ១

### អំពីកំណើតព្រះតេមិយ

និទានខាងដើម ............................................................. ...១
ពិធីបួងសួងសុំបុត្រ ........................................................... ...២
កំណើតព្រះបរមពោធិសត្វនិងទេវបុត្រ ៥០០ អង្គ .................៥
មូលហេតុនៃព្រះរាជកុមារមានឈ្មោះថា តេមិយ................១១
ការជ្រើសរើសលក្ខណៈស្ត្រីមេដោះ .....................................៧
ព្រះរាជាកាត់ទោសចោរ ៤ នាក់ .......................................១៣
ទេវតារក្សាព្រះមហាស្វេតច្ឆត្រដាស់តឿនតេមិយកុមារ ......១៥

## ជំពូកទី ២

### អំពីការសាកល្បងព្រះរាជកុមារដោយវិធីផ្សេង ៗ

ពិសោធន៍ដោយបង្អត់ទឹកក្សីរដល់ព្រះកុមារ .....................១៩
ពិសោធន៍ដោយនំនិងបង្អែមក្នុងព្រះជន្ម ១ ឆ្នាំ .................២០
ពិសោធន៍ដោយផ្លែឈើក្នុងព្រះជន្ម ២ ឆ្នាំ .......................២១
ពិសោធន៍ដោយគ្រឿងលេងក្នុងព្រះជន្ម ៣ ឆ្នាំ .................២២

ពិសោធន៍ដោយភោជនក្នុងព្រះជន្ម ៤ ឆ្នាំ ……………………..២៣

ពិសោធន៍ដោយភ្លើងក្នុងព្រះជន្ម ៥ ឆ្នាំ ………………………...២៤

ពិសោធន៍ដោយដំរីក្នុងព្រះជន្ម ៦ ឆ្នាំ …………………………..២៥

ពិសោធន៍ដោយពស់ក្នុងព្រះជន្ម ៧ ឆ្នាំ ………………………...២៧

ពិសោធន៍ដោយរបាំមហោស្រពក្នុងព្រះជន្ម ៨ ឆ្នាំ ………….២៩

ពិសោធន៍ដោយមនុស្សគុនក្បាច់ដាវក្នុងព្រះជន្ម ៩ ឆ្នាំ ......៣០

ពិសោធន៍ដោយផ្ទុំស័ង្ខក្នុងព្រះជន្ម ១០ ឆ្នាំ …………………..៣២

ពិសោធន៍ដោយសូរស្គរក្នុងព្រះជន្ម ១១ ឆ្នាំ …………………៣៣

ពិសោធន៍ដោយពន្លឺប្រទីបក្នុងព្រះជន្ម ១២ ឆ្នាំ ……………....៣៣

ពិសោធន៍ដោយទឹកអំពៅក្នុងព្រះជន្ម ១៣ ឆ្នាំ ………………៣៤

ពិសោធន៍ដោយអាចម៍និងទឹកនោមក្នុងព្រះជន្ម ១៤ ឆ្នាំ ....៣៥

ពិសោធន៍ដោយរងើកភ្លើងក្នុងព្រះជន្ម ១៥ ឆ្នាំ ……………...៣៧

ពិសោធន៍ដោយកាមគុណក្នុងព្រះជន្ម ១៦ ឆ្នាំ ………………៣៩

## ជំពូកទី ៣

**អំពីព្រះនាងចន្ទាទេវីទូលសុំពររាជសម្បត្តិ**

បុរោហិតក្រាបទូលព្រះរាជាថាព្រះកុមារជាកាឡកណ្ណី……៤៣

ព្រះរាជាអនុញ្ញាតឲ្យព្រះតេមិយសោយរាជ្យ ៧ ថ្ងៃ ...........៤៥

## ជំពូកទី ៤

### សុនន្ទសារថីនិងព្រះតេមិយ

សុនន្ទសារថីដឹកព្រះតេមិយយកទៅកប់ ..........................៤៩
ព្រះតេមិយឈរត្រៃរថ ..................................................៥៣
ព្រះតេមិយទ្រង់គ្រឿងប្រដាប់កាយដូចសក្កទេវរាជ ...........៥៨
នាយសារថីក្រាបទូលដំណឹងបុត្រដល់ព្រះនាងចន្ទាទេវី .....៧៥

## ជំពូកទី៥

### មហាជនសាងផ្នួសតាមព្រះតេមិយ

សក្កទេវរាជថ្វាយអាស្រមដល់ព្រះតេមិយ ..........................៧៩
ជីវិតសាងផ្នួសនៃព្រះតេមិយ..............................................៨១
ព្រះបាទកាសិរាជយាងទៅកាន់អាស្រមរបស់បុត្រ .............៨៣
ព្រះតេមិយសំណេះសំណាលជាមួយនឹងព្រះបិតា .............៨៦
ព្រះនាងចន្ទាទេវីសន្ទប់បាត់ស្មារតី .....................................៩០

ព្រះតេមិយតាបសសម្ដែងធម្មកថាបដិសេធរាជសម្បត្តិ ......៩៣
មហាជនសាងផ្នួស ..........................................................១០០
ស្ដេចសាមន្តរាជ ៧ នគរ សាងផ្នួសតាមព្រះតេមិយ .........១០២
ព្រះសាស្ដាប្រជុំជាតក ....................................................១០៥

# ជំពូកទី ១

## អំពីកំណើតព្រះតេមិយ

### និទានខាងដើម

*ធម្មទេសនាដែលមានបទបាលីថា "មា បណ្ឌិច្ចយំ វិភាវយ" ជាដើមនេះ គឺព្រះសម្មាសម្ពុទ្ធ កាលព្រះអង្គគង់នៅក្នុងវត្តជេតពន បានសម្តែងប្រារព្ធអំពីនេក្ខម្មបារមី[១] គឺការសាងផ្នួសក្នុងអតីតកាលរបស់ព្រះអង្គ ។*

*មានសេចក្តីពិស្តារថា ក្នុងថ្ងៃមួយ ភិក្ខុទាំងឡាយកំពុងប្រជុំគ្នាក្នុងធម្មសភា បានពោលសរសើរនូវនេក្ខម្មបារមីរបស់ព្រះពុទ្ធអង្គ ។ ព្រះអង្គទ្រង់ពុទ្ធដំណើរយាងមក ហើយបានត្រាស់សួរភិក្ខុទាំងឡាយនោះថា ៖*

*"ម្នាលភិក្ខុទាំងឡាយ ពួកអ្នកប្រជុំគ្នានិយាយអំពីអ្វី ?"*

*ក្រោយពីព្រះពុទ្ធអង្គទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ភិក្ខុទាំងឡាយក្រាបទូលហើយ ព្រះអង្គទ្រង់ត្រាស់បន្តថា ៖*

---

*[១] នេក្ខម្មបារមីក្នុងរឿងតេមិយនេះ ត្រូវបានគាំទ្រដោយបារមីសំខាន់ៗ ៣ ទៀតគឺ ១- អធិដ្ឋានបារមី ២- វិរិយបារមី ៣- ខន្តិបារមី ។*

"ម្នាលភិក្ខុទាំងឡាយ ក្នុងកំណើតនេះ តថាគតមានបារមីគ្រប់គ្រាន់ មានញាណចាស់ក្លាហើយ លះបង់នូវរាជសម្បត្តិ ចេញសាងផ្នួសក្នុងពេលនេះ មិនមែនជារឿងអស្ចារ្យទេ ។ ក្នុងអតីតជាតិ ដែលតថាគតមានបារមីនៅមិនទាន់គ្រប់គ្រាន់ មានញាណនៅមិនទាន់ចាស់ក្លា តថាគតក៏ធ្លាប់លះបង់រាជសម្បត្តិ ចេញទៅសាងផ្នួស នោះទើបជារឿងអស្ចារ្យ" ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់ត្រឹមតែប៉ុណ្ណោះ ព្រះអង្គក៏គង់នៅស្ងៀម ។ ភិក្ខុទាំងឡាយក្រាបទូលអារាធនានិមន្តព្រះអង្គសម្ដែងរឿងពីអតីតនោះ ។ ព្រះអង្គក៏ទ្រង់លើកយកអតីតនិទានមកសម្ដែងដូចតទៅនេះ ៖

## ពិធីបួងសួងសុំបុត្រ

ក្នុងអតីតកាល មានស្ដេចមួយអង្គព្រះនាមថា កាសិរាជ ទ្រង់បានអភិសេកគ្រងរាជសម្បត្តិក្នុងរាជធានីពារាណសី[២] នៃដែនដីកាសី ។

[២] អានថា ពារាណៈសី (បា.), វារាណសី ឬវរាណសី (សំ.) ន. ឈ្មោះ ក្រុងមួយក្នុងដែនកាសី (ប្រទេសឥណ្ឌា) តាំងនៅនាត្រើយខាងឆ្វេង (ខាងកើត) នៃទន្លេគង្គា ជាយូរអង្វែងណាស់ហើយមិនដែលរុះរើទៅណាឡើយ តែសព្វថ្ងៃនេះក្លាយឈ្មោះជា បេណារ៉េសឬបេណារ៉ែស ក្នុងផែនទីលោកហើយ ។ បានជាក្រុងនេះមានឈ្មោះថា វារាណសី ឬ ពារាណសី ដូច្នេះ ពីព្រោះមានទឹកស្ទឹងឈ្មោះ វរុណា និងស្ទឹងអសិ ហូរ

ស្តេចអង្គនោះមានស្រីស្នំ[៣] ចំនួន ១៦.០០០ នាក់ ។ បណ្តាស្នំទាំងនោះ ពុំមានស្នំណាម្នាក់មានបុត្របុត្រីធីតាទេ ។ អាណាប្រជានុរាស្ត្រទាំងឡាយដឹងថា ស្តេចរបស់ខ្លួនមិនមានបុត្រសូម្បីតែមួយអង្គដើម្បីស្នងរាជ្យ ដូច្នេះទើបប្រជានុរាស្ត្រមកជួបជុំគ្នាក្នុងព្រះលានហ្លួង ទូលអង្វរសូមព្រះរាជាយ៉ាងនេះថា ៖

"បពិត្រព្រះសម្មតិទេព សូមទ្រង់ធ្វើពិធីបួងសួងបន់ស្រន់សុំបុត្រ" ។ ព្រះមហាក្សត្រទ្រង់ព្រះសណ្តាប់នូវសេចក្តីអង្វររបស់ពួកអាណាប្រជានុរាស្ត្រហើយ ទ្រង់មានព្រះរាជឱង្ការបង្គាប់អស់ស្នំទាំង ១៦.០០០ នាក់នោះថា ៖

"ចូរនាងគ្រប់គ្នារៀបចំធ្វើពិធីបន់ស្រន់សុំបុត្រចុះ" ។

---

ចូលមកក្នុងទន្លេគង្គា (Ganga) នាវស្សានរដូវ ទឹកហូរខ្លាំង មកទល់មុខគ្នាត្រង់ចន្លោះប៉ែកខាងត្បូង (ជាព្រះរាជវាំង) និងប៉ែកខាងជើង (ជាទីផ្សារធំទូលាយ) នៃក្រុងនេះ ។ ក្រុងពារាណសីនេះ មានឈ្មោះ ហៅប្លែកទៅទៀតក្នុងជាតកផ្សេង ៗ ដូចក្នុងឧទយជាតក ហៅថា ក្រុងសុរុន្ធនៈ, ក្នុងចូឡសុត្តសោមជាតក ហៅថា ក្រុងសុទស្សនៈ, ក្នុងសោណនន្ទជាតក ហៅថា ក្រុងព្រហ្មវឌ្ឍនៈ, ក្នុងខណ្ឌហាលជាតក ហៅថា ក្រុងបុប្ផវតី, ក្នុងសង្ខព្រាហ្មណជាតក ហៅថា ក្រុងមោឡិនី, ក្នុងយុធញ្ជយជាតក ហៅថា ក្រុងរម្មៈ ។

[៣] ស្រីអ្នកបម្រើក្សត្រិយ៍ទ្រង់រាជ្យ ។

ស្រីស្នំទាំងនោះ នាំគ្នារៀបចំពលិការ សំបូងសង្រួងដល់ទេវតាគ្រប់ទិសទី មានទេវតានៅឋានព្រះចន្ទជាដើម ហើយតាំងសេចក្តីប្រាថ្នាសុំបុត្រ ទោះបីរៀបចំធ្វើយ៉ាងនេះហើយក្តី ក៏ពុំមានស្នំណាម្នាក់មានបុត្រ ឬធីតាឡើយ ។

ចំណែកព្រះអគ្គមហេសីរបស់ព្រះបាទកាសិរាជ ជាបុត្រីនៃស្តេចដែនមទ្ទៈ មានព្រះនាមថា **ចន្ទាទេវី** ព្រះនាងជាអគ្គមហេសីមានសីលបរិសុទ្ធ ។ ព្រះរាជាបានត្រាស់ថា ៖

"មហេសីអូន ចូរម្ចាស់អូនបួងសួងសុំបុត្រនឹងគេដែរចុះ" ។

ព្រះនាងចន្ទាទេវី បានសមាទានឧបោសថសីលក្នុងថ្ងៃពេញបូណ៌មី រួចហើយផ្ទំលើក្រឡាព្រះបន្ទំ សំងំនឹករំពៃដល់សីលរបស់ខ្លួន ធ្វើសត្យាធិដ្ឋាន[៤] ក្នុងហឫទ័យថា ៖

"ប្រសិនបើខ្ញុំមានសីលបរិសុទ្ធ មិនពព្រុះពពាលទេ ដោយសច្ចៈនេះ សូមឲ្យខ្ញុំមានបុត្រដូចក្តីប្រាថ្នា" ។

---

[៤] ការតាំងចិត្តទៀងទាត់, ការតាំងប្រកាសពាក្យសច្ចៈ, ធ្វើសត្យាធិដ្ឋាន ។ ពាក្យនេះមានន័យដូចនឹងពាក្យថា សច្ចាធិដ្ឋាន (សច្ច + អធិដ្ឋាន) ។

**កំណើតព្រះបរមពោធិសត្វនិងទេវបុត្រ ៥០០ អង្គ**

ដោយតេជានុភាពនៃសីលរបស់ព្រះនាងចន្ទាទេវី បណ្ដាលឲ្យឋាន
របស់សក្កទេវរាជមានអាការក្ដៅធួលឡើង ។ ស្ដេចសក្កៈរំពឹងមើលទៅ
បានជ្រាបនូវស្ថានការណ៍នោះថា ៖

"ព្រះនាងចន្ទាទេវីកំពុងប្រាថ្នាសុំបុត្រ, ណ្ហើយចុះ អញនឹងប្រទាន
បុត្រមួយអង្គដល់ព្រះនាង" ។

ដូច្នេះហើយទ្រង់ជ្រើសរើសទេវបុត្រអង្គណាដែលសក្តិសមមកកើតជា
បុត្ររបស់ព្រះនាង ក៏បានឃើញតួអង្គព្រះពោធិសត្វ ។

ក្នុងសម័យកាលមួយនោះ ព្រះពោធិសត្វនៃយើងធ្លាប់ឡើងគ្រង
រាជ្យក្នុងនគរពារាណសីបាន ២០ ឆ្នាំ ក្រោយពេលសោយទិវង្គត ច្យុត
ចាកអត្តភាពនោះ ទ្រង់ក៏បានទៅកើតក្នុងឧស្សទនរក[៥] រងទុក្ខអស់

---

[៥] ជាឈ្មោះនរកតូចៗនៅជុំវិញមហានរកនីមួយៗ ទាំង ៤ ទិស ។ ក្នុងទិសរបស់មហា-
នរកនីមួយៗ មានឧស្សទនរក ៤ ៗ គឺ គូថនរក ១, កុក្កុឡនរក ១, សិម្ពលីនរក ១,
អសិបត្តនរក ឬវេតរណីនរក ១ សរុបក្នុងមហានរក ១ មានឧស្សទនរក ១៦ ដោយជុំ
វិញ ។ ដូច្នេះ មហានរកទាំង ៨ មានឧស្សទនរកសរុបចំនួន ១២៨ ។ មហានរកទាំង ៨
មាន សញ្ជីវនរក ១, កាឡសុត្តនរក ១, សង្ឃាតនរក ១, រូរុវនរក ១, មហារោ-
រុវនរក ១, តាបននរក ១, មហាតាបននរក ១, អវីចិនរក ១ ។ (ស្រង់ចាកដីកាលង្ការ-
ដីកានិងអនុដីកាអភិធម្ម)

៨០.០០០ ឆ្នាំ ទើបរួចពីនរកនោះ ហើយបានទៅកើតជាទេវបុត្រក្នុងភព តាវត្តិង្សដែលគ្រប់គ្រងដោយស្តេចសក្កៈនេះ ។ ព្រះពោធិសត្វបាន អធិដ្ឋានក្នុងព្រះទ័យថា ៖

"អញនឹងនៅក្នុងឋានតាវត្តិង្សនេះដរាបអស់ជន្មាយុ លុះច្យុតចាក អត្តភាពនេះហើយ អញនឹងទៅកាន់ទេវលោកជាន់លើ ៗ ទៀត" ។

គាប់ចួនពេលនោះ ស្តេចសក្កៈយាងទៅកាន់សម្នាក់របស់ព្រះពោធិសត្វ ហើយមានព្រះរាជឱង្ការអញ្ជើញថា ៖

"នែអ្នកនិរទុក្ខ[៦] អើយ ប្រសិនបើលោកចុះទៅកើតក្នុងឋានមនុស្ស វិញ លោកនឹងមានឱកាសដើម្បីបំពេញបារមីបានបរិបូរ រីឯសេចក្តី ចម្រើន ក៏នឹងកើតមានដល់មហាជន ។ នុ៎ះន៏ ព្រះនាងចន្ទាទេវី ជា អគ្គមហេសីរបស់ព្រះបាទកាសិរាជ កំពុងតែប្រាថ្នាសុំបុត្រ សូម លោកអញ្ជើញទៅកើតជាបុត្ររបស់ព្រះនាង" ។

បន្ទាប់ពីអញ្ជើញព្រះពោធិសត្វហើយ ស្តេចសក្កៈបានទៅអញ្ជើញទេវ-បុត្រ ៥០០ អង្គផ្សេង ៗ ទៀត ដែលនឹងត្រូវច្យុតដំណាលគ្នានឹងពោធិសត្វ រួចទ្រង់វិលមកសម្នាក់របស់ព្រះអង្គវិញ ។ ចំណែកព្រះពោធិសត្វ បាន យល់ព្រមតាមការអញ្ជើញរបស់ស្តេចសក្កៈ លោកក៏បានច្យុតចាកទេវ-

[៦] ដែលឥតទុក្ខ ឥតព្រួយ ឬអ្នកដែលមានដំណើរចេញចាកសង្សារទុក្ខ ។

លោកដំណាលគ្នានឹងទេវបុត្រ ៥០០ អង្គនោះ ។ ព្រះពោធិសត្វបានចាប់បដិសន្ធិក្នុងផ្ទៃរបស់ព្រះនាងចន្ទាទេវី, រីឯទេវបុត្រទាំង ៥០០ អង្គចាប់បដិសន្ធិក្នុងផ្ទៃរបស់ភរិយាអាមាត្យទាំង ៥០០ នាក់ ។

## ការជ្រើសរើសលក្ខណៈស្ត្រីមេដោះ

គ្រានោះ ព្រះឧទររបស់ព្រះនាងចន្ទាទេវីហាក់ដូចជាពោរពេញដោយគ្រាប់ពេជ្រ លុះសង្កេតដឹងថាខ្លួនមានគភ៌ ទើបក្រាបទូលចំពោះព្រះស្វាមីឲ្យទ្រង់ជ្រាប ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ដូច្នោះ ព្រះអង្គបានបង្គាប់ព្រះមហេសីឲ្យរក្សាគភ៌យ៉ាងហ្មត់ចត់ ។ ព្រះអគ្គមហេសីទ្រង់ព្រះគភ៌[៧] គ្រប់ ១០ ខែហើយ បានប្រសូតរាជបុត្រមួយអង្គមានលក្ខណៈបរិបូរដោយបុណ្យ ជាហេតុបណ្ដាលឲ្យស្រូវដំណាំក្នុងស្រែចម្ការមានផលផ្កាផ្លែយ៉ាងបរិបូណ៌[៨] ។ ក្នុងថ្ងៃជាមួយគ្នានោះ ភរិយារបស់អាមាត្យចំនួន ៥០០ នាក់ ក៏បានប្រសូតទារក ៥០០ នាក់ដែរ ។ ក្នុងខណៈនោះ ព្រះមហាក្សត្រគង់ប្រថាប់ក្នុងមហាមន្ទីរដោយមានពួក

---

[៧] សត្វកើតក្នុងផ្ទៃ ឧ. ទ្រង់គភ៌, ស្ត្រីមានគភ៌ ពាក្យធម្មតាថា មានផ្ទៃពោះ, មានទម្ងន់ជាដើម ។

[៨] ដូចគ្នានឹង បរិបូរ ដែរ មានន័យថា ដែលគ្រប់គ្រាន់, ដែលពេញគ្រប់គ្រាន់, ពេញលេញ, សម្បូរ, ដែលឆ្អែតហើយ ប្រើជា គុ. ក៏បាន ជា កិ. ក៏បាន ជា កិ.វិ. ក៏បាន ។

អាមាត្យអង្គុយចោមរោមជាបរិវារផង ស្រាប់តែអាមាត្យម្នាក់មកក្រាបទូលព្រះអង្គថា ៖

"បពិត្រព្រះសម្មតិទេព រាជបុត្រព្រះអង្គប្រសូតហើយ ក្រាបទូល" ។

គ្រាន់តែទ្រង់ព្រះសណ្ដាប់នូវពាក្យនោះភ្លាម សេចក្ដីស្នេហាចំពោះបុត្រ បានធ្វើឲ្យសម្បុរស្បែកព្រះមហាក្សត្រ ព្រឺញាក់កន្ទ្រាក់ចាក់ដល់ទៅខួរក្នុងឆ្អឹង, បីតិក៏កើតឡើងដល់ទ្រង់, ព្រះហឫទ័យត្រជាក់ ហើយមានព្រះរាជឱង្ការសួរទៅពួកអាមាត្យថា ៖

"តើអស់លោកសប្បាយឬទេ ពេលឮដំណឹងថា បុត្ររបស់យើងប្រសូត ?"

អាមាត្យទាំងឡាយក្រាបទូលថា ៖

"ព្រះសម្មតិទេព ពួកទូលបង្គំត្រេកអរសប្បាយរីករាយណាស់ ដើមឡើយព្រះអង្គគ្មានរាជបុត្រដើម្បីស្នងរាជត្រកូលទេ តែឥឡូវនេះទ្រង់មានព្រះរាជបុត្រហើយ ព្រះរាជបុត្ររបស់ព្រះអង្គនឹងបានជាម្ចាស់នៃពួកទូលបង្គំយើងខ្ញុំគ្រប់ៗគ្នា" ។

ព្រះរាជាត្រាស់បញ្ជាឲ្យហៅលោកមហាសេនគុត្តចូលគាល់ ហើយត្រាស់បង្គាប់ថា ៖

"យើងត្រូវការបរិវារសម្រាប់បុត្ររបស់យើង លោកចូរទៅសង្កេតមើលថា តើក្នុងថ្ងៃនេះមានទារកប៉ុន្មាននាក់ ដែលកើតនៅឯផ្ទះរបស់ពួកអាមាត្យ" ។

លោកមហាសេនគុត្តទទួលព្រះរាជបញ្ជាហើយ បានទៅសង្កេតមើលគ្រប់ផ្ទះអាមាត្យទាំងអស់ លុះដឹងច្បាស់ថា មានទារក ៥០០ នាក់ ក៏ត្រឡប់មកទូលថ្វាយព្រះមហាក្សត្រឲ្យទ្រង់ជ្រាបវិញ ។

ព្រះរាជាក៏បានប្រទានគ្រឿងប្រដាប់ផ្សេង ៗ សម្រាប់ឧបត្ថម្ភទារកទាំង ៥០០ នាក់ និងទ្រង់ព្រះរាជទានស្ត្រីមេដោះ ៥០០ នាក់បន្ថែមទៀត ។

ចំពោះព្រះមហាសត្តជាបុត្រផ្ទាល់វិញ ទ្រង់ព្រះរាជទាននូវមេដោះ ៦៤ នាក់ ដែលជាស្ត្រីទឹកដោះផ្អែម មិនមែនជាស្ត្រីមានដោះសណ្តាយ និងវៀរបង់ពួកស្ត្រីដែលខ្ពស់ពេកជាដើម ។

ត្រង់នេះ មានសេចក្តីថា កាលទារកអង្គុយបៅដោះលើភ្លៅស្ត្រីខ្ពស់ពេក កទារកនឹងដកវែង ។ កាលទារកអង្គុយបៅដោះលើភ្លៅស្ត្រីទាបពេក ឆ្អឹងកទារកនឹងស្រុញចុះ ។ កាលទារកអង្គុយបៅដោះលើភ្លៅស្ត្រីស្គមពេក ភ្លៅទារកនឹងឈឺចុកចាប់ ។ កាលទារកអង្គុយបៅដោះលើភ្លៅស្ត្រីធាត់ពេក ជើងទារកនឹងកន្ទែក ។ ទឹកដោះនៃស្ត្រីខ្មៅពេក រមែង

ត្រជាក់ពេក ។ ទឹកដោះនៃស្ត្រីសពេក រមែងក្តៅពេក ។ កាលទារកអង្គុយបៅដោះលើភ្លៅស្ត្រីមានដោះសណ្តាយ ច្រមុះទារកនឹងក្រពឹត ។ ទឹកដោះនៃស្ត្រីដែលកើតរោគក្អក រមែងមានរសជាតិជូរពេក ។ ទឹកដោះនៃស្ត្រីដែលកើតរោគហឺត រមែងមានរសជាតិផ្សេង ៗ មានហឹរពេកជាដើម ។

ដូច្នោះហើយ ទើបព្រះរាជាទ្រង់ចៀសវាងគុណវិបត្តិទាំងអស់នោះ មិនឲ្យមានឡើយ ព្រះអង្គទ្រង់ព្រះរាជទានតែមេដោះណាដែលមានទឹកដោះផ្អែម មិនមានដោះយារធ្លាក់ រហូតគ្រប់ចំនួន ៦៤ នាក់ ។ ជាមួយគ្នានេះដែរ ព្រះរាជាបានទ្រង់ប្រទានរង្វាន់ជាច្រើនចំពោះព្រះអគ្គមហេសីចន្ទាទេវី ។ ពេលនោះព្រះអង្គទ្រង់មានព្រះរាជបន្ទូលថា ៖

"យើងមានហឫទ័យរីករាយណាស់ ដែលមហេសីបានបង្កើតបុត្រឲ្យយើងដូចក្តីប្រាថ្នា ថ្ងៃនេះ យើងនឹងប្រោសប្រទានពរពិសេសមួយដល់មហេសី តើមហេសីសម្ងាញ់ ប្រាថ្នាចង់បានអ្វី យើងនឹងប្រទានតាមបំណង" ។

រីឯព្រះនាងចន្ទាទេវី ក្រាបទូលព្រះស្វាមីវិញថា ៖

"បពិត្រព្រះករុណាថ្លៃវិសេស ជាអម្ចាស់ជីវិតតម្កល់លើត្បូង ខ្ញុំម្ចាស់ពុំទាន់ចង់បានពរអ្វីពីព្រះអង្គទេ នៅពេលនេះ សូមព្រះអង្គ

ទ្រង់ព្រះរាជានុញ្ញាតឲ្យខ្ញុំម្ចាស់រក្សាទុកនូវព្រះពរដ៏ប្រសើរនិង
ពិសេសនេះទៅពេលក្រោយចុះ ក្រាបទូល" ។

ព្រះរាជាក៏យល់ព្រមតាមសំណូមពររបស់មហេសីចន្ទាទេវី ។

## មូលហេតុនៃព្រះរាជកុមារមានឈ្មោះថា តេមិយ

លុះដល់ថ្ងៃដាក់ព្រះនាមថ្វាយព្រះរាជកុមារ ព្រះរាជាទ្រង់ចាត់គេឲ្យអញ្ជើញព្រាហ្មណ៍ទាំងឡាយដែលចេះទាយលក្ខណៈមកចូលគាល់ ហើយទ្រង់ធ្វើសក្ការៈ[៩] ដ៏ធំជូនចំពោះពួកព្រាហ្មណ៍ទាំងនោះ រួចសាកសួរអំពីភាពមិនមានអន្តរាយដល់ព្រះរាជកុមារ ។

ព្រាហ្មណ៍ទាំងនោះ មើលឃើញនូវលក្ខណសម្បត្តិរបស់រាជបុត្រ ហើយ ក៏ក្រាបទូលថា ៖

"បពិត្រមហារាជ ព្រះរាជកុមារនេះ បរិបូរដោយលក្ខណសម្បត្តិនៃបុណ្យ ញុំាំងស្រូវស្រែ ដំណាំចម្ការឲ្យមានផលផ្កាផ្លែឥតខ្វះកន្វះអ្វីទេ ចំណែកខាងសមត្ថភាពគ្រងរាជ្យរបស់ព្រះកុមារវិញ

---

[៩] ការធ្វើនូវសេចក្ដីគោរព, ការធ្វើបដិសណ្ឋារៈដោយគោរព, តង្វាយ, ជំនូន, គ្រឿងបូជា ឧ. ធ្វើសក្ការៈ, មានគ្រឿងសក្ការៈ ។

កុំថាឡើយទ្វីបមួយ ទោះបីមហាទ្វីប[១០] ទាំង ៤ រួមទាំងទ្វីបអមជាបរិវារ ២.០០០ ផងនោះ ក៏ព្រះរាជកុមារមានសមត្ថភាពអាចគ្រប់គ្រងបានដែរ ពុំមានអ្នកណាម្នាក់ ឬអ្វីមួយបង្កឲ្យមានអន្តរាយដល់ព្រះរាជកុមារទេ ក្រាបទូល" ។

ព្រះមហាក្សត្រលុះព្រះសណ្ដាប់ដូច្នោះហើយ ទ្រង់មានសេចក្ដីត្រេកអរជាពន់ពេក[១១] រកព្រះនាមដាក់ឲ្យព្រះរាជកុមារដោយអាស្រ័យហេតុ ៣ យ៉ាង ៖

១- ក្នុងថ្ងៃព្រះរាជកុមារប្រសូត មានភ្លៀងបង្អុរស្រោចស្រពទូទៅពេញដែនកាសី ។

២- ហឫទ័យរបស់ព្រះរាជានិងពួកអាមាត្យមានសភាពត្រជាក់

---

[១០] មហាទ្វីប ៤ គឺ៖ ១- បុព្វវិទេហទ្វីប គឺទ្វីបធំស្ថិតនៅទិសខាងកើតភ្នំសិនេរុ ។ ២- ជម្ពូទ្វីប គឺទ្វីបធំស្ថិតនៅទិសខាងត្បូងភ្នំសិនេរុ ។ ៣- អបរគោយានទ្វីប គឺទ្វីបធំស្ថិតនៅទិសខាងលិចភ្នំសិនេរុ ។ ៤- ឧត្តរកុរុទ្វីប គឺទ្វីបធំស្ថិតនៅទិសខាងជើងភ្នំសិនេរុ ។ ទ្វីបដែលយើងនៅសព្វថ្ងៃគឺជម្ពូទ្វីប ដែលមនុស្សមានផ្ទៃពោះចំនួន ៩ ខែ ១០ ថ្ងៃ ទើបសម្រាលបុត្រ ខុសអំពីមហាទ្វីទាំង ៣ ដែលមនុស្សពពោះតែ ៧ ថ្ងៃប៉ុណ្ណោះ ក៏សម្រាលបុត្រ ៧ ថ្ងៃក្រោយមក បុត្រនោះក៏ធំពេញវ័យ ។

[១១] ពន់ពេក នឹងប្រើ ពេកពន់ ក៏បាន មានន័យថា ហួសពេក, ពេកណាស់, លើសលន់ ។

៣-	ដែនដីសើមជោកជាំ

ព្រោះហេតុដូច្នោះ ព្រះរាជាទ្រង់បានសម្រេចព្រះទ័យដាក់ព្រះនាមឲ្យរាជបុត្រថា "**តេមិយ**" ។

ជារៀងរាល់ថ្ងៃ តេមិយកុមារត្រូវបានស្រីស្នំទាំងឡាយ ដូរវេនគ្នាតុបតែងស្អិតស្អាងព្រះកាយថ្វាយ ហើយតែងនាំទៅកាន់សម្នាក់របស់ព្រះរាជបិតាក្នុងមួយខែម្ដង ។ ព្រះរាជាទ្រង់តែងតែទទួលនូវរាជបុត្រសំណព្វព្រះទ័យមកឱបបីថើបត្រង់ព្រះសីសៈ ត្រកងដាក់លើព្រះឧរូ (ភ្លៅ) ហើយទ្រង់ប្រថាប់ប្រលែងលេងជាមួយនឹងព្រះរាជបុត្រ ។

## ព្រះរាជាកាត់ទោសចោរ ៤ នាក់

គាប់ចួនខណៈនោះ រាជបុរសចាប់ចោរបាន ៤ នាក់ នាំមកថ្វាយព្រះរាជាដើម្បីកាត់ទោស ។ បន្ទាប់ពីទតឃើញចោរទាំងនោះហើយ ព្រះមហាក្សត្រទ្រង់ត្រាស់បញ្ជាថា ៖

"ចូរពួកឯងវាយចោរម្នាក់នេះនឹងខ្សែលួសបន្លាមួយពាន់ខ្វាប់, ចោរម្នាក់ទៀត ចូរពួកឯងចងនឹងច្រវាក់ដាក់ពន្ធនាគារ, ចោរម្នាក់ទៀតត្រូវចាក់នឹងលំពែង, ចោរម្នាក់ទៀតត្រូវសូលនឹងដែកស្រួច" ។

ព្រះរាជបុត្រឮព្រះបិតាត្រាស់ដូច្នោះ ក៏កើតភ័យតក់ស្លុត គិតឃើញថា ៖

"ឱះឱ! ព្រះបិតាអញ ហេតុតែខ្លួនជាស្តេច បានសាងបាបកម្មដ៏ធ្ងន់ក្រៃពេកណាស់ បាបកម្មនេះនឹងនាំទៅកាន់នរកទេតើ" ។

លុះដល់ថ្ងៃស្អែកឡើង មាតាបិតាទ្រង់ដាក់ឲ្យតេមិយកុមារផ្ទំនៅលើសិរីសយនា ជាក្រឡាព្រះបន្ទំវិចិត្ររចនាយ៉ាងស្រស់ស្អាតនៅខាងក្រោមស្វេតច្ឆត្រ ។ តេមិយកុមារលង់លក់មួយស្របក់ ក៏ភ្ញាក់បើកព្រះនេត្រឃើញស្វេតច្ឆត្រ ព្រមទាំងសិរីសម្បត្តិនានាជាច្រើនទៀត ។ តេមិយកុមារមានសេចក្តីភ័យតក់ស្លុតរន្ធត់ជាប់មកតាំងពីម្សិលមិញមកស្រាប់ លុះបានឃើញនូវទិដ្ឋភាពដូច្នេះទៀត ក៏រឹងរឹតតែភ័យខ្លាំងឡើង ៗ ព្រះរាជកុមារមានជាតិស្សរញ្ញាណ គឺញាណសម្រាប់រឭកជាតិកំណើតបាន ទើបរំពឹងគិតមើលថា ៖

"ចុះដើមឡើយ អញកើតនៅឯណា បានជាឥឡូវនេះមកកើតក្នុងផ្ទះចោរ[១២] នេះ ។ លុះបានទ្រង់ជ្រាបថា ព្រះអង្គមកអំពីទេវលោក រំពឹងមើលជាតិខាងមុខទេវលោកទៀតឃើញថា ព្រះអង្គធ្លាប់

---

[១២] **ផ្ទះចោរ** ក្នុងន័យប្រៀបធៀបថា កើតក្នុងត្រកូលក្សត្រ សោយរាជ្យជាស្តេច ប្រព្រឹត្តអំពើអាក្រក់ផ្សេងៗ ប្រៀបដូចជាចោរលួចទ្រព្យសម្បត្តិ លួចជាតិកំណើតជាមនុស្ស លួចបុណ្យកុសលគ្រប់យ៉ាង ។

សោយទុក្ខក្នុងឧស្សទនរក រំពឹងមើលទៅខាងមុខទៀតក៏ឃើញថា ព្រះអង្គធ្លាប់សោយរាជ្យជាស្ដេចផែនដីក្នុងនគរពារាណសីជានគរកំណើតបច្ចុប្បន្ននេះ" ។

**ទេវតារក្សាព្រះមហាស្វេតច្ឆត្រជាស់តឿនតេមិយកុមារ**

គ្រានោះ ភ័យធំបានកើតឡើងដល់ព្រះតេមិយ ដែលកំពុងនឹកពិចារណាថា ៖

"ពីអតីតជាតិ អញសោយរាជ្យក្នុងក្រុងពារាណសីនេះតែ ២០ ឆ្នាំសោះ អញបានទៅកើតក្នុងឧស្សទនរក ៨០.០០០ ឆ្នាំ, ឥឡូវមកកើតក្នុងផ្ទះចោរនេះដដែលទៀតហើយអញ ! ចោរ ៤ នាក់ដែលរាជបុរសនាំមកក្នុងថ្ងៃម្សិលមិញ ត្រូវបានព្រះបិតាអញចេញរាជបញ្ជាធ្វើទារុណកម្មដ៏ឃោរឃៅព្រៃផ្សៃពេកណាស់ កម្មនោះជាទោសជាតនាំឲ្យទៅកើតក្នុងនរកទេតើ ! ប្រសិនបើអញសោយរាជ្យ មុខតែអញកើតក្នុងនរកទទួលរងមហាទុក្ខទៀតជាក់ជាពុំខានឡើយ" ។

សរីរៈរបស់ព្រះពោធិសត្វ ដែលធ្លាប់តែមានពណ៌សម្បុរល្អដូចមាស ត្រឡប់ប្រែក្លាយជាស្រពោនស្រពាប់អាប់អស់ពណ៌ធើត ប្រៀបដូចផ្កាបទុមត្រូវគេឈ្វេចឈ្វីដោយដៃ ប្រែក្លាយជាស្មោកពណ៌ដូច្នោះ

ដែរ ។ ពិតមែនតែព្រះតេមិយកុមារកំពុងផ្ទំស្ដូកស្ដឹង ប៉ុន្ដែចិត្ដមិនបាន
ចូលកាន់និទ្រាលង់លក់បន្ដិចសោះ គឺចិត្ដនៅតែគិតគ្នេរថា ៖

"ធ្វើដូចម្ដេចហ្ន៎ អញអាចចេញផុតអំពីផ្ទះចោរនេះបាន ?" ។

គ្រានោះ ទេវតាដែលអាស្រ័យព្រះមហាស្វេតច្ឆត្រនិងធ្លាប់ជា
ម្ដាយរបស់ព្រះកុមារពីអតីតជាតិផងនោះ ចេញមុខមកលួងលោមថា ៖

"ហៃបាតេមិយកុមារ កុំភ័យអីកូន, កុំសោកអីកូន, កុំគិតអីកូន,
ប្រសិនបើកូនពិតជាមានបំណងចេញអំពីទីនេះមែន ចូរកូនធ្វើ
តាមពាក្យម្ដាយ គឺបើទោះបីកូនមិនខ្វិន ក៏ត្រូវធ្វើជាខ្វិន, មិនថ្លង់
ក៏ត្រូវធ្វើជាថ្លង់, មិនគ ក៏ត្រូវធ្វើជាគ, កូនឯងត្រូវតាំងចិត្ដប្រកាន់
ខ្ជាប់នូវអង្គទាំង ៣ នេះ កុំតាំងខ្លួនជាបណ្ឌិតឲ្យសោះ" ។

ដូច្នេះហើយ ទេវតាបានពោលបន្ដថា ៖

មា បណ្ឌិច្ចយំ វិភាវយ ពាលមតោ ភវ សព្វបាណិនំ
សព្វោ តំ ជនោ ឱចិនាយតុ ឯវំ តវ អត្ថោ ភវិស្សតិ ។

"កូនឯងកុំតាំងខ្លួនជាអ្នកប្រាជ្ញ ត្រូវតាំងខ្លួនឲ្យជនទាំងពួងយល់ថា
កូនល្ងង់វិញ កាលបើជនទាំងពួងយល់ហើយនឹងសម្គាល់កូនថា
ជាមនុស្សកាឡកណ្ណី គង់តែពួកគេបំបរបង់កូនចេញអំពីនគរ ។
តាមវិធីនេះ សេចក្ដីចម្រើននឹងមានដល់កូនជាក់ជាពុំខាន" ។

តេមិយកុមារបានដកដង្ហើមធូរពីភាពតានតឹងក្នុងទ្រូង ដោយសារពាក្យរបស់ទេវតានោះ ហើយពោលតបដូច្នេះ ៖

កាហាមិ តេ តំ វចនំ　　　យំ មំ ភណសិ ទេវតេ

អត្ថកាមាសិ មេ អម្ម　　　ហិតកាមាសិ ទេវតេ ។

"បពិត្រទេវតា ខ្ញុំនឹងធ្វើតាមពាក្យដែលអ្នកប្រាប់ខ្ញុំ ដ្បិតថាអ្នកប្រាថ្នាសេចក្ដីចម្រើននិងប្រយោជន៍ដល់ខ្ញុំ" ។

ក្រោយពេលពោលពាក្យនេះចប់ ព្រះកុមារបានអធិដ្ឋាន[១៣]នូវអង្គទាំង ៣ នោះ ទុកក្នុងព្រះទ័យខ្ជាប់ខ្ជួន ។ រីឯទេវធីតាក៏អន្តរធាន[១៤]បាត់ខ្លួនពីទីនោះទៅ ។

ដើម្បីកែសេចក្ដីអផ្សុករបស់រាជបុត្រ ព្រះមហាក្សត្របានបញ្ជូនកុមារ ៥០០ នាក់ ទៅក្នុងសម្នាក់របស់ព្រះតេមិយកុមារ ។ ពួកទារក

---

[១៣] ការតាំងចិត្ត, ការតាំងចិត្តនឹកតម្រង់ចំពោះ, ការតាំងចិត្តសំបូងសង្រួងឬការសំបូងសង្រួងដោយចិត្តនឹក ឧ. ធ្វើអធិដ្ឋាន ។ ខ្មែរប្រើជា កិ. តាំងចិត្ត, តាំងចិត្តនឹកថា ឱ្យទៅជាដូច្នេះដូច្នោះ ឬថាឱ្យបានសម្រេចដូចបំណងផ្សងប្រាថ្នា ។

[១៤] ការបាត់, ការខូច, សេចក្ដីវិនាស ឧ. នាំបណ្ដាលឱ្យអន្តរធាន ។ ខ្មែរច្រើនប្រើជា កិ. បាត់, បាត់ទៅ, ខូច, ខូចបង់, វិនាស, អន្តរាយ ឧ. អន្តរធានទ្រព្យធនអស់រលីង ។

ទាំងនោះ ស្រែកយំរំអុកទាររកដោះបៅ ។ ចំណែកព្រះមហាសត្វត្រូវភ័យក្នុងនរកគំរាមដល់ព្រះទ័យ មិនយំនឹងគេទេ ខំអត់ធ្មត់ថា ៖

"ការស្គមខ្លួនស្លាប់របស់អញ ប្រសើរជាងការសោយរាជសម្បត្តិ" ។

តាំងពីពេលនោះមក តេមិយកុមារក៏ផ្លាស់ប្ដូរឥរិយាបថរបស់ខ្លួនទៅជាខ្វិន ថ្លង់ និងគ ។

គ្រានោះ ពួកមេដោះរបស់ព្រះអង្គដឹងស្ថានការណ៍នោះ ក៏នាំគ្នាក្រាបទូលចំពោះព្រះនាងចន្ទាទេវី ។ ព្រះនាងក្រាបទូលតដល់ព្រះរាជ-ស្វាមី ។ ព្រះមហាក្សត្រ ទ្រង់បញ្ជាឲ្យទៅអញ្ជើញពួកព្រាហ្មណ៍ទាយនិមិត្តមកសាកសួរ ។

លំដាប់នោះ ព្រាហ្មណ៍ទាំងឡាយក្រាបទូលថា ៖

"បពិត្រព្រះករុណាថ្លៃវិសេស ការឲ្យព្រះរាជកុមារបៅដោះ គួរតែពន្យារពេលឲ្យហួសប្រក្រតី កាលបើធ្វើយ៉ាងនេះ ព្រះរាជកុមារមុខតែយំស្រវាចាប់ដោះបៅដោយខ្លួនឯងមិនខាន ក្រាបទូល" ។

តាំងពីកាលនោះមក មេដោះទាំងឡាយតែងបំបៅដោះព្រះរាជ-កុមារឲ្យហួសវេលាប្រក្រតី, ចួនកាល ឲ្យហួសមួយពេល ទើបឲ្យបៅ, ចួនកាល មិនឲ្យបៅសោះពេញមួយថ្ងៃ ។

# ជំពូកទី ២

## អំពីការសាកល្បងព្រះរាជកុមារដោយវិធីផ្សេង ៗ

### ពិសោធន៍ដោយបង្អត់ទឹកក្សីរ[១៩]ដល់ព្រះកុមារ

*តេមិយកុមារមានចិត្តខ្លាចភ័យក្នុងនរក សុខចិត្តស្គាំងស្គម ក៏មិនយំរំអុកទាររកដោះបៅដែរ ។ កាលព្រះកុមារមិនយំ ទើបព្រះមាតាទ្រង់លើកមកបំបៅដោយអង្គឯង ឬគ្រាខ្លះត្រូវពួកមេដោះបំបៅដោយគិតថា "បុត្ររបស់អញឃ្លានហើយ" ។*

*តំណាលពីទារកផ្សេង ៗ វិញ ហួសពេលបន្តិចមិនបាន ម្នាក់ ៗ ស្រែកយំទាររកដោះបៅ ។ ចំណែកព្រះមហាសត្វដែលរអាភ័យខ្លាចទុក្ខក្នុងនរកមិនយំ មិនលង់លក់ មិនកម្រើកដៃជើង មិនលាន់មាត់ទាល់តែសោះ ។*

*លំដាប់នោះ ស្ត្រីមេដោះទាំងឡាយរបស់ព្រះអង្គពិគ្រោះយោបល់គ្នាថា ៖*

---

[១៩] *ទឹកដោះស្រស់ ។*

"ដៃជើងរបស់មនុស្សខ្វិន មិនមែនបែបនេះទេ, ចុងចង្ការបស់មនុស្សគ មិនមែនបែបនេះទេ, ស្នឹកត្រចៀករបស់មនុស្សថ្លង់ មិនមែនបែបនេះទេ, ហេតុការណ៍នេះចម្លែកណាស់, ដូច្នេះ យើងគួរនាំគ្នាសាកល្បងព្រះកុមារមើល, ជំហានដំបូង យើងសាកល្បងព្រះអង្គដោយទឹកដោះ" ។

លុះគិតគ្នាដូច្នេះហើយ ពួកគេមិនឲ្យដោះព្រះអង្គបៅមួយថ្ងៃវាស់ល្ងាច (ពេញមួយថ្ងៃ) ។

ព្រះតេមិយកុមារ ទោះបីរសេះរសោះអស់កម្លាំងបាក់ពោះគ្រហែតយ៉ាងណា ក៏ព្យាយាមអត់ធ្មត់ មិនលាន់មាត់ធ្វើជាសញ្ញាត្រូវការទឹកដោះអ្វីឡើយ ។

គ្រានោះ ព្រះមាតាបង្ក្រើតលើកព្រះអង្គបំបៅដោយអង្គឯងដោយព្រះទ័យអាណិតថា "បុត្ររបស់អញឃ្លានហើយ" ។

ការសាកល្បងមិនឲ្យដោះបៅជាបន្តបន្ទាប់យ៉ាងនេះអស់រយៈពេលមួយឆ្នាំ នៅតែពុំឃើញព្រះកុមារយំទាររកដោះបៅម្តងណាសោះ ។

## ពិសោធន៍ដោយនំនិងបង្អែមក្នុងព្រះជន្ម ១ ឆ្នាំ

បន្ទាប់មក មន្ត្រីទាំងឡាយមានអាមាត្យជាដើម ក្រាបទូលព្រះមហាក្សត្រថា ៖

"ជាធម្មតា ទារកអាយុ ១ ឆ្នាំ តែងមានចំណង់ចំណូលចិត្តញុំានំ និងបង្អែមណាស់ យើងនឹងយកឧបាយនោះទៅសាកល្បងព្រះកុមារលមើល" ។

លុះក្រាបទូលដូច្នេះហើយ ពួកគេបាននាំកុមារ ៥០០ នាក់ មកអង្គុយក្នុងសម្នាក់របស់តេមិយកុមារ ហើយចាត់ឲ្យអ្នកបម្រើយកនំនិងបង្អែមផ្សេង ៗ ទៅទុកក្បែរព្រះពោធិសត្វ រួចឈរក្នុងទីកំបាំងចាំលបមើលថា តើព្រះកុមារចាប់នំនិងបង្អែមនោះសោយដែរឬទេ?

ទារកផ្សេង ៗ ទាស់ទែងវាយគ្នាដណ្ដើមនំបរិភោគ ។ ចំណែកព្រះមហាសត្តទូន្មានខ្លួនឯងថា "នែតេមិយ អ្នកប្រាថ្នាភ័យក្នុងនរកឬ ឬក៏ប្រាថ្នានំនិងបង្អែម?" ដូច្នេះហើយ ព្រះអង្គរអាភ័យក្នុងនរក មិនយកព្រះទ័យទុកដាក់មើលនំនិងបង្អែមទេ ។

ការសាកល្បងដោយនំនិងបង្អែមជាបន្តបន្ទាប់យ៉ាងនេះ អស់រយៈមួយឆ្នាំដែរ នៅតែពុំឃើញព្រះកុមារបង្ហាញអាការឃ្លាននំនិងបង្អែមម្ដងណាសោះ ។

## ពិសោធន៍ដោយផ្លែឈើក្នុងព្រះជន្ម ២ ឆ្នាំ

បន្ទាប់ពីនោះ មន្ត្រីទាំងឡាយមានអាមាត្យជាដើម ពិគ្រោះគ្នាថា ៖

"ធម្មតា ទារកដែលមានអាយុ ២ ឆ្នាំ តែងមានចំណូលចិត្តបរិភោគផ្លៃឈើតូចធំ យើងនឹងយកផ្លៃឈើសាកល្បងព្រះកុមារមើល" ។

គិតដូច្នេះហើយ ពួកគេបានចាត់អ្នកបម្រើឲ្យយកផ្លៃឈើផ្សេង ៗ ទៅដាក់ក្បែរព្រះពោធិសត្វសាកល្បងលមើល ។

ទារកផ្សេង ៗ ឈ្លោះប្រវាយប្រតប់គ្នាដណ្ដើមផ្លៃឈើបរិភោគ ។ ចំណែកតេមិយកុមារវិញ ហេតុតែខ្លាចរអាសេចក្ដីទុក្ខក្នុងនរក មិនយកព្រះទ័យទុកដាក់សម្លឹងមើលផ្លៃឈើនោះឡើយ ។

ការសាកល្បងដោយផ្លៃឈើតូចធំជាបន្តបន្ទាប់យ៉ាងនេះ អស់រយៈពេលមួយឆ្នាំដែរ នៅតែពុំឃើញព្រះកុមារបង្ហាញអាការៈឃ្លានផ្លៃឈើម្ដងណាសោះ ។

## ពិសោធន៍ដោយគ្រឿងលេងក្នុងព្រះជន្ម ៣ ឆ្នាំ

បន្ទាប់ពីនោះ មន្ត្រីទាំងឡាយមានអាមាត្យជាដើមប្រឹក្សាគ្នាថា ៖

"ធម្មតា ទារកដែលមានអាយុ ៣ ឆ្នាំ តែងមានចំណូលចិត្តខាងកីឡនកណ្ឌ (គ្រឿងលេងរបស់កុមារ) ពួកយើងនឹងសាកល្បងព្រះកុមារដោយកីឡនកណ្ឌនោះ" ។

ជំនុំគ្នាដូច្នេះហើយ ពួកគេបានជួលជាងឲ្យឆ្លាក់រូបដំរី រូបសេះ

ជាដើម ដែលមានខ្លះធ្វើអំពីមាស ខ្លះទៀតធ្វើអំពីវត្ថុនានា រួចយកទៅដាក់ក្បែរព្រះពោធិសត្វ ។

ទារកផ្សេង ៗ ឈ្លោះដណ្ដើមគ្នាលេង ។ ចំណែកព្រះមហាសត្វមិនក្រឡេកមើលអ្វីទាល់តែសោះ ។

ការសាកល្បងដោយគ្រឿងលេងរបស់កុមារ ជាបន្តបន្ទាប់យ៉ាងនេះ អស់រយៈពេលមួយឆ្នាំដែរ នៅតែពុំឃើញព្រះកុមារបញ្ចេញអាការចង់លេងកីឡូនភណ្ឌម្ដងណាសោះ ។

## ពិសោធន៍ដោយភោជនក្នុងព្រះជន្ម ៤ ឆ្នាំ

បន្ទាប់ពីនោះ មន្ត្រីទាំងឡាយមានអាមាត្យជាដើមប្រឹក្សាគ្នាថា ៖ "ជាធម្មតា ទារកដែលមានអាយុ ៤ ឆ្នាំ មានចំណូលចិត្តបរិភោគភោជន យើងនឹងសាកល្បងព្រះកុមារដោយភោជន[១៦] ម្ដងវិញមើល" ។

គិតដូច្នេះហើយ ពួកគេចាត់អ្នកបម្រើឲ្យយកភោជននានា ទៅដាក់ក្បែរព្រះកុមារ ។

[១៦] វត្ថុសម្រាប់បរិភោគ, អាហារ ។

*ទារកផ្សេង ៗ ពួតភោជនជាដុំ ៗ បរិភោគ ។ ចំណែកព្រះមហាសត្វ ទូន្មានខ្លួនឯងថា "នែតេមិយ អ្នកមិនធ្លាប់បានអាហារភោជនបែបនេះ ជាច្រើនអត្តភាពរាប់មិនអស់មកហើយ" ដូច្នេះហើយ ព្រះអង្គខ្លាចរអាសេចក្ដីទុក្ខក្នុងនរក មិនយកព្រះទ័យទុកដាក់សម្លឹងមើលនូវភោជននោះឡើយ ។*

*ក្នុងគ្រានោះ ព្រះមាតារបស់ព្រះមហាសត្វឃើញដូច្នោះ ព្រះនាងស្ទើរតែបែកព្រះឱរាស្ងាប់ អត់សង្កត់ព្រះទ័យមិនបាន ក៏ស្ទុះទៅចាប់អាហារភោជនបញ្ចុកបុត្រ ដោយព្រះហស្តរបស់ព្រះនាងផ្ទាល់ ។*

*ការសាកល្បងដោយអាហារភោជនជាបន្តបន្ទាប់យ៉ាងនេះ អស់រយៈពេលមួយឆ្នាំដែរ នៅតែពុំឃើញព្រះកុមារបង្ហាញអាការឃ្លានភោជនាហារម្តងណាឡើយ ។*

## ពិសោធន៍ដោយភ្លើងក្នុងព្រះជន្ម ៥ ឆ្នាំ

*បន្ទាប់មក មន្ត្រីទាំងឡាយមានអាមាត្យជាដើម ប្រឹក្សាគ្នាថា ៖*

*"ធម្មតា ក្មេងអាយុ ៥ឆ្នាំ តែងតែខ្លាចភ្លើង, យើងនឹងយកភ្លើងមកបន្លាចព្រះកុមារមើល" ។*

*គិតដូច្នេះហើយ ពួកអាមាត្យបានឲ្យជាងធ្វើផ្ទះស្លឹកត្នោតដ៏ធំមួយ ខ្នងមានទ្វារច្រើន នៅឯព្រះលានហ្លួង រួចហើយដាក់ព្រះពោធិសត្វឲ្យ*

អង្គុយកណ្តាល រីឯកុមារផ្សេង ៗ ឲ្យអង្គុយចោមរោមព្រះពោធិសត្វនោះ រួចនាំគ្នាបង្កាត់ភ្លើង ។

កុមារផ្សេង ៗ ក្រឡេកឃើញភ្លើងឆេះ ម្នាក់ ៗ ស្រែកព្ទរំពង រត់រកច្រកចេញយកតែព្រះអាយុស (អាយុជីវិត) ។ ចំណែកមហាសត្វ គិតក្នុងហឫទ័យថា "កម្តៅភ្លើងប៉ុណ្ណោះមិនស្មើកម្តៅភ្លើងក្នុងនរកឡើយ កម្តៅភ្លើងនរកលើសនេះ ១០០ ដង, ១.០០០ ដង, ១០.០០០ ដង, ១០០.០០០ ដងទៅទៀត" ។ គិតដូច្នេះហើយ ព្រះកុមារនៅស្ងៀមនឹងថ្កល់ឥតកម្រើកមើលទៅហាក់ដូចជាព្រះមហាថេរ[១៧] កំពុងចូលនិរោធសមាបត្តិដូច្នោះ ។

គ្រានោះ ភ្លើងឆេះរាលជិតដល់ព្រះមហាសត្វ ទើបពួកមេដោះម្នីម្នាទៅយកតេមិយកុមារចេញ ។

ការសាកល្បងដោយភ្លើងជាបន្តបន្ទាប់យ៉ាងនេះ អស់រយៈពេលមួយឆ្នាំដែរ តែពុំឃើញព្រះកុមារខ្លាចរអាចំពោះភ្លើងម្តងណាសោះ ។

**ពិសោធន៍ដោយដំរីក្នុងព្រះជន្ម ៦ ឆ្នាំ**

បន្ទាប់មក មន្ត្រីទាំងឡាយមានអាមាត្យជាដើមប្រឹក្សាគ្នាថា ៖

---

[១៧] ព្រះថេរៈធំ, ព្រះថេរៈដែលបានសាងផ្នួសយ៉ាងតិចពីត្រឹម ១០ ឆ្នាំឡើងទៅ ហើយមានចំណេះវិជ្ជាជ្រៅជ្រះទាំងផ្លូវលោកទាំងផ្លូវធម៌ ។

"ធម្មតា ក្មេងអាយុ ៦ ឆ្នាំ តែងតែខ្លាចដំរីចុះប្រេង, យើងនឹងល្បង ព្រះកុមារដោយដំរីសាកមើល" ។

គិតដូច្នេះហើយ បានចាត់នាយហត្ថាចារ[១៨] ឲ្យបង្ហឹកដំរីមួយក្បាល ឲ្យចេះស្តាប់បង្គាប់ដាក់លាក់រួចលែងឲ្យដើរទៅរកព្រះមហាសត្វ ដែល ដាក់ឲ្យអង្គុយនៅឯព្រះលានហ្លួង មានកុមារផ្សេង ៗ ចោមរោមជុំជិត ។ ដំរីនោះដើរមកចេះសម្ដែងអាការបំភិតបំភ័យ ដោយបន្លឺកោញ្ចនាទ[១៩] លាន់ឮខ្ទរខ្ទារ ប្រមោយបោយបក់ទៅនឹងផែនប្រឹថពីឮសូរឱបឱបគួរឲ្យ រន្ធត់ក្រៃពេក ។

កុមារផ្សេង ៗ គ្រាន់តែក្រឡេកឃើញដំរីនោះភ្លាម ម្នាក់ ៗ ភិតភ័យ ខ្លាចស្លាប់ រត់បែកខ្ញែកចែកផ្លូវគ្នាទៅគ្រប់ទិសតូចទិសធំ ។ ចំណែក ព្រះមហាសត្វឃើញដំរីចុះប្រេងដើរតម្រង់មក គិតក្នុងហឫទ័យថា "ការ ស្លាប់ដោយប្រមោយដំរីកាច ល្អជាជាងការឆេះក្នុងនរកដ៏សែនក្ដៅ"

---

[១៨] ហត្ថាចារ្យ គឺអាចារ្យអ្នកបង្ហឹកបង្ហាត់ដំរី ហៅម្យ៉ាងទៀត ហ្មដំរី ឬទម័កដំរី អ្នក ទូន្មានដំរី ។

[១៩] ការបន្លឺសូរសព្ទដូចជាសម្រែកនៃសត្វក្រៀល ឧ. ដំរីបន្លឺនូវកោញ្ចនាទ (ប្រើ ចំពោះតែដំរី) ។

ដូច្នេះហើយ ទ្រង់គង់ប្រថាប់នៅទីនោះដដែលមិនគេចវេះទេ ព្រោះនឹករអាដល់ភ័យនៅក្នុងនរកឯណោះវិញ ។

ចំណែកដំរីដែលបង្វឹកថ្មីកល្អហើយនោះ ដើរទៅដល់យកប្រមោយត្រកងចាប់ព្រះមហាសត្តលើកឡើងទៅលើដូចសំណុំផ្កា រួចគ្រវាត់ទៅមក ៗ ថ្នម ៗ មិនឲ្យព្រះពោធិសត្វឈឺចុកចាប់ដល់ខ្លួនប្រាណឡើយ ។

ការសាកល្បងដោយដំរីជាបន្តបន្ទាប់យ៉ាងនេះ អស់រយៈពេលមួយឆ្នាំដែរ ក៏នៅតែពុំឃើញព្រះកុមារមានអារម្មណ៍ភ័យខ្លាចបន្តិចសោះឡើយ ។

## ពិសោធន៍ដោយពស់ក្នុងព្រះជន្ម ៧ ឆ្នាំ

បន្ទាប់មក មន្ត្រីទាំងឡាយមានអាមាត្យជាដើមប្រឹក្សាគ្នាថា ៖

"ធម្មតា ក្មេងអាយុ ៧ ឆ្នាំ តែងខ្លាចសត្វពស់ យើងនឹងល្បងព្រះកុមារដោយពស់សាកមើល" ។

ដូច្នេះហើយ អាមាត្យបានដាក់ព្រះពោធិសត្វឲ្យអង្គុយជាមួយនឹងក្មេងផ្សេង ៗ រួចលែងសត្វពស់ទាំងឡាយ ដែលដកចង្កូមនិងចងមាត់រួចហើយឲ្យលូនកាត់វង់ក្មេង ៗ ។

ក្មេងផ្សេង ៗ ឃើញសត្វពស់ទាំងនោះ ក៏ភ័យខ្លាចរន្ធត់ស្រែកថ្ងូររំពង នាំគ្នារត់គេចចេញ ។ ចំណែកព្រះមហាសត្តរំពឹងដល់ភ័យក្នុង

នរកថា "ការស្លាប់ដោយពស់ពិសនេះចឹកល្អជាងការទទួលរងនូវមហា-ទុក្ខដ៏ធ្ងន់ក្នុងនរក" ។ គិតដូច្នេះហើយ ទ្រង់នៅស្ងៀមនឹងថ្កល់ឥតកម្រើក ហាក់ដូចជាព្រះមហាថេរកំពុងចូលនិរោធសមាបត្តិ ដូច្នោះដែរ ។

គ្រានោះ ពស់រុំព័ទ្ធជុំវិញព្រះកាយ ព្រះរាជកុមារទាំងអស់ រួចបើកពពារ[២០] ពីលើក្បាល ។ ទោះយ៉ាងណាក៏ដោយ ពេលនោះ ព្រះកុមារនៅស្ងៀមដដែល ។

ការយកសត្វពស់មកសាកល្បងព្រះកុមារយ៉ាងនេះអស់រយៈពេលមួយឆ្នាំដែរ នៅតែពុំឃើញព្រះកុមារមានអារម្មណ៍ភ័យខ្លាចបន្តិចសោះឡើយ ។

---

[២០] អាការសម្បើមរបស់ពស់ ដែលប្រឹងដំឡើងកឱ្យរីកធំជាងប្រក្រតី ឧ. ពស់ដកពពារ ។

## ពិសោធន៍ដោយរបាំមហោស្រព[២១]ក្នុងព្រះជន្ម ៨ ឆ្នាំ

បន្ទាប់ពីនោះ មន្ត្រីទាំងឡាយមានអាមាត្យជាដើមពិភាក្សាគ្នាថា ៖ "ធម្មតា ក្មេងអាយុ ៨ ឆ្នាំ មានចំណូលចិត្តខាងរបាំមហោស្រព, យើងនឹងល្បងព្រះកុមារដោយរបាំមហោស្រពនោះសាកមើល" ។

ដូច្នេះហើយ ចាត់ពួកមេដោះយកព្រះតេមិយកុមារទៅដាក់ឲ្យអង្គុយឯព្រះលានហ្លួងជាមួយនឹងក្មេង ៗ ៥០០ នាក់ រួចចាត់ឲ្យគេចាប់ផ្តើមលេងរបាំមហោស្រព ។

កុមារផ្សេង ៗ មើលរបាំមហោស្រពនោះគ្រប់គ្នា ញញឹមសើច[២២] ក្អាកក្អាយ ហ៊ោកញ្ច្រៀវថា "ល្អមើលមែន ! ល្អមើលមែន !" ។ ចំណែក

---

[២១] របាំយ៉ាងធំ, ការលេងល្បែងរបាំគគ្រឹកគគ្រេង, ការរីករាយសប្បាយខ្លាំងដោយល្បែងរបាំ, ការបញ្ចេញរបស់ប្លែក ៗ ដាក់តាំងជារបៀបយ៉ាងធំឱ្យមហាជនមើល, ពិធីសម្ពោធន៍យ៉ាងធំ ឧ. លេងមហោស្រព, មើលមហោស្រព ។

[២២] ហើបបបូរមាត់លាន់សូរសព្ទតិចឬខ្លាំងចេញរន្ទាន់រអឹកទប់មិនឈ្នះ ។ ក្នុងគម្ពីរសុពោធាលង្ការចែកប្រភេទនៃការសើចមាន ៦ យ៉ាងគឺ (១) **សិត** ការសើចមិនចេញអញ្ចាញធ្មេញ, (២) **ហសិត** ការសើចចេញអញ្ចាញធ្មេញ, (៣) **វិហសិត** ការសើចចេញសំឡេងស្រាល ៗ, (៤) **អតិហសិត** ការសើចចេញសំឡេងខ្លាំង, (៥) **ឧបហសិត** ការសើចញ័រខ្លួនប្រាណ, (៦) **អវហសិត** ការសើចចេញទឹកភ្នែក ។

ព្រះមហាសត្តនឹកគិតដល់ភ័យក្នុងនរកថា "ពេលកើតក្នុងនរក តេមិយឯងពុំមានឱកាសបញ្ចេញសំណើចឬការសប្បាយរីករាយ សូម្បីតែមួយវិនាទីសោះ" ក្រោយពីគិតឃើញដូច្នេះហើយ ទ្រង់ពុំបានបញ្ចេញសំណើចនិងកាយវិការអ្វីសោះ គឺនៅស្ងៀម មិនរវល់យកព្រះនេត្រទតមើលនូវរបាំមហោស្រពនោះឡើយ ។

ការសាកល្បងដោយរបាំមហោស្រពជាបន្តបន្ទាប់យ៉ាងនេះ អស់រយៈពេលមួយឆ្នាំដែរ នៅតែពុំឃើញព្រះកុមារបង្ហាញអាការត្រេកត្រអាលរីករាយនឹងរបាំមហោស្រពម្ដងណាសោះ ។

## ពិសោធន៍ដោយមនុស្សគុនក្បាច់ជាចន្លុះព្រះជន្ម ៩ ឆ្នាំ

បន្ទាប់មក មន្ត្រីទាំងឡាយមានអាមាត្យជាដើមពិភាក្សាគ្នាថា ៖ "ធម្មតាក្មេងអាយុ ៩ ឆ្នាំ តែងខ្លាចដាវ, យើងនឹងល្បងព្រះកុមារដោយផ្ទៃដាវនោះសាកមើល" រួចហើយ ដាក់ព្រះកុមារឲ្យអង្គុយរួមជាមួយនឹងកុមារ ៥០០ នាក់ ។

ពេលកុមារផ្សេង ៗ កំពុងអង្គុយប្រលែងគ្នាលេងយ៉ាងសប្បាយ ពួកអាមាត្យចាត់បុរសម្នាក់ឲ្យសម្ដែងអាការជាមនុស្សកាចសាហាវកាន់ដាវចាំងផ្ទេក គុនក្បាច់គ្រវីជុំវិញខ្លួន លាន់ស្នូរខ្ទាប់ ៗ លោតត្រឡប់

លោតផ្លោង បញ្ចេញស្នូរកណ្តាប់ដៃ ហក់ស្ទុះទៅលឿនក្រៃ ស្រែកសន្ធាប់[២៣]ថា ៖

"ឯណាបុត្រកាឡកណ្ណីរបស់ស្តេចកាសិរាជ យើងរកមុខកាត់ក្បាលវា" ។

ឃើញដូច្នោះ កុមារផ្សេង ៗ ភិតភ័យតក់ស្លុតរន្ធត់បាត់អស់ស្មារតី រត់បែកខ្ញែកសព្វទិសា យកតែព្រះអាយុស ។ ចំណែកព្រះមហាសត្តវិញ ជញ្ជឹងដល់ភ័យក្នុងនរក អង្គុយធ្វើព្រងើយដូចជាមិនដឹងស្ពានការណ៍អ្វីសោះ ។

គ្រានោះ បុរសនោះយកដាវកកិតព្រះសីសៈរបស់ព្រះតេមិយកុមារ ហើយសម្លុតថា "យើងនឹងកាត់ក្បាលឯង" ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏មិនអាចធ្វើឲ្យព្រះកុមារភ័យតក់ស្លុតបានដែរ អ្នកកាន់ដាវអស់តម្រិះបញ្ចេញក្បាច់ ទើបដើរចេញពីព្រះកុមារទៅវិញ ។

ការសាកល្បងដោយមនុស្សគុនក្បាច់ដាវជាបន្តបន្ទាប់យ៉ាងនេះ អស់រយៈពេលមួយឆ្នាំដែរ នៅតែពុំឃើញព្រះកុមារមានអារម្មណ៍ភិតភ័យម្តងណាសោះ ។

---

[២៣] ស្រែកគំរាមខ្លាំង, គំហកពេញសំឡេង ឧ. សន្ធាប់ដាក់, ស្រែកសន្ធាប់ ។

## ពិសោធន៍ដោយផ្លុំស័ង្ខក្នុងព្រះជន្ម ១០ ឆ្នាំ

*បន្ទាប់មក ក្នុងពេលព្រះកុមារមានព្រះជន្ម ១០ ឆ្នាំ ដើម្បីដឹងថា ព្រះរាជកុមារ ជាមនុស្សថ្លង់ពិត ឬមិនពិតនោះ មន្ត្រីទាំងឡាយមាន អាមាត្យជាដើម ក៏ធ្វើការសាកល្បងដោយដាក់ឲ្យព្រះរាជកុមារគង់ ប្រថាប់លើសិរីសយនា[២៤] ដែលបិទបាំងជិតដោយវាំងនន រួចចោះ ប្រហោងក្នុងទីទាំង ៤ ខាង ពួនមិនឲ្យព្រះតេមិយកុមារមើលឃើញ ហើយចាត់ អ្នកផ្លុំសង្ខ[២៥] ទាំងឡាយ ឲ្យមកអង្គុយនៅខាងក្រោមក្រឡា ព្រះបន្ទំ បង្គាប់ឲ្យផ្លុំសង្ខឮសំឡេងព្រមគ្នា ។*

*អាមាត្យទាំងឡាយឈរនៅខាងទាំង ៤ លបមើលតាមប្រហោង វាំងនន ទោះជាយ៉ាងណាក៏ដោយ ក៏ពួកគាត់មិនបានឃើញនូវការ ភាំងស្មារតី ការកម្រើកដៃជើងជាកាយវិការប្លែក ឬការប្រែខ្លួនសូម្បីតែ បន្តិច ។*

---

*[២៤] ដំណេកដ៏មានសិរី, ទីសម្រាប់ដេកដ៏មានសិរី, ក្រឡាបន្ទំរបស់ក្សត្រិយ៍ ។*

*[២៥] ខ្យងសមុទ្រមួយបែប គូទស្រួចមានស្នាមវិលស្រួល សម្បុរ-ស សម្រាប់ពួកបារគូផ្លុំ ឬសម្រាប់ដងទឹកសក្តិសិទ្ធិស្រោចក្នុងព្រះរាជពិធីជាដើម ឧ. ពួកបារគូផ្លុំសង្ខ, ស្រោច ទឹកក្ងស់ទឹកសង្ខថ្វាយ ។*

ការសាកល្បងដោយស្នូរសំឡេងសង្ខជាបន្តបន្ទាប់យ៉ាងនេះ អស់រយៈពេលមួយឆ្នាំដែរ នៅតែពុំឃើញព្រះរាជកុមារភាំងស្មារតី ឬកម្រើកកាយម្តងណាសោះ ។

## ពិសោធន៍ដោយស្នូរស្គរក្នុងព្រះជន្ម ១១ ឆ្នាំ

បន្ទាប់ពីនោះ ឈានដល់ឆ្នាំមួយទៀត ជាកាលនៃព្រះកុមារមានព្រះជន្ម ១១ ឆ្នាំ ។

ការសាកល្បងដោយស្នូរស្គរភេរី (ស្គរធំ) អស់រយៈពេល មួយឆ្នាំដែរ នៅតែពុំបានលទ្ធផលដដែល ។

## ពិសោធន៍ដោយពន្លឺប្រទីបក្នុងព្រះជន្ម ១២ ឆ្នាំ

បន្ទាប់ពីនោះ ក្នុងពេលព្រះកុមារមានព្រះជន្ម ១២ ឆ្នាំ មន្ត្រីទាំងឡាយមានអាមាត្យជាដើមប្រឹក្សាគ្នាថា ៖

"យើងនឹងសាកល្បងព្រះកុមារដោយប្រទីបលមើល

តើព្រះកុមារកម្រើកដៃឬជើងក្នុងយប់ងងឹតឬអត់" ។

ជំនុំគ្នាដូច្នេះហើយ ពួកអាមាត្យក៏អុជប្រទីបជាច្រើនដាក់ក្នុងក្អមទាំងឡាយ ពន្ធត់នូវប្រទីបផ្សេង ៗ រួចដាក់ព្រះកុមារឲ្យផ្ទុំក្នុងទីងងឹត

មួយស្របក់ ហើយលើកប្រទីបចេញអំពីក្អមឲ្យភ្លឺព្រម ៗ គ្នា សង្កេតមើលឥរិយាបថព្រះកុមារ ។

ការសាកល្បងដោយប្រទីបជាបន្តបន្ទាប់យ៉ាងនេះអស់រយៈពេលមួយឆ្នាំដែរ នៅតែពុំទទួលបានលទ្ធផល ។

## ពិសោធន៍ដោយទឹកអំពៅក្នុងព្រះជន្ម ១៣ ឆ្នាំ

បន្ទាប់ពីនោះ ក្នុងពេលព្រះកុមារមានព្រះជន្ម ១៣ ឆ្នាំ មន្ត្រីទាំងឡាយមានអាមាត្យជាដើមពិភាក្សាគ្នាថា ៖

"យើងនឹងល្បងព្រះកុមារដោយទឹកអំពៅសាកមើល" ។

ដូច្នេះ ក៏យកទឹកអំពៅលាបពេញព្រះកាយរបស់ព្រះកុមារ រួចយកទៅដាក់ឲ្យផ្ទំក្នុងទីមានសត្វរុយច្រើន ។ ហ្វូងសត្វរុយមករោមពាសពេញសរីរៈរបស់ព្រះកុមារ បឺតជញ្ជក់យករសជាតិផ្អែមដែលជាប់នឹងព្រះកាយព្រះកុមារ មើលទៅដូចជាពួកវាកំពុងចាក់ដោយម្ជុល ។ ទោះបីជាយ៉ាងនេះក្តី ព្រះតេមិយកុមារនៅស្ងៀមនឹងថ្កល់ ហាក់ដូចព្រះមហាថេរកំពុងចូលនិរោធសមាបត្តិ[២៦] ដូច្នោះ ។

---

[២៦] ការចូលឈានដល់ថ្នាក់រំលត់ខ្យល់ដកដង្ហើមចេញចូល តាំងនៅបានអស់កាលកំណត់យ៉ាងយូរត្រឹម ៧ ថ្ងៃ ទើបចេញវិញ ។

ការសាកល្បងដោយទឹកអំពៅជាបន្តបន្ទាប់យ៉ាងនេះ អស់រយៈពេលមួយឆ្នាំដែរ តែពុំឃើញព្រះកុមារកម្រើកកាយម្តងណាសោះ ។

**ពិសោធន៍ដោយអាចម៍និងទឹកនោមក្នុងព្រះជន្ម ១៤ ឆ្នាំ**

បន្ទាប់មក ក្នុងពេលព្រះរាជកុមារមានព្រះជន្ម ១៤ ឆ្នាំ មន្ត្រីទាំងឡាយមានអាមាត្យជាដើមពិភាក្សាគ្នាថា ៖

"ឥឡូវនេះ ព្រះរាជកុមារធំហើយ ចេះស្រឡាញ់របស់ស្អាត ចេះខ្ពើមរបស់មិនស្អាត យើងនឹងសាកល្បងព្រះរាជកុមារនោះដោយរបស់ដែលមិនស្អាតមើល" ។

តាំងអំពីកាលនោះមក មេដោះទាំងឡាយមិនងូតទឹក មិនលាងជម្រះលាមក ថ្វាយព្រះរាជកុមារទេ ។ ព្រះតេមិយកុមារ កាលបន្ទោបង់ឧច្ចារៈនិងបស្សាវៈ (ជុះនិងនោម) ក៏ដេកត្រាំប្រឡាក់អាចម៍និងនោមក្នុងទីនោះឯង ។ សត្វរុយទាំងឡាយរោមស៊ីប្រញាយពាសពេញសរីរៈកាយរបស់ព្រះរាជកុមារ ព្រោះតែក្លិនដ៏ស្អុយឆ្អេះឆ្អាបនោះ មើលទៅហាក់ដូចជាហ្វូងរុយកំពុងហើរចេញអំពីសាកសពដែលស្អុយរលួយមានក្លិនអសោច ។ ព្រះមហាសត្តនៅស្ងៀមមិនកម្រើកកាយវិការអ្វីទេ ស្រាប់តែមេដោះទាំងឡាយ ដែលឈរជុំវិញព្រះមហាសត្តនោះ នាំគ្នាត្មះតិះដៀលថា ៖

"នៃតេមិយកុមារ អ្នកធំពេញវ័យហើយ អ្នកណានឹងផ្គត់ផ្គង់អ្នកឯង គ្រប់ពេល អ្នកមិនបេះខ្មាសគេទេឬអី ? ហេតុម្ដេចបានជាដេកត្រាំក្នុងមូត្រនិងលាមកអ៊ីចឹង[២៧] ក្រោកឡើងសម្អាតកាយខ្លួនឯងមើល" ។ ពួកមេដោះបាននាំគ្នាតិះដៀលដូច្នេះ ។

ព្រះតេមិយកុមារ ទោះបីប្រឡាក់ដោកក្នុងគំនរលាមកគួរខ្ពើមបែបណាក៏ដោយ ក៏ទ្រង់នៅស្ងៀមមិនកម្រើក ដោយនឹកឃើញដល់ក្លិនស្អុយក្នុងរណ្ដៅគូថនរក ជារណ្ដៅនរកមួយប្រភេទដែលពោរពេញដោយលាមក ដែលអាចជះក្លិនស្អុយដល់បេះដូងរបស់មនុស្ស ទោះឈរនៅឆ្ងាយ ១០០ យោជន៍ក៏ដោយ ។

ការសាកល្បងព្រះរាជកុមារដោយអាចម៍និងទឹកនោម ជាបន្តបន្ទាប់យ៉ាងនេះ អស់រយៈពេលមួយឆ្នាំដែរ តែពុំឃើញព្រះរាជកុមារកម្រើកព្រះកាយម្ដងណាសោះ ។

---

[២៧] យ៉ាងហ្នឹង, ដូចហ្នឹង ។ អ៊ី < អ + ៊ + ី ត្រូវផ្លាស់សញ្ញាត្រីសព្ទជាជាស្រះ ុ ដើម្បីកុំឱ្យត្រួតលើគ្នាពីរជាន់ ដូចជាពាក្យ ស៊ី, ហ៊ឺហា ដូច្នោះដែរ (កុំសរសេរ អញ៉ឹង ) ។

**ពិសោធន៍ដោយរងើកភ្លើងក្នុងព្រះជន្ម ១៥ ឆ្នាំ**

បន្ទាប់អំពីនោះ ក្នុងកាលព្រះរាជបុត្រចម្រើនព្រះជន្មបាន ១៥ ឆ្នាំ មន្ត្រីទាំងឡាយមានអាមាត្យជាដើមពិភាក្សាគ្នាថា ៖

"យើងនឹងល្បងព្រះរាជបុត្រនោះ ដោយរងើកភ្លើងសាកមើល" ។ រួចគេនាំគ្នាយកអំបែងទាំងឡាយដ៏ពោរពេញដោយរងើកភ្លើងទៅដាក់ខាងក្រោមគ្រែរបស់ព្រះរាជបុត្រ ដោយគិតថា ៖

"ពេលត្រូវចំហាយក្ដៅហើយ ព្រះរាជបុត្រនឹងមិនអាចទ្រាំនឹងទុក្ខវេទនាបាន ប្រាកដជាកម្រើកកាយវិការពុំខាន" ។

គ្រានោះ កន្ទួលធំ ៗ បានចេញលើសរីរៈរបស់ព្រះរាជបុត្រ ។ ព្រះមហាសត្តនៅស្ងៀមដោយអត់សង្កត់ព្រះទ័យថា ៖

"កម្ដៅនៅឯអវិចីនរក[២៨] ជះចំហាយបានដល់ទៅ ១០០ យោជន៍, ទុក្ខនោះខ្លាំងជាងទុក្ខដែលអញកំពុងទទួលរងនេះ ១០០ ដង, ១.០០០ ដង, ១០.០០០ដង, ១០០.០០០ ដងទៅទៀត" ។

---

[២៨] ឈ្មោះរណ្ដៅនរកធំមួយ បណ្ដារណ្ដៅនរកធំទាំង ៨, សត្វដែលមានបាបធ្ងន់ តែងទៅកើតក្នុងនរកនេះ ។ ពាក្យបាលីចំថា អវីចិ < ន (មិន) + វីចិ (=អន្តរ គឺចន្លោះ) ប្រែថា មិនមានចន្លោះ សំដៅន័យ ៣ យ៉ាងគឺ (១) នរកនេះតែងមានអណ្ដាតភ្លើងឆេះ

គ្រានោះ ព្រះមាតាបិតារបស់ព្រះមហាសត្វ ឃើញសភាពដូច្នោះ ស្មើរតែបែកព្រះរាជហឫទ័យ ទើបដេញមនុស្សទាំងឡាយឲ្យចៀស ចេញហើយ ទ្រង់ក៏ស្ទុះម្ទីម្ទាទៅចាប់លើកបីរាជបុត្រនាំចេញអំពីកម្ដៅ ភ្លើងនោះ ទាំងមានព្រះវាចារអាក់រអួលអង្វរថា ៖

"តេមិយបុត្រសម្លាញ់អើយ, យើងដឹងថា អ្នកមិនមែនខ្វិនថ្លង់គទេ, ពីព្រោះមនុស្សខ្វិន ថ្លង់ គ ពុំមានដៃ ជើង និងស្នឹកត្រចៀកមាន សណ្ឋានបែបនេះឡើយ, បាគឺជាបុត្រដែលយើងបានមកដោយ ការបន់ស្រន់, កុំធ្វើឲ្យយើងអស់ក្ដីសង្ឃឹម, ចូរឲ្យយើងរួចពីពាក្យ ដំណៀល[២៩] របស់ស្ដេចទូទាំងសកលជម្ពូទ្វីប" ។

ទោះបីព្រះមាតាបិតាអង្វរយ៉ាងនេះ ក៏ព្រះមហាសត្វទ្រង់ នៅតែធ្វើ ស្ងៀមធ្វើហាក់ដូចពុំឮអ្វី ៗ ទាំងអស់ ។ គ្រានោះ ព្រះមាតាបិតារបស់ ព្រះអង្គទ្រង់យាងត្រឡប់ទៅវិញ ទាំងព្រះកន្សែងខ្សឹកខ្សួលយ៉ាងខ្លាំង, ពេលខ្លះ ព្រះមាតាយាងចូលមកអង្វរតែមួយអង្គឯង, ពេលខ្លះ ព្រះ

---

ជាប់រហូតឥតស្រាក, (២) សត្វក្នុងនរកនេះមានចំនួនច្រើនណែនណាន់តាន់តាប់ដូច ម្សៅក្នុងនាឡិ, (៣) មានសេចក្ដីទុក្ខឈឺចាប់ពើតពោលពាលខ្លោចផ្សាឥតធូរស្បើយ ។

[២៩] សម្ដីដៀល, សម្ដីរិះគន់, និន្ទាធ្ងន់ ៗ ឧ. គួរប្រយ័ត្ន កុំប្រព្រឹត្តអំពើអាក្រក់ ក្រែងនឹង មានដំណៀលដល់ខ្លួន រាលដាលដល់ផៅពង្សវង្សត្រកូលផង ។

បិតាយាងចូលមកអង្វរតែមួយអង្គឯង ។ ការសាកល្បង ដោយភ្លើងជាបន្តបន្ទាប់យ៉ាងនេះ អស់រយៈពេលមួយឆ្នាំដែរ តែពុំឃើញព្រះរាជបុត្រកម្រើកកាយម្ដងណាសោះ ។

## ពិសោធន៍ដោយកាមគុណក្នុងព្រះជន្ម ១៦ ឆ្នាំ

បន្ទាប់ពីនោះ ក្នុងកាលព្រះរាជបុត្រមានព្រះជន្ម ១៦ ឆ្នាំ មន្ត្រីទាំងឡាយមានអាមាត្យជាដើមប្រឹក្សាគ្នាថា ៖

"ជាធម្មតា មនុស្សគ្រប់រូបឲ្យតែដល់វ័យគ្រប់ការហើយ ទោះជាខ្វិន គ ថ្លង់ ពិការពិកលយ៉ាងណា ក៏តែងតែត្រេកអរក្នុងអារម្មណ៍ដែលគួរឲ្យត្រេកអរ អ្នកដែលមិនត្រេកអរនោះ ឥតអង្គីមាន[៣០] ឡើយ, តែងតែប្រទូស្តក្នុងអារម្មណ៍ដែលគួរឲ្យប្រទូស្ត អ្នកដែលមិនប្រទូស្តនោះ ឥតអង្គីមានឡើយ ដូចជាផ្កាទាំងឡាយ ដល់រដូវត្រូវរីក ក៏រមែងរីកឡើងដូច្នោះដែរ យើងនឹងនាំពួកស្រីរបាំមកល្បងព្រះរាជបុត្រសាកមើល" ។

---

[៣០] ឥតដែលមានសោះ, ទេសោះ (ច្រើនតែដាក់ពាក្យ ក៏ ផ្សំពីខាងដើម) ឧ. ខ្ញុំនឹងដែលបានឃើញរបស់នោះ សូម្បីតែម្ដងក៏ឥតអង្គីមាន ។

ប្រឹក្សាគ្នារួចហើយ អាមាត្យនិងព្រាហ្មណ៍បានហៅស្រីរបាំដែលមានរូបឆោមលោមពណ៌ល្អស្រស់ប្រិមប្រិយ ដល់ព្រមដោយដំណើរកែក្រាយដូចទេពកញ្ញា ឲ្យចូលមកជួបហើយប្រាប់ថា ៖

"បើនាងណាមួយ អាចធ្វើឲ្យព្រះរាជបុត្រសើចឬជាប់ព្រះទ័យដោយកិលេសបាន នាងនោះនឹងបានធ្វើជាអគ្គមហេសីរបស់ព្រះរាជបុត្រ" ។

ពួកស្រីរបាំទាំងនោះបាននាំគ្នាផ្ងូតទឹកក្រអូប តុបតែងថ្វាយព្រះអង្គ ឲ្យដូចជាទេវបុត្រ លើកដាក់លើសិរីសយនាក្រឡាព្រះបន្ទំ ដែលរៀបចំក្រាលស្អាតបាតក្នុងបន្ទប់ដ៏មានសិរី ប្រាកដដូចទេវវិមាន អប់ទាំងគ្រឿងក្រអូប ភួងផ្កា ទឹកអប់ និងលម្អិតជាដើម ធ្វើឲ្យមានក្លិនឈ្ងុយឈ្ងប់ក្រអូបសាយទូទៅពេញបន្ទប់ ហើយនាំគ្នាចេញមកខាងក្រៅវិញ ។

គ្រានោះ ស្ត្រីទាំងឡាយនាំគ្នាទៅចោមរោមជុំជិតព្រះតេមិយកុមារព្យាយាមលួងអភិរម្យ[៣១] ដោយប្រើស្នៀតផ្សេង ៗ មានរាំផង ច្រៀងផងនិយាយផ្អែមល្ហែមដូចទឹកឃ្មុំផងជាដើម ។ ព្រះមហាសត្វមិនក្រឡេក

---

[៣១] ការលួងដោយវិធីផ្សេង ៗ ដើម្បីធ្វើឱ្យរីករាយ ឬត្រេកអរក្រៃពេក ។

មើលនូវស្ត្រីទាំងនោះ ព្រោះទ្រង់បរិបូណ៌ដោយពុទ្ធិ ហើយទ្រង់បាន
អធិដ្ឋានក្នុងចិត្តថា ៖

"សូមកុំឲ្យស្ត្រីទាំងនេះ បានទទួលសម្ផស្សពីការប៉ះសរីរៈអញ
ឡើយ" ។

ខណៈនោះទ្រង់បិទខ្យល់ដកដង្ហើមចេញនិងខ្យល់ដកដង្ហើមចូល
ភ្ជាម, ស្រាប់តែសរីរៈរបស់ព្រះអង្គមានអាការរឹង ។ ស្រី ៗ ទាំងនោះបាន
ប៉ះសរីរៈរបស់ព្រះរាជបុត្រ តែមិនបានទទួលសម្ផស្សទន់ស្រួលគួរជាទី
ពេញចិត្តឡើយ បែរជានាំគ្នាគិតភ័យតក់ស្លុតដូច្នេះថា ៖

"សរីរៈរឹងម៉្លេះបុរសនេះ ! នេះមិនមែនជាមនុស្សទេ ប្រហែលជា
យក្ខហើយមើលទៅ" ។ ម្នាក់ ៗ មិនអាចនៅទីនោះបានក៏ស្ទុះរត់
ចេញមកវិញ ។

ការសាកល្បងដោយស្រីរបាំ ជាបន្តបន្ទាប់យ៉ាងនេះ អស់រយៈ
ពេលមួយឆ្នាំដែរ តែពុំឃើញព្រះរាជបុត្រត្រេកត្រអាលនឹងកាមគុណ
ម្តងណាសោះ ។

សរុបសេចក្តីមក ការសាកល្បងដោយមធ្យោបាយធំ ៗ មាន ១៦
ដង អស់រយៈពេល ១៦ ឆ្នាំ ។ ឯមធ្យោបាយតូចវិញរាប់មិនអស់ តែគ្មាន

នរណាម្នាក់អាចស្តាបស្ទង់យល់ពីជម្រៅនៃដួងព្រះហឫទ័យរបស់ព្រះ
តេមិយបានឡើយ ។

# ជំពូកទី ៣

## អំពីព្រះនាងចន្ទាទេវីទូលសុំពររាជសម្បត្តិ

**បុរោហិតក្រាបទូលព្រះរាជាថាព្រះកុមារជាកាឡកណ្ណី**

*បន្ទាប់មក ព្រះរាជាទ្រង់មានសេចក្តីស្តាយក្រោយជាពន់ពេក ចាត់គេឲ្យទៅអញ្ជើញពួកព្រាហ្មណ៍បុរោហិតអ្នកទាយលក្ខណៈក្នុងថ្ងៃប្រសូតព្រះរាជកុមារ មកចូលគាល់ម្តងទៀត ហើយទ្រង់ត្រាស់ថា ៖*

*"នៃអស់លោក ក្នុងពេលបុត្រយើងទើបនឹងប្រសូតថ្មី ៗ អស់លោកបានទស្សន៍ទាយចំពោះមុខយើងថា បុត្រនេះបរិបូរដោយបុញ្ញលក្ខណៈខាងធញ្ញជាតិ គ្មានអន្តរាយណាមួយកើតប្រាកដដល់គេទេ ប៉ុន្តែឥឡូវនេះ បុត្រយើងនោះជាមនុស្សខ្វិន គ ថ្លង់ទៅវិញ, អ៊ីចឹងការទស្សន៍ទាយរបស់អស់លោក មិនចុតសោះ" ។*

*ពួកព្រាហ្មណ៍ក្រាបទូលថា ៖*

*"បពិត្រមហារាជ ពួកទូលបង្គំអាចមើលដឹងរឿងរ៉ាវគ្រប់យ៉ាងទាំងអស់បាន ប៉ុន្តែបើពួកទូលបង្គំក្រាបទូលព្រះអង្គដោយត្រង់ថា ព្រះរាជបុត្រដែលបានមកដោយរាជត្រកូលធ្វើពិធីបួងសួងសុំ*

ជាបុត្រកាឡកណ្ណីនោះ ព្រះអង្គប្រាកដជាថ្នាំងថ្នាក់ព្រះទ័យពុំខាន ដូច្នេះហើយ ពួកទូលបង្គំពុំហ៊ានទូលថ្វាយតាមការណ៍ពិតឡើយ ក្រាបទូល" ។

គ្រានោះ ព្រះរាជាត្រាស់សួរថា ៖

"តើឥឡូវនេះ យើងគួរធ្វើដូចម្ដេចទៅវិញ ?"

ពួកព្រាហ្មណ៍ក្រាបទូលថា ៖

"បពិត្រមហារាជ បើព្រះអង្គទុកព្រះតេមិយឲ្យនៅក្នុងរាជបុរី[៣២] នេះ មុខជាមានអន្តរាយ ៣ យ៉ាងណាមួយកើតប្រាកដ គឺអន្តរាយដល់ព្រះជន្មព្រះអង្គ១ អន្តរាយដល់ស្វេតច្ឆត្រព្រះអង្គ១ អន្តរាយដល់ព្រះអគ្គមហេសីព្រះអង្គ១ ។ ព្រោះហេតុយ៉ាងនេះ កុំបង្អង់យូរឡើយ ព្រះសម្មតិទេព ! ។ សូមព្រះអង្គទ្រង់ចេញរាជបញ្ជាគេឲ្យយកសេះអបមង្គល[៣៣] និងរថអបមង្គល ទឹមបរដឹករាជបុត្រចេញ

---

[៣២] ក្រុងដែលស្ដេចគង់នៅ ។

[៣៣] ដែលប្រាសចាកឬឃ្លាងចាកមង្គល ឥតមានសេចក្ដីចម្រើន ត្រូវចង្រៃរបរិត ។ ពាក្យ អបមង្គល នេះ ន័យដូចអពមង្គលដែរ ។

ទៅតាមទ្វារទិសខាងលិច ចូលទៅកាន់ព្រៃស្មសាន[៣៤] រួចជីករណ្ដៅជារាងចតុកោណកប់ព្រះរាជបុត្រចោលក្នុងទីនោះ ។ ការដែលព្រះអង្គធ្វើយ៉ាងនេះទើបផុតពីអន្តរាយបាន ក្រាបទូល" ។
ព្រះរាជាខ្លាចភយន្តរាយ យល់ព្រមធ្វើតាមពាក្យរបស់ពួកព្រាហ្មណ៍ ។

## ព្រះរាជាអនុញ្ញាតឲ្យព្រះតេមិយសោយរាជ្យ ៧ ថ្ងៃ

គ្រានោះ ព្រះនាងចន្ទាទេវី បានជ្រាបនូវហេតុការណ៍នោះ ព្រះនាងមិ្មម្នាមួយអង្គឯងចូលទៅថ្វាយបង្គំព្រះមហាក្សត្រក្រាបទូលថា ៖

"បពិត្រព្រះស្វាមី ព្រះអង្គបានប្រទានពរដល់ខ្ញុំម្ចាស់រួចហើយកាលដែលព្រះរាជបុត្រទើបនឹងប្រសូត ពរនោះគឺខ្ញុំម្ចាស់បានទទួលទុក ឥឡូវនេះ សូមព្រះអង្គប្រទានពរនោះដល់ខ្ញុំម្ចាស់" ។
ព្រះរាជាទ្រង់ត្រាស់តបថា ៖

"ទទួលយកចុះ ព្រះទេវី"។
ព្រះនាងចន្ទាទេវីក្រាបទូលព្រះស្វាមីថា ៖

"បពិត្រព្រះសម្មតិទេព សូមព្រះអង្គប្រទានរាជសម្បត្តិដល់បុត្រ

---

[៣៤] ព្រៃខ្មោច, ព្រៃដែលគេយកខ្មោចទៅចោល, ប៉ាឆា ឧ. ព្រៃស្មសាន ឋានស្ងាត់ ។ តាមទម្លាប់ ច្រើននិយាយថា សំសាន ប៉ុន្តែសរសេរ ស្មសាន ដូចដែល ។

របស់ខ្ញុំម្ចាស់" ។

ព្រះរាជាទ្រង់ត្រាស់តបថា ៖

"នៃទេពី ពរនោះយើងមិនអាចប្រទានដល់នាងបានទេ" ។

ព្រះនាងចន្ទាទេវីក្រាបទូលព្រះស្វាមីថា ៖

"បពិត្រព្រះសម្មតិទេព បើទ្រង់ពុំប្រទានរាជ្យរហូតអស់មួយជីវិត សូមប្រទានត្រឹមតែ ៧ ឆ្នាំ ក៏បានដែរព្រះអង្គ" ។

ព្រះរាជាទ្រង់ត្រាស់តបថា ៖

"មិនអាចទេ ទេពី" ។

ទោះជាយ៉ាងនេះក៏ដោយ ព្រះនាងចន្ទាទេវីក្រាបទូលសុំជាបន្ត បន្ទាប់មកទៀតតាំងពី ៦-៥-៤-៣-២ ឆ្នាំ រហូតដល់ ១ ឆ្នាំ ព្រះរាជានៅតែមិនយល់ព្រម ។ ព្រះនាងនៅតែទទូចសុំពី ៧ ខែ ចុះទៅ ៦-៥-៤-៣-២-១ ខែ រហូតដល់ត្រឹមតែកន្លះខែ ព្រះរាជាទ្រង់បដិសេធទៀត ។ ជាចុងក្រោយ ព្រះនាងចន្ទាទេវីក្រាបទូលសុំថា ៖

" សូមព្រះអង្គមេត្តាប្រទានឲ្យបុត្រយើងសោយរាជ្យត្រឹមតែ ៧ ថ្ងៃបានទេ ក្រាបទូល" ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ ត្រាស់តបវិញភ្លាមថា ៖

"ណ្ហើយចុះ ត្រឹមតែ ៧ ថ្ងៃ មិនអីទេព្រះទេពី យើងរាជាអនុញ្ញាតឲ្យ
ចាត់ចែងពិធីរាជាភិសេករាជបុត្រសោយរាជ្យត្រឹម ៧ ថ្ងៃចុះ" ។

ខណៈនោះ ព្រះនាងចន្ទាទេវី បានចាត់អ្នកបម្រើឲ្យប្រដាប់តាក់តែងស្អិតស្អាងរាងកាយថ្វាយព្រះរាជបុត្រ និងចាត់រាជបុរសឲ្យដើរទូងស្គរក្នុងនគរដោយប្រកាសថា "នេះជារាជ្យរបស់តេមិយរាជបុត្រ" ហើយចាត់ឲ្យគេតុបតែងព្រះនគរឲ្យមានសោភណភាព និងបង្គាប់ឲ្យគេលើកព្រះរាជបុត្រដាក់លើ-កដំរី បាំងដោយស្វេតច្ឆត្រ ហែប្រទក្សិណព្រះនគររួចត្រឡប់មកកន្លែងដើមវិញ ហើយព្រះនាងចាត់រាជបុរសឲ្យហែចូលទៅខាងក្នុងព្រះនគរ រួចផ្ដេកព្រះរាជបុត្រលើសិរីសយនា, ពេញមួយរាត្រីនោះ ព្រះនាងអង្វររាជបុត្រជាទីស្រឡាញ់ថា ៖

"ហៃតេមិយបុត្រមាតាអើយ ព្រោះតែបុត្រ ទើបមាតាយំក្ដុកក្ដួល
មិនបានបិទព្រះនេត្រផ្ទំលក់អស់ ១៦ ឆ្នាំមកហើយ ដោយសារ
សេចក្ដីសោកសង្រេងចំពោះបុត្រ ធ្វើឲ្យមាតាស្ទើរតែ[៣៩]បែកហឫ-
ទ័យស្លាប់ មាតាស្គាល់បុត្រច្បាស់ណាស់ថា បុត្រពុំមែនជាមនុស្ស
ខ្វិនគថ្លង់ទេ ចូរបាកុំធ្វើឲ្យមាតាឯកាឥតទីពឹងឡើយ" ។

ព្រះនាងបានអង្វរក្នុងថ្ងៃបន្ទាប់ ៗ តាមទំនងនេះឯងអស់ ៥ ថ្ងៃ ។

---

[៣៩] ស្ទើរតែ ឬស្ទើរនឹង ជានិបាតសព្ទ មានន័យថា ជិតនឹង, ទៀបនឹង ។ មាននិបាតដែលមានន័យដូចគ្នានេះ ដូចជា រកកល់, រិះ, ប៊ិះ, ធិត, ហៀប, អង្គ្រៀត, រៀប, ជិត ។

# ជំពូកទី ៤

## សុនន្ទសារថីនិងព្រះតេមិយ

### សុនន្ទសារថីដឹកព្រះតេមិយយកទៅកប់

*លុះដល់ថ្ងៃទី ៦ ព្រះមហាក្សត្រចាត់គេឲ្យទៅហៅសុនន្ទសារថីមកចូលគាល់ ហើយទ្រង់ត្រាស់បង្គាប់ថា ៖*

*"នែ៎នាយសុនន្ទសារថី ព្រឹកស្អែកនេះ អ្នកត្រូវទឹមសេះអបមង្គលជាមួយនឹងរថអបមង្គល ហើយបរដឹកតេមិយចេញទៅតាមទ្វាររាំងខាងលិចរហូតទៅដល់ព្រៃស្មសាន លុះទៅដល់ព្រៃស្មសានហើយ អ្នកគប្បីជីករណ្ដៅជារាងចតុកោណ រួចដាក់តេមិយក្បែរមាត់រណ្ដៅ ហើយយកត្បូងចបសំពងក្បាលឲ្យបែកស្លាប់ រួចកប់អាចម៍ដីពូនធ្វើផ្នូរទៅ, បន្ទាប់មក ចូរឯងងូតទឹកជម្រះញើសក្អែលឲ្យស្អាត ហើយសឹមត្រឡប់មកវិញ" ។*

*សុនន្ទសារថីក៏បានទទួលធ្វើតាមព្រះរាជបញ្ជា ។*

*សុរិយាទេវទៀបលិចបាត់រស្មី ឈានចូលដល់រាត្រីទី ៦ ព្រះនាងចន្ទាទេវីអង្វររាជបុត្រថា ៖*

"ហៃតេមិយបុត្រសម្លាញ់មាតាអើយ កាសិរាជបិតារបស់បុត្រ បានបង្គាប់ឲ្យគេជីករណ្ដៅកប់បុត្រ ក្នុងវេលាព្រឹកថ្ងៃស្អែកនេះឯង ហើយ, នៅព្រឹកថ្ងៃស្អែកនេះ សេចក្ដីស្លាប់នឹងប្រាកដជាមានដល់បុត្រហើយ" ។

ឮដូច្នោះហើយ ព្រះមហាសត្វគិតថា ៖

"នៃតេមិយ ១៦ ឆ្នាំកន្លងមកនេះ អ្នកឯងបានធ្វើនូវសេចក្ដីព្យាយាម, ឥឡូវសេចក្ដីព្យាយាមនោះបានមកដល់ទីបំផុតហើយ" ។

គិតដូច្នេះរួច ព្រះអង្គកើតបីតិ សេចក្ដីត្រេកអរព្រឺព្រួច ព្រះហឫទ័យមានអំណរជាពន់ពេក ។

ចំណែកព្រះមាតារបស់ព្រះមហាសត្វ ស្ទើរតែបែកព្រះរាជហឫទ័យ, បើទុកជាដូច្នេះក្ដី ព្រះមហាសត្វពុំបានចរចាជាមួយនឹងព្រះមាតាមួយម៉ាត់ឡើយ ព្រោះព្រះអង្គគិតថា ៖

"គោលបំណង របស់ខ្លួនជិតបានសម្រេចហើយ" ។

បន្ទាប់អំពីរាត្រីនោះកន្លងផុតទៅ អរុណោទ័យចាប់ផ្ដើមបញ្ចេញរស្មីពណ៌ក្រហមព្រឿង ៗ នៅឯទិសបូព៌ា នាយសុនន្ទសារថីក៏រៀបចំទឹមរថ ។

ក្នុងខណៈនោះ ដោយអានុភាពនៃទេវតានិងដោយអានុភាពនៃបារមីរបស់ព្រះមហាសត្តផ្ទាល់ បណ្តាលឲ្យនាយសុនន្ទសារថីទឹមសេះមង្គលជាមួយនឹងរថមង្គលទៅវិញ រួចក៏បររថនោះទៅបញ្ឈប់ក្បែរព្រះរាជដំណាក់ ។ រួចហើយនាយសារថីដើរឡើងទៅលើព្រះរាជមន្ទីរ[៣៦] ចូលទៅក្នុងក្រឡាព្រះបន្ទំរបស់ព្រះនាងចន្ទាទេវី ហើយក្រាបបង្គំទូលថា ៖

"បពិត្រព្រះទេពី កុំទ្រង់ខ្វាល់ចំពោះទូលព្រះបង្គំជាខ្ញុំឡើយ ទូលព្រះបង្គំជាខ្ញុំធ្វើតាមតែព្រះរាជបញ្ជាទេ ក្រាបទូល" ។

បន្ទាប់មកនាយសារថីក៏យកដៃកៀសព្រះនាងទេពីដែលកំពុងផ្ទំឱបព្រះរាជបុត្រចេញ រួចចាប់លើកព្រះរាជបុត្របីដើរចុះអំពីប្រាសាទមើលទៅដូចជាមនុស្សលើកបីត្រកងបាច់ផ្កាដូច្នោះ ។

គ្រានោះ ព្រះនាងចន្ទាទេវីគក់ព្រះឱរាសោកាសង្រេងដោយព្រះសរនីយ៍ខ្លាំង ៗ ភាន់ភាំងអស់ព្រះស្មារតី ម្ចាស់ក្សត្រីទ្រង់ទ្រឹងព្រះកាយនៅនឹងមួយកន្លែងក្នុងព្រះរាជមន្ទីរ ។

ក្លាមនោះ ព្រះមហាសត្តបែរព្រះភក្ត្រទតសម្លឹងទៅព្រះមាតាដែលទ្រង់កំពុងព្រះកន្សែងសោកសង្រេង ព្រះអង្គប្រាថ្នានឹងពោលព្រះវាចាឲ្យបានខ្លះ ក្នុងបំណងថា ៖

---

[៣៦] លំនៅឋានរបស់ក្សត្រិយ៍, ព្រះរាជដំណាក់ ។

"បើអញមិននិយាយទេ មុខតែព្រះមាតាបែកព្រះហឫទ័យសោយព្រះវិលាល័យពុំខានឡើយ" ។ តែទ្រង់មានព្រះតម្រិះទប់ស្មារតីអត់សង្កត់ព្រះទ័យវិញថា "ប្រសិនបើអញនិយាយក្នុងពេលនេះសេចក្ដីព្យាយាមដែលអញប្រឹងប្រែងធ្វើអស់ ១៦ ឆ្នាំកន្លងមក នឹងក្លាយជាអសារឥតការសម្រាប់អាត្មាអញមិនខាន, កាលបើអាត្មាអញអត់សង្កត់ចិត្តទ្រាំមិននិយាយបាន គង់នឹងបានជាបច្ច័យយឹតយោងដល់អាត្មាអញនេះផង ដល់ព្រះមាតាបិតាផង ដល់មហាជនផង" ។

គ្រានោះ នាយសុនន្ទសារថីលើកព្រះតេមិយដាក់លើរថបរចេញទៅដោយគិតថា ៖

"អញនឹងបរចេញតាមទ្វារខាងលិច តែដោយអានុភាពនៃបារមីរបស់ព្រះមហាសត្ត នាយសារថីត្រូវទេវតាបង្វែរឲ្យបររថឆ្ពោះមុខទៅទ្វារទិសខាងកើតវិញ បណ្ដាលឲ្យធរណីទ្វារ[៣៧] ខ្ទង់ខ្ទប់លែងរាបស្មើស្អាតដូចមុន ដោយសារកង់រថដែលបត់បែរបរទៅនោះ" ។ ចំណែកព្រះមហាសត្តឮស្នូររថបរចេញទៅ ទ្រង់មានព្រះទ័យត្រេកអរជាខ្លាំង ដោយមានព្រះតម្រិះថា ៖

[៣៧] មេទទឹងទ្វារដែលដាក់ផ្ទាល់នឹងផែនដីឬនឹងផ្ទៃខាងក្រោម ។

"គោលបំណងរបស់អាត្មាអញ បានសម្រេចហើយ" ។

រថដែលបរចេញអំពីនគរទៅបានចម្ងាយត្រឹមតែ ៣ យោជន៍ ដោយអានុភាពនៃទេវតា នាយសារថីឃើញព្រៃស្នាប់[៣៨] នៅម្តុំនោះ យល់ថាជាព្រៃស្មសានសម្រាប់កប់ឬចោលខ្មោចទៅវិញ ។ សុនន្ទសារថីកំណត់សម្គាល់ឃើញទីមួយកន្លែងមានផាសុកភាព ក៏បំបែររថគេចចេញអំពីផ្លូវទៅឈប់នៅម្ខាងផ្លូវ ចុះពីរថហើយដោះគ្រឿងអាភរណៈ[៣៩] របស់ព្រះបរមពោធិសត្វ ប្រមូលចងជាបង្វេចទុកដាក់ក្នុងទីសមគួរមួយហើយ ទាញចបលីដើរទៅមិនឆ្ងាយអំពីរថប៉ុន្មានទេ គេក៏ចាប់ផ្តើមជីករណ្តៅដែលមានទំហំជារាង ៤ ជ្រុង ។

## ព្រះតេមិយឈរគ្រវីរថ

បន្ទាប់អំពីនោះ ព្រះពោធិសត្វមានព្រះតម្រិះថា ៖

---

៣៨ ដែលញៀតញឹកជុកជិត, ព្រៃដែលមានដើមឈើដុះក្រាស់ឃ្មឹក ។

៣៩ គ្រឿងប្រដាប់កាយ, អលង្ករណ៍, អលង្ការ ។ ខ្មែរប្រើតាមសម័យនិយមហៅគ្រឿងឥស្សរិយយស ឬគ្រឿងតម្កើងកិត្តិយស ( មេដាយ ) ហៅថា អាភរណៈ ដែរ ដូចជា អាភរណៈអស្សឫទ្ធិ, អាភរណៈសេនា, មុនីសារាភរណៈ ឬមុនីសារាភរណ៍ ។

"ពេលនេះជាពេលដែលអាត្មាអញត្រូវបញ្ចេញកាយវិការហើយ ព្រោះអាត្មាអញខានធ្វើចលនាដៃជើងអស់រយៈពេល ១៦ ឆ្នាំ មកហើយ, តើអាត្មាអញមានកម្លាំងពលំឬអត់?" ។

ព្រះតម្រិះដូច្នេះហើយ ទ្រង់ក៏ក្រោកឈរឡើង យកព្រះហស្ដឆ្វេងស្ទាបព្រះហស្ដស្ដាំ ព្រះហស្ដស្ដាំស្ទាបព្រះហស្ដឆ្វេង ឱនព្រះកាយយកព្រះហស្ដទាំងទ្វេស្ទាបព្រះបាទទាំងសងខាង គ្រាន់តែនឹកគិតថានឹងចុះអំពីរថ រំពេចនោះ ស្រាប់តែមហាប្រឹថពីប៉ោងផុសឡើង ដូចជាប៉ីតប៉ោងពេញដោយខ្យល់ មានកម្ពស់ស្មើនឹងប្រែករថ ល្មមឲ្យព្រះអង្គដាក់ព្រះបាទចុះយ៉ាងស្រួល ។

ព្រះបរមពោធិសត្វយាងចុះអំពីរថ ឈានពីរបីជំហានទៅមក ៗ សាកកម្លាំងមើលទើបជ្រាបថា ៖

"កម្លាំងរបស់អាត្មាអញខ្លាំងបែបនេះ អាចដើរមួយថ្ងៃបានចម្ងាយ ១០០ យោជន៍ ក៏បានដែរ" រួចទ្រង់ត្រិះរិះថា ៖

"ចុះប្រសិនបើនាយសារថីក្រោធខឹងរកដាល់អាត្មាអញ តើអាត្មាអញមានកម្លាំងដាល់តបតជាមួយនឹងគេបានដែរឬទេ ?" ។

ពេលនោះ ព្រះអង្គចង់សាកល្បងមើលកម្លាំង ក៏ទ្រង់ចាប់ក្បាលក្រពើរទេះលើកឡើងទៅលើ ឈរគ្រវីបង្វិលល្បងមើលកម្លាំង ដូចជាគ្រវីកូន

រទេះរបស់ពួកក្មេង ៗ លេងដូច្នោះ ។ ក្រោយពេលកំណត់ដឹង កម្លាំងរបស់ព្រះអង្គថា អាចតទល់ជាមួយនឹងនាយសារថីបាន ទើបព្រះអង្គមានប្រាថ្នារកគ្រឿងប្រដាប់កាយ ។

## កំណត់សម្គាល់

ការសាងបារមីទាំង ១០ របស់និយតពោធិសត្វ បានញ៉ាំងព្រះអង្គឲ្យទទួលនូវគុណធម៌ដ៏មហាវិសេសវិសាលខ្ពស់បំផុតលើលោក ដែលពុំមាននរណាម្នាក់ប្រៀបប្រដូចបាន ទោះបីព្រះអង្គខានធ្វើលំហាត់ប្រាណអស់ ១៦ ឆ្នាំ ក៏ទ្រង់នៅមានកម្លាំងពលំ កាយសម្បទាមាំមួនខុសពីមនុស្សធម្មតា ។ អំឡុងពេល ១៦ ឆ្នាំនោះ ព្រះអង្គពិតជាពុំមានកាយវិការបន្តិចបន្តួចមែន សូម្បីក្នុងពេលរាត្រីដែលស្ងាត់ ក៏ព្រះអង្គពុំមានព្រះទ័យនឹកហាត់ប្រាណបន្ធូរបន្ថយការស្ពឹកស្រពន់ ឬការពោយដៃជើងនោះដែរ ពីព្រោះរាជវាំងបានដាក់ការពិសោធន៍និងការឃ្លាំមើលទៅលើព្រះតេមិយពោធិសត្វយ៉ាងហ្មត់ចត់និងជិតដល់ជាទីបំផុតតាមព្រះរាជបញ្ជារបស់ព្រះមហាក្សត្រជាព្រះវររាជបិតា ដ្បិតថាពុំមាននរណាម្នាក់ជឿថាព្រះតេមិយពោធិសត្វជាមនុស្សគថ្លង់ខ្វិនឡើយ បើបានឃើញអវយវៈតូចធំរបស់ព្រះអង្គ ។ម្យ៉ាងទៀត អធិដ្ឋានគឺជាការតាំងចិត្តប្តេជ្ញាខ្លួនមោះមុត ក្នុងការប្រតិបត្តិឲ្យខាងតែបាន ឆ្ពោះទៅ

សម្រេចទិសដៅរបស់ខ្លួន ទោះអ្នកដទៃមិនឃើញក្តី ក៏មិនហ៊ានទម្លាយអធិដ្ឋានដែរ ដូច្នេះពុំមានអំណះអំណាងណាដែលថាព្រះតេមិយពោធិសត្វលួចហាត់ប្រាណពេលយប់ស្ងាត់ ឬពេលអជ្រាតនោះឡើយ ។

ចំណុចអច្ឆិយៈគួរឲ្យស្ញើច ហួសវិស័យនឹងគិតដល់ របស់ព្រះមហាសត្វ ឬព្រះនិយតពោធិសត្វនៃយើង មានច្រើនជាតិណាស់ដូចជា ៖

- កំណើតជាព្រះមហោសថ គឺគ្រាន់តែព្រះអង្គប្រសូតចាកឧទរនៃព្រះមាតាមកភ្លាម ក៏ចេះនិយាយប្រាប់ថ្នាំកែរោគដ៏សក្តិសិទ្ធិដល់ព្រះមាតា
- កំណើតជាព្រះវេស្សន្តរ គឺគ្រាន់តែព្រះអង្គប្រសូតចាកឧទរនៃព្រះមាតាមកភ្លាម ក៏ចេះមានព្រះបន្ទូលសុំព្រះរាជទ្រព្យធ្វើទាន អំពីព្រះមាតា
- កំណើតជាព្រះសិទ្ធត្ថ គឺគ្រាន់តែព្រះអង្គប្រសូតចាកឧទរនៃព្រះមាតាមកភ្លាម ក៏ដើរបាន ៧ ជំហានហើយលាន់ព្រះឱស្ឋថាខ្លួនព្រះអង្គជាកំពូលជាចម្បងលើគេក្នុងលោក អំណើះតទៅមុខ ព្រះអង្គលែងមានកំណើតក្នុងភពទៀតហើយ ។ល។

ចំពោះព្រះកាយពលរបស់ព្រះមហាសត្វ ដែលបានត្រាស់ជាអង្គព្រះសព្វញ្ញុពុទ្ធហើយ រមែងសម្រេចបាននូវកម្លាំងដ៏ខ្លាំងក្លាផ្នែកសរីរកាយ

១០ យ៉ាង (**ទសកាយពល**) ។ កម្លាំងនោះខ្លាំងហួសពីសាមញ្ញជនយើង ឆ្ងាយណាស់ ដោយប្រៀបធៀបទៅនឹងកម្លាំងនៃត្រកូលដំរីទាំង ១០ ដូចខាងក្រោម ៖

១- កម្លាំងដំរីត្រកូលកាឡាវក ១០ ស្មើនឹងកម្លាំងដំរីត្រកូលគង្គេយ្យ ១ ។

២- កម្លាំងគង្គេយ្យ ១០ ស្មើនឹងកម្លាំងដំរីត្រកូលបណ្ឌរ ១

៣- កម្លាំងបណ្ឌរ ១០ ស្មើនឹងកម្លាំងដំរីត្រកូលតម្ព ១

៤- កម្លាំងតម្ព ១០ ស្មើនឹងបិង្គល ១

៥- កម្លាំង បិង្គល ១០ ស្មើនឹងកម្លាំងគន្ធ ១

៦- កម្លាំងគន្ធ ១០ ស្មើនឹងមង្គល ១

៧- មង្គល ១០ ស្មើនឹងហេមវត ១

៨- ហេមវត ១០ ស្មើនឹងឧបោសថ ១

៩- ឧបោសថ ១០ ស្មើនឹងកម្លាំងដំរី ឆទ្ទន្ត ១

១០- កម្លាំងដំរីឆទ្ទន្ត ១០ ស្មើនឹងកម្លាំងព្រះពុទ្ធ ១ អង្គ

ដូច្នេះនឹងឃើញបានថា កម្លាំងនៃព្រះកាយពលរបស់ព្រះសម្មាសម្ពុទ្ធ ១ ព្រះអង្គ ស្មើនឹងកម្លាំងដំរីប្រក្រតី ១ ពាន់កោដិ ឬស្មើនឹងកម្លាំងបុរស ១០ ពាន់កោដិ ។ ចំពោះព្រះពោធិសត្វដែលពុំទាន់ត្រាស់ដឹង គឺក្នុង

សភាវៈជានិយតពោធិសត្វដូចជា ព្រះតេមិយ ព្រះមហាជនក ព្រះមហោសថ ព្រះវេស្សន្តរ ជាដើមនៅឡើយ ក៏ព្រះអង្គទ្រង់សម្រេចបាននូវព្រះកាយពលខ្លាំងក្លាជាពន់ពេកដែរ ដូចក្នុងជាតកមួយ ព្រះអង្គយោនយកកំណើតជាសត្វគោឈ្មោះនន្ទិវិសាល បានអូសរទេះ ៥០០ ដែលផ្ទុកពេញដោយសម្ភារៈ ។

**ព្រះតេមិយទ្រង់គ្រឿងប្រដាប់កាយដូចសក្កទេវរាជ**

ក្នុងខណៈនោះ ភពរបស់ស្ដេចសក្កទេវរាជមានអាការក្ដៅស្អុះស្អាប់កើតឡើង ។ ស្ដេចសក្កទេវរាជរំពឹងមើលទៅជ្រាបស្ថានការណ៍នោះថា ៖

"យីអើ ! គោលបំណងរបស់ព្រះតេមិយបានសម្រេចហើយហ្ន៎ ឥឡូវ ព្រះតេមិយនឹកចង់ទ្រង់គ្រឿងប្រដាប់កាយ តែគ្រឿងប្រដាប់កាយជារបស់មនុស្ស មិនសមគួរដល់ព្រះអង្គទេ" ។

ទ្រង់ព្រះតម្រិះដូច្នេះហើយ សក្កទេវរាជក៏ប្រើទេវតាមួយអង្គឲ្យយកគ្រឿងប្រដាប់ទិព្វមកថ្វាយ រួចប្រើឲ្យទៅហៅវិស្សកម្មទេវបុត្រមកចូលគាល់ នៅពេលដែលវិស្សកម្មទេវបុត្រមកដល់ ទ្រង់បង្គាប់ថា ៖

"ម្នាលវិស្សកម្មទេវបុត្រ ចូរអ្នកយកគ្រឿងអម្ពរ[៤០] នេះ ទៅតុបតែងថ្វាយព្រះតេមិយជាបុត្ររបស់ស្តេចកាសិរាជ" ។

គ្រានោះ វិស្សកម្មទេវបុត្រទទួលបង្គាប់ហើយ បានចុះចាកភពតាវត្តិង្ស មកកាន់ភពមនុស្ស ចុះចំត្រង់សម្នាក់របស់ព្រះតេមិយនោះ ហើយក៏បានតុបតែងកាយព្រះតេមិយដោយគ្រឿងអលង្ការ[៤១] ផ្សេង ៗ ជារបស់សួគ៌ផង ជារបស់មនុស្សផង គ្រាន់តែឈ្នួតដែលរុំព្រះសិរសា គឺធ្វើដោយសំពត់ ១០.០០០ ផ្ទាំង ។

បន្ទាប់ពីវិស្សកម្មទេវបុត្របានតុបតែងកាយព្រះតេមិយរួចហើយ ព្រះតេមិយស្រស់សង្ហាហាក់ដូចជាស្តេចសក្កទេវរាជបេះបិទ[៤២], កាលបើវិស្សកម្មទេវបុត្រធ្វើកិច្ចការចប់សព្វគ្រប់ហើយ ក៏វិលទៅកាន់លំនៅរបស់ខ្លួនវិញហោង ។

ព្រះតេមិយបរមពោធិសត្វ មានដំណើរយាងយាសកែក្រាយ ដូចសក្កទេវរាជ សំដៅឆ្ពោះទៅរកនាយសុនន្ទសារថីដែលកំពុងជីកលុង

---

[៤០] សំពត់គ្រឿងស្លៀកពាក់ ។

[៤១] គ្រឿងប្រដាប់សម្រាប់តាក់តែងខ្លួន មានចិញ្ចៀន, កងដៃ, ខ្សែដៃ, ខ្សែខ្លួនជាដើម ។ ពាក្យនេះមានន័យដូចពាក្យ អលង្ករណ៍ ដែរ ។

[៤២] ដូចណាស់, ដូចគេបេះពីម្ខាងយកមកបិទភ្ជាប់ម្ខាង ។

រណ្ដៅ ។ ព្រះអង្គទ្រង់ឈរក្បែររណ្ដៅសួរឆ្លងឆ្លើយគ្នាជាមួយនឹងនាយសារថី ដូចខាងក្រោមនេះ ៖

តេមិយទ្រង់សួរថា ៖

"នែនាយសារថី អ្នកប្រញាប់ប្រញាល់ជីករណ្ដៅ តើព្រោះហេតុអ្វី? ម្នាលសម្លាញ់ ខ្ញុំសួរអ្នកហើយ ចូរអ្នកប្រាប់ខ្ញុំផង តើអ្នកជីករណ្ដៅកប់អ្វី?"

នាយសារថីឮដូច្នោះហើយ ដោយខ្លួនកំពុងតែជាប់ដៃជីកលុងរណ្ដៅពុំបានងើយមើលលើ ឆ្លើយតបទាំងឈ្ងោកមុខថា ៖

"ព្រះរាជបុត្រយើងប្រសូតមកហើយ ស្រាប់តែថ្លង់ផង គផង ខ្វិនផង ព្រះរាជាត្រាស់បង្គាប់ឲ្យមកជីករណ្ដៅ ដើម្បីកប់បុត្ររបស់ព្រះអង្គក្នុងព្រៃនេះ" ។

តេមិយទ្រង់បញ្ជាក់ប្រាប់ថា ៖

"ខ្ញុំមិនថ្លង់ មិនគ មិនខ្វិន មិនមែនវិកលវិការទេ នែនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថា ធ្វើខុសក្នុងធម៌ អ្នកចូរមើលជើងនិងដើមដៃរបស់ខ្ញុំ ចូរស្ដាប់សម្ដីខ្ញុំ" ។

គ្រានោះ នាយសារថីជញ្ជឹងគិតដូច្នេះថា "នរណាគេហ្ន៎ អួតខ្លួនម្ល៉េះតាំងពីមកដល់ភ្លាម!" ។ គាត់ផ្អាកជីករណ្ដៅ ហើយងើបមុខមើលលើ

ស្រាប់តែឃើញរូបសម្បត្តិរបស់ព្រះបរមពោធិសត្វ នឹកឆ្ងល់ថា "បុរសនេះ ជានរណាហ្ន៎, ជាមនុស្សឬទេវតា" ហើយសួរថា ៖

"អ្នកជាទេវតាឬជាគន្ធព្វ ឬក៏ជាសក្កទេវរាជ ? អ្នកជាអ្វី ? អ្នកជាកូនរបស់អ្នកណា ? ធ្វើដូចម្ដេច ទើបយើងអាចស្គាល់អ្នកបាន ?"

គ្រានោះ ព្រះបរមពោធិសត្វណែនាំខ្លួនឲ្យនាយសារថីបានស្គាល់ ថែមទាំងពន្យល់ធម៌ដោយពោលនូវគាថានេះ ៖

"ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាសក្កទេវរាជទេ ខ្ញុំនេះឯងជាបុត្ររបស់ព្រះបាទកាសិរាជ ដែលអ្នកបម្រុងកប់នៅក្នុងរណ្ដៅនោះ ។ ខ្ញុំជាបុត្ររបស់ព្រះរាជាដែលអ្នកអាស្រ័យរស់នៅប្រកបដោយសេចក្ដីសុខហ្នឹងឯង ។ នៃនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថាធ្វើខុសធម៌ បុគ្គលមិនត្រូវកាច់បំបាក់មែកឈើដែលខ្លួនបានចូលទៅអង្គុយឬដេកនៅខាងក្រោមដើមឈើនោះទេ ព្រោះថា ដើមឈើដែលបុគ្គលនោះបានជ្រកកោន ទុកដូចជាមិត្រ កាលបើបុគ្គលនោះកាប់មែក បូតស្លឹក ឬក្តិចត្រួយបំផ្លាញចោល ឈ្មោះថាជាមនុស្សអាក្រក់ ព្រោះសម្លាប់មិត្រ ចាំបាច់និយាយថ្វីដល់មនុស្សដែលសម្លាប់កូនចៅហ្វាយនាយរបស់ខ្លួននោះ ។ នៃនាយសារថី ព្រះរាជាជាព្រះបិតាខ្ញុំ ទុកដូចជាដើមឈើ

ខ្លួនខ្ញុំជាបុត្រទុកដូចជាមែកឈើ អ្នកឯងដែលអាស្រ័យនៅនឹងព្រះរាជអង្គនោះ ទុកដូចជាបុគ្គលដែលបានចូលទៅជ្រកក្រោមម្លប់ឈើដូច្នោះ ។ នៃនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថាធ្វើខុសនឹងធម៌ ។

ទោះបីព្រះពោធិសត្វរ៉ាយរ៉ាប់ប្រាប់យ៉ាងនេះក៏ដោយ ក៏នាយសុនន្ទសារថីនោះមិនជឿទាល់តែសោះ ។ គ្រានោះព្រះមហាសត្វបានព្យាយាមពន្យល់សុនន្ទសារថីឲ្យជឿព្រះអង្គ ដោយទ្រង់លើកយកនូវអានិសង្សនៃការគោរពបូជាមិត្ត ១០ ប្រការ មកបរិយាយ ។ សំឡេងគ្រាំងគ្រឹម[៤៣]របស់ព្រះអង្គ លាយឡំដោយសំឡេងថ្វាយសព្ទសាធុការពររបស់ពពួកទេវតាផងនោះ ក្នុងព្រៃក៏លាន់ឮសំឡេងកងរំពងទ្រហឹងអឺងកង ហាក់ដូចជាសំឡេងវាយគង ។ អានិសង្សនៃការគោរពបូជាមិត្ត ១០ ប្រការ ដែលព្រះតេមិយពោធិសត្វសម្ដែងនោះគឺ ៖

១- បហូតភក្ខោ ភវតិ, វិប្បវុដ្ឋោ សកំ ឃរា;
ពហូ នំ ឧបជីវន្តិ, យោ មិត្តានំ ន ទុព្ភតិ ។

[៤៣] សូរសំឡេងលាន់រំពងសាយពីពោះ ។

បុគ្គលណាមិនទ្រុស្តកល្យាណមិត្រ[៤៤] ទាំងឡាយ មានព្រះពុទ្ធជាដើម បុគ្គលនោះទោះបីចេញអំពីផ្ទះរបស់ខ្លួន (ទៅទីណា ៗ) ក៏រមែងជាអ្នកមានភក្សាហារ[៤៥] ច្រើន មនុស្សទាំងឡាយតែងចិញ្ចឹមទំនុកបម្រុងជីវិតបុគ្គលនោះ ។

២- យំ យំ ជនបទំ យាតិ, និគមេ រាជធានិយោ;
សព្វត្ថ បូជិតោ ហោតិ, យោ មិត្តានំ ន ទុព្ភតិ ។

បុគ្គលណាមិនទ្រុស្តកល្យាណមិត្រទាំងឡាយ បុគ្គលនោះកាលទៅកាន់និគម ជនបទឬរាជធានីណា ៗ រមែងមានអ្នកបូជាក្នុងទីនោះ ៗ ។

៣- នាស្ស ចោរា បសាហន្តិ, នាតិមញ្ញន្តិ ខត្តិយា;
សព្វេ អមិត្តេ តរតិ, យោ មិត្តានំ ន ទុព្ភតិ ។

---

[៤៤] មិត្រល្អ, មិត្រត្រឹមត្រូវដែលគួរសេពគប់, គួររាប់រកយកជាគ្នាមាន ៤ ប្រភេទគឺ មិត្រមានឧបការៈ ១ មិត្ររួមសុខទុក្ខ ១ មិត្រប្រាប់ផ្លូវដែលមានប្រយោជន៍ ១ មិត្រមានសេចក្តីអាណិត ១ ។

[៤៥] ចំណីអាហារឬអាហារជាចំណីសម្រាប់បរិភោគ ។

*បុគ្គលណាមិនទ្រុស្តកល្យាណមិត្រទាំងឡាយ ពួកចោរក្តី ក្សត្រទាំងឡាយក្តីរមែងមិនគំរាមកំហែង មិនមើលងាយចំពោះបុគ្គលនោះ និងជាអ្នកមិនមានសត្រូវគ្រប់ទីកន្លែង ។*

៤- អក្កុទ្ធោ សឃរំ ឯតិ, សភាយំ បដិនន្ទិតោ;
ញាតីនំ ឧត្តមោ ហោតិ, យោ មិត្តានំ ន ទុព្ភតិ ។

*បុគ្គលណាមិនទ្រុស្តកល្យាណមិត្រទាំងឡាយ បុគ្គលនោះរមែងមិនយកកំហឹងចូលផ្ទះរបស់ខ្លួន ជាអ្នកត្រូវគេទទួលរាក់ទាក់ក្នុងទីប្រជុំជន និងជាបុគ្គលដ៏ឧត្តមរបស់ពួកញាតិ ។*

៥- សក្កត្វា សក្កតោ ហោតិ, គរុ ហោតិ សគារវោ;
វណ្ណកិត្តិភតោ ហោតិ, យោ មិត្តានំ ន ទុព្ភតិ ។

*បុគ្គលធ្វើសក្ការៈចំពោះមិត្រ រមែងត្រូវមិត្រធ្វើសក្ការៈតបវិញ ជាអ្នកគោរពមិត្រ រមែងទទួលបានសេចក្តីគោរពតបវិញ បុគ្គលមិនទ្រុស្តមិត្រ រមែងទទួលបានការសរសើរនិងកេរ្តិ៍ឈ្មោះល្បីរន្ទឺ ។*

៦- បូជកោ លភតេ បូជំ, វន្ទកោ បដិវន្ទនំ;
យសោកិត្តិញ្ច បប្បោតិ, យោ មិត្តានំ ន ទុព្ភតិ ។

បុគ្គលអ្នកបូជាមិត្រ រមែងទទួលបានការបូជាតបវិញ អ្នកសំពះមិត្រ រមែងទទួលបានការសំពះតបវិញ បុគ្គលមិនទ្រុស្តមិត្រ រមែងបានយសបរិវារនិងមានកេរ្តិ៍ឈ្មោះល្បីសុសសាយ ។

៧- អគ្គិ យថា បជ្ជលតិ, ទេវតាវ វិរោចតិ;
សិរិយា អជហិតោ ហោតិ, យោ មិត្តានំ ន ទុព្ភតិ ។

បុគ្គលណាមិនទ្រុស្តកល្យាណមិត្រទាំងឡាយ បុគ្គលនោះ រមែងរុងរឿងដូចពន្លឺភ្លើង រុងរឿងដូចរស្មីទេវតា ទៅណាមកណាតែងមានសិរីសួស្តី ។

៨- គាវោ តស្ស បជាយន្តិ, ខេត្តេ វុត្តំ វិរូហតិ;
វុត្តានំ ផលមស្នាតិ, យោ មិត្តានំ ន ទុព្ភតិ ។

បុគ្គលណាមិនទ្រុស្តកល្យាណមិត្រទាំងឡាយ មេគោទាំងឡាយរបស់បុគ្គលនោះ កើតកូនដោយស្រួល ស្រូវស្រែ ដំណាំចម្ការរបស់បុគ្គលនោះ រមែងលូតលាស់ដុះដាលបែកគុម្ពទទួលបានទិន្នផលល្អ សម្រាប់ម្ចាស់បរិភោគប្រើប្រាស់តាមតម្រូវការ ។

៩- ទរិតោ បព្វតាតោ វា, រុក្ខតោ បតិតោ នរោ;

ចុតោ បតិដ្ឋំ លភតិ, យោ មិត្តានំ ន ទុព្ភតិ ។

បុគ្គលណាមិនទ្រុស្តកល្យាណមិត្រទាំងឡាយ ទោះបីធ្លាក់អំពីភ្នំក្តី អំពីដើមឈើក្តី ឬក៏ធ្លាក់ចុះទៅក្នុងជ្រោះក្តី បុគ្គលនោះរមែងបាននូវទីពឹងណាមួយជួយស្រោចស្រង់មិនឲ្យស្លាប់ឡើយ ។

១០- វិរូឡ្ហមូលសន្តានំ, និគ្រោធមិវ មាលុតោ;
អមិត្តា នប្បសាហន្តិ, យោ មិត្តានំ ន ទុព្ភតិ ។

បុគ្គលមិនទ្រុស្តកល្យាណមិត្រទាំងឡាយ សត្រូវទាំងឡាយមិនអាចយកជ័យជម្នះលើបាន ប្រៀបដូចដើមជ្រៃមានឫសពួរយ៉ាងមាំ ខ្យល់មិនអាចបក់ផ្តួលរំលំបានដូច្នោះដែរ ។

ទោះបីព្រះបរមពោធិសត្វបានសម្តែងធម៌មានប្រមាណប៉ុណ្ណោះ ក៏នាយសុនន្ទសារថីចំណាំព្រះអង្គមិនបាន គាត់នៅតែឆ្ងល់ថា "បុរសនេះជានរណា" ។ ដូច្នេះហើយក៏ផ្អាកជីករណ្តៅ ដើរទៅជិតរទេះ រកមើលព្រះតេមិយនិងគ្រឿងប្រសាធន៍[៤៦] ក៏មិនឃើញនៅលើរទេះ រួចក៏ត្រឡប់មកវិញ ឈរជិតព្រះបរមពោធិសត្វ ពិនិត្យមើលទ្រង់ទ្រាយម្តង

[៤៦] គ្រឿងប្រដាប់តុបតែងលម្អកាយ, អលង្ការ ។

ទៀត ទើបស្គាល់ជាក់ជាព្រះតេមិយរាជបុត្រ ហើយក៏លុតជង្គង់ប្រណម្យអញ្ជលីក្រាបថ្វាយបង្គំព្រះបាទា អង្វរថា ៖

"បពិត្រព្រះរាជបុត្រ សូមស្ដេចយាងក្រាបទូល ទូលព្រះបង្គំជាខ្ញុំនឹងយាងព្រះអង្គត្រឡប់ទៅកាន់ព្រះនគរវិញ ហើយសូមព្រះអង្គសោយរាជ្យចុះ សេចក្ដីចម្រើននឹងមានដល់ព្រះអង្គ ការនៅក្នុងព្រៃនេះ មិនបានប្រយោជន៍អ្វីដល់ព្រះអង្គទេ ក្រាបទូល" ។

តេមិយទ្រង់តបថា ៖

"នែនាយសារថី ខ្ញុំមិនត្រូវការទ្រព្យ ញាតិ ឬរាជសម្បត្តិ ដែលជាហេតុនាំឲ្យប្រព្រឹត្តខុសចាកគន្លងធម៌ទេ" ។

សារថីក្រាបទូលអង្វរទៀតថា ៖

"បពិត្រព្រះរាជបុត្រ សូមទ្រង់ស្ដេចយាងចេញអំពីទីនេះទៅកាន់ព្រះនគរ កាលបើព្រះអង្គធ្វើដូច្នេះ ទូលព្រះបង្គំជាខ្ញុំនឹងបានរង្វាន់ជាទីគាប់ចិត្ត, បពិត្រព្រះរាជបុត្រ កាលបើព្រះអង្គស្ដេចយាងទៅកាន់នគរ ព្រះរាជបិតានិងព្រះរាជមាតានឹងប្រទានរង្វាន់ជាទីគាប់ចិត្តដល់ទូលព្រះបង្គំជាខ្ញុំ ។ បពិត្រព្រះរាជបុត្រ កាលទ្រង់ស្ដេចយាងទៅកាន់ព្រះនគរ ពួកស្រីស្នំនិងរាជកុមារ ពួកឈ្មួញនិងពួកព្រាហ្មណ៍ ជនទាំងអម្បាលនោះ មានចិត្តត្រេកអរ ពួកគេនឹងឲ្យ

រង្វាន់ដល់ទូលព្រះបង្គំជាខ្ញុំ ។ បពិត្រព្រះរាជបុត្រ កាលទ្រង់ស្ដេចយាងទៅកាន់ព្រះនគរ ពួកហ្មដំរី ពួកពលរក្សាព្រះអង្គ ពួកពលរថ ពួកពលថ្មើរជើង ជនទាំងអម្បាលនោះមានចិត្តត្រេកអរ ពួកគេនឹងឲ្យរង្វាន់ដល់ទូលព្រះបង្គំជាខ្ញុំ ។ បពិត្រព្រះរាជបុត្រ កាលទ្រង់ស្ដេចយាងទៅកាន់ព្រះនគរ ពួកអ្នកនិគមនិងពួកអ្នកជនបទមានធញ្ញាហារច្រើនមកប្រជុំគ្នា ពួកគេនឹងឲ្យគ្រឿងបណ្ណាការជាច្រើនដល់ទូលព្រះបង្គំជាខ្ញុំ" ។

តេមិយព្យាយាមបដិសេធថា ៖

"នៃនាយសារថី ខ្ញុំត្រូវព្រះមាតាបិតា អ្នកដែន អ្នកនិគម និងពួករាជកុមារបោះបង់ចោលហើយ ខ្ញុំមិនមានផ្ទះទេ ខ្ញុំត្រូវបានព្រះមាតាអនុញ្ញាតឲ្យសោយរាជ្យ ៧ ថ្ងៃហើយ ខ្ញុំត្រូវព្រះបិតាបោះបង់ចោលហើយ ខ្ញុំនឹងបួសនៅក្នុងព្រៃនេះតែម្នាក់ឯង មិនប្រាថ្នានូវកាមទាំងឡាយឡើយ" ។

ពេលដែលព្រះពោធិសត្វកំពុងពោលនូវគុណទាំងឡាយរបស់ខ្លួន បីតិសេចក្ដីឆ្អែតចិត្ត ក៏កើតឡើងដល់ព្រះអង្គ ដោយកម្លាំងនៃបីតិនោះ ព្រះអង្គបានបន្លឺនូវឧទាននេះថា ៖

"ខ្ញុំបានសម្រេចផលតាមសេចក្ដីប្រាថ្នាហើយ ព្រោះខ្ញុំមិនប្រញាប់ប្រញាល់ ហើយព្យាយាមតស៊ូអស់ពេល ១៦ ឆ្នាំ ខ្ញុំមានព្រហ្មចរិយធម៌ចាស់ក្លាហើយ នៃនាយសារថី អ្នកចូរដឹងយ៉ាងនេះចុះ ។ ប្រយោជន៍ដ៏ប្រពៃតែងសម្រេចដល់ខ្ញុំ ព្រោះខ្ញុំមិនប្រញាប់ប្រញាល់ ខ្ញុំមានព្រហ្មចរិយធម៌ចាស់ក្លាហើយ ខ្ញុំចេញផុតពីទុក្ខភ័យហើយ" ។

នាយសារថីទូលសួរថា ៖

"បពិត្រព្រះរាជបុត្រ ព្រះអង្គមានព្រះបន្ទូលពីរោះ មានព្រះបន្ទូលក្បោះក្បាយយ៉ាងនេះ ហេតុអ្វីបានជាព្រះអង្គមិនមានព្រះបន្ទូលក្នុងសម្នាក់នៃព្រះមាតាព្រះបិតារបស់ព្រះអង្គ ក្នុងពេលនោះ ?"

តេមិយទ្រង់តបថា ៖

"ម្នាលនាយសារថី ខ្ញុំមិនមែនខ្វិន ព្រោះខ្ញុំមិនមានសន្ទាក់ទេ ខ្ញុំមិនមែនថ្លង់ ព្រោះមិនមានសោតប្រាសាទទេ ខ្ញុំមិនមែនគ ព្រោះមិនមានជិវ្ហាប្រាសាទទេ អ្នកកុំយល់ច្រឡំថា ខ្ញុំជាមនុស្សគឲ្យសោះ ។ ខ្ញុំរឭកឃើញនូវជាតិមុន ដែលបានសោយរាជ្យក្នុងនគរពារាណសីនេះ លុះសោយរាជ្យក្នុងជាតិនោះបានតែ ២០ ឆ្នាំ ខ្ញុំក៏ស្លាប់ទៅកើតក្នុងនរក ត្រូវភ្លើងក្នុងនរកឆេះអស់ ៨០.០០០ ឆ្នាំ ។ ខ្ញុំខ្លាចរាជ្យនោះណាស់ ហេតុដែលខ្ញុំមិននិយាយក្នុងសម្នាក់នៃព្រះបិតា

មាតាក្នុងកាលនោះ គឺក្នុងគោលបំណងដើម្បីកុំឲ្យព្រះមាតាបិតាអភិសេកខ្ញុំក្នុងរាជ្យនោះ ។ ពេលមួយ ព្រះរាជបិតាបានឲ្យខ្ញុំអង្គុយលើព្រះឱរូ ហើយទ្រង់កាត់ទោសចោរ ៤ នាក់ថា ចោរ ១ ត្រូវវាយនឹងខ្សែលួសបន្លា ១ ពាន់ខ្ទាប់ ចោរ ១ ត្រូវដាក់គុក ចោរ ១ ត្រូវប្រឡាក់ទឹកក្បុង និងចោរម្នាក់ទៀត ត្រូវដោតនឹងឈើអណ្ដោត ។ ខ្ញុំគ្រាន់តែឮនូវព្រះបន្ទូលដ៏ព្រៃផ្សៃរបស់ព្រះបិតាភ្លាម ខ្ញុំមិនគទេ តែធ្វើជាគ ខ្ញុំមិនខ្វិនទេ តែធ្វើជាខ្វិន បើទោះបីខ្ញុំនៅត្រាំក្នុងមូត្រនិងលាមករបស់ខ្លួនក៏ដោយ ។ ជីវិតរបស់សត្វតែងមានសេចក្ដីលំបាកផង តិចតួចផង ជីវិតនោះប្រកបដោយទុក្ខផង ចុះហេតុដូចម្ដេច បុគ្គលអាស្រ័យជីវិតដ៏តិចតួចនេះហើយ ធ្វើនូវកម្មពៀរទៀត ? បុគ្គលដែលអាស្រ័យនូវជីវិតដ៏តិចតួចនេះហើយ ប្រព្រឹត្តធ្វើនូវកម្មពៀរទៅបាននោះ ព្រោះមិនមានវិបស្សនាបញ្ញាផង ព្រោះមិនឃើញច្បាស់នូវធម៌ផង ។ ខ្ញុំបានសម្រេចផលតាមសេចក្ដីប្រាថ្នាហើយ ព្រោះខ្ញុំមិនប្រញាប់ប្រញាល់ ហើយព្យាយាមតស៊ូអស់ពេល ១៦ ឆ្នាំ ខ្ញុំមានព្រហ្មចរិយធម៌ចាស់ក្លា[៤៧] ហើយ នៃនាយ

---

[៤៧] ធម៌ជាបែបបទ ឬជាសណ្ដាប់ធ្នាប់របស់អ្នកប្រព្រឹត្តធម៌, ធម៌ដ៏ប្រសើរដែលព្រហ្មចារី ឬព្រហ្មចារិនីគួរប្រព្រឹត្ត ។ ន័យម្យ៉ាងទៀតថា ការឱ្យទាន ១ ការខ្វល់ខ្វាយ ឬខ្នះខ្នែង

សារថី អ្នកចូរដឹងយ៉ាងនេះចុះ ។ ប្រយោជន៍ដ៏ប្រពៃតែងសម្រេច ដល់ខ្ញុំ ព្រោះខ្ញុំមិនប្រញាប់ប្រញាល់ ខ្ញុំមានព្រហ្មចរិយធម៌ចាស់ក្លាហើយ ខ្ញុំចេញផុតពីទុក្ខភ័យហើយ" ។

លុះឮដូច្នោះហើយ សុនន្ទសារថីក៏គិតថា ៖

"ព្រះតេមិយរាជបុត្រនេះ លះបង់ចោលនូវរាជសម្បត្តិដ៏មានសិរី ដូចចោលសាកសព ដោយមិនអាឡោះអាល័យ មិនទម្លាក់ចោលអធិដ្ឋាន គឺសេចក្ដីតាំងចិត្តរបស់ខ្លួនឡើយ ហើយចូលមកកាន់ព្រៃបំណងនឹងបួស, ជីវិតដ៏អាក្រក់នេះមិនមានប្រយោជន៍អ្វីដល់អញឡើយ អញនឹងសាងផ្នួសជាមួយនឹងព្រះតេមិយរាជបុត្រនេះដែរ" ។

គិតដូច្នេះហើយ នាយសារថីក៏ពោលថា ៖

---

ចំពោះអំពើជាកុសល ១ ការរក្សាសីលប្រាំ ១ ការចម្រើនព្រហ្មវិហារធម៌បួន ១ ការសម្ដែងធម៌ ឬណែនាំពន្យល់អ្នកដទៃឱ្យប្រព្រឹត្តអំពើសុចរិត ១ ការវៀរចាកមេថុនធម្ម ១ សេចក្ដីសន្ដោសចំពោះភរិយារបស់ខ្លួន ១ សេចក្ដីព្យាយាមដ៏ខ្ជាប់ខ្ជួនក្នុងការបំពេញកុសល ១ ការរក្សាឧបោសថតាមកាលកំណត់ ១ អរិយមគ្គ ១ ព្រះពុទ្ធសាសនាទាំងមូល ១ អជ្ឈាស្រ័យ ១ ទាំង ១២ យ៉ាងនេះ ក៏ហៅថា ព្រហ្មចរិយធម៌ ដែរ ។

"បពិត្រព្រះរាជបុត្រ ទូលព្រះបង្គំជាខ្ញុំនឹងបួសក្នុងសម្នាក់ព្រះអង្គ បពិត្រព្រះរាជបុត្រដ៏ចម្រើន សូមព្រះអង្គអនុញ្ញាតឲ្យទូលព្រះបង្គំជាខ្ញុំបួសផង ទូលព្រះបង្គំជាខ្ញុំពេញចិត្តនឹងបព្វជ្ជាដែរ" ។

ពេលដែលនាយសារថីទូលសុំបួសយ៉ាងនេះ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ៖

"ប្រសិនបើអញអនុញ្ញាតឲ្យនាយសារថីបួសឥឡូវនេះ ព្រះមាតាបិតារបស់អញប្រាកដជាទ្រង់ពុំបានយាងមកកាន់ទីនេះទេ ។ កាលបើដូច្នេះ សេចក្ដីសាបសូន្យនឹងមានដល់ពួកទ្រង់ ។ម្យ៉ាងទៀត សេះ រទេះ និងគ្រឿងប្រសាធន៍អស់ទាំងនេះ នឹងទៅជាអសារឥតការក្នុងទីនេះពុំខាន ហើយពួកអ្នកនគរអាចនឹងរិះគន់អញថាជាយក្សស៊ីនាយសារថីនោះទៀតផង" ។

កាលព្រះពោធិសត្វទ្រង់ព្រះតម្រិះឃើញនូវសេចក្ដីចម្រើនដល់ព្រះមាតាបិតាផង គិតឃើញនូវមធ្យោបាយ[៤៨]ដើម្បីដោះខ្លួនអំពីពាក្យរិះគន់របស់អ្នកនគរមកលើខ្លួនព្រះអង្គផង ទើបទ្រង់ត្រាស់បង្ហាញសេះ

---

[៤៨] ឧបាយកណ្ដាល, ដំណើរទំនងដ៏ល្មមសមគួរសម្រាប់ធ្វើកិច្ចការឱ្យបានសម្រេចតាមបំណង ។

រទេះ និងគ្រឿងប្រសាធន៍បង្វែរថាជាបំណុលរបស់នាយសារថីនោះ រួចត្រាស់ថា ៖

"នែនាយសារថី អ្នកចូរយកសេះ រទេះ និងគ្រឿងប្រសាធន៍ទាំងនេះទៅថ្វាយព្រះរាជាសិន ទើបអ្នករួចពីបំណុល ហើយត្រឡប់មកបួសវិញចុះ ព្រោះថា អ្នកជាប់បំណុលគេមិនអាចបួសបានទេ ឥសីទាំងឡាយតែងពោលសរសើរការបួសនេះណាស់" ។

ព្ទដូច្នោះ នាយសារថីគិតថា ៖

"ប្រសិនបើអញទៅកាន់នគរ ព្រះតេមិយនេះនឹងទៅក្នុងទីដទៃ, លុះព្រះបិតាព្រះអង្គជ្រាបដំណឹងនេះ ប្រាកដជាទ្រង់យាងមកសួររកបុត្ររបស់ព្រះអង្គ មិនឃើញ ទ្រង់នឹងដាក់ទោសអញ ព្រោះហេតុដូច្នោះ អញត្រូវពោលនូវគុណរបស់ខ្លួន រួចសូមឲ្យព្រះតេមិយដាក់ខសន្យាថា មិនត្រូវទៅកាន់ទីដទៃឡើយ" ។

លុះនាយសារថីគិតដូច្នេះហើយ ក៏ក្រាបទូលថា ៖

"សេចក្ដីចម្រើនចូរមានដល់ព្រះអង្គ ទូលព្រះបង្គំជាខ្ញុំនឹងធ្វើតាមពាក្យរបស់ព្រះអង្គ ពាក្យដែលទូលបង្គំជាខ្ញុំអង្វរសុំព្រះអង្គហើយសូមព្រះអង្គមេត្តាធ្វើតាមពាក្យរបស់ទូលព្រះបង្គំជាខ្ញុំផងចុះ ។ សូមព្រះអង្គមេត្តាស្ដេចគង់នៅក្នុងទីនេះ ដរាបដល់ទូលព្រះបង្គំ

ជាខ្ញុំយាងព្រះបិតាមកដល់ ពេលព្រះបិតាទតឃើញព្រះអង្គហើយ សមជាមានព្រះហឫទ័យនោះប្រកបដោយសេចក្តីត្រេកអររីករាយក្រៃពេក" ។

តេមិយទ្រង់តបថា ៖

"នៃនាយសារថី ខ្ញុំប្តេជ្ញាធ្វើតាមពាក្យរបស់អ្នក ខ្ញុំក៏មានបំណងចង់ជួបព្រះបិតារបស់ខ្ញុំ ដែលទ្រង់ស្តេចយាងមកក្នុងទីនេះដែរ ។ ម្នាលសម្លាញ់ អ្នកទៅដល់ហើយ ចូរប្រាប់នូវសេចក្តីសុខរបស់ខ្ញុំដល់ព្រះញាតិទាំងឡាយផង ចូរទូលថ្វាយព្រះមាតាបិតាថា ខ្ញុំជាបុត្រតែងក្រាបថ្វាយបង្គំចំពោះព្រះមាតាបិតាជានិច្ច ហើយចូរប្រញាប់ប្រញាល់ត្រឡប់មកវិញ" ។

បន្ទាប់ពីត្រាស់ដូច្នេះហើយ ព្រះមហាសត្តទ្រង់បែរព្រះកត្រ្តបង្អោនព្រះកាយ ដែលប្រៀបបាននឹងដើមចេកមាស តម្រង់ឆ្ពោះទៅរកនគរពារាណសី ថ្វាយបង្គំប្រកបដោយបញ្ចង្គប្រតិស្ឋ[៤៩] ចំពោះព្រះមាតា

[៤៩] ការថ្វាយបង្គំប្រកបដោយអង្គ ៥ គឺលុតជង្គង់ទាំង ២, ដាក់ដុំដៃទាំង ២ លើផ្ទៃរាប, ឱនក្បាលចុះដល់ផ្ទៃរាប រួមជា ៥ ហៅថា ថ្វាយបង្គំដោយបញ្ចង្គ ឬបញ្ចង្គប្រតិស្ឋ ។

បិតារួច ទ្រង់ថ្វាយដំណឹងតាមរយៈសារថី ។ សុនន្ទសារថីទទួលពាក្យផ្តាំផ្ញើហើយ ចាប់ព្រះបាទានៃព្រះមហាសត្វ ដើរប្រទក្សិណ[៥០] ព្រះអង្គរួចក៏ឡើងជិះរថបរឆ្ពោះមុខទៅព្រះនគរ ។

**នាយសារថីក្រាបទូលដំណឹងព្រះរាជបុត្រដល់ព្រះនាងចន្ទាទេវី**

ក្នុងខណៈនោះ ព្រះនាងចន្ទាទេវី កំពុងបើកសីហបញ្ជរ[៥១] ទន្ទឹងរង់ចាំមើលផ្លូវនាយសារថី ក្រែងបានដំណឹងល្អខ្លះពីបុត្ររបស់ព្រះនាង លុះឃើញនាយសារថីត្រឡប់មកវិញតែម្នាក់ឯង មិនឃើញព្រះរាជ-បុត្រលើរថ ព្រះនាងទ្រង់ព្រះកន្សែងសោយសោកវិយោគបោកព្រះកាយាអួលណែនឱរាខ្លោចផ្សាកាន់តែខ្លាំង មានព្រះភក្ត្រនោះដោក

---

[៥០] (ន.) ការសម្តែងសេចក្តីគោរពឬសេចក្តីស្រឡាញ់ដោយដើរពទ្ធជុំវិញបុគ្គលឬវត្ថុអ្វីៗ ដោយឱ្យបុគ្គលឬវត្ថុនោះៗ នៅខាងស្តាំដៃ ឧ. ធ្វើប្រទក្សិណព្រះវិហារ ៣ ជុំ ។ ប្រើជា កិ.វិ. ក៏បាន ឧ. ដើរប្រទក្សិណ ។

[៥១] បង្អួចរបស់លោកអ្នកមានអានុភាពដូចសត្វសីហៈ គឺបង្អួចដំណាក់ ឬប្រាសាទរបស់ក្សត្រិយ៍ទ្រង់រាជ្យ ឬបង្អួចមានរង្វង់ដូចជាទ្រង់ជំហរសីហៈ ឧ. ព្រះរាជាទ្រង់ប្រថាប់ក្បែរសីហបញ្ជរ ។

ជាំដោយទឹកនេត្រា[៥២] ទើបព្រះនាងទ្រង់ព្រះចិន្តាថា "បុត្ររបស់អញច្បាស់ជានាយសារថីនេះសម្លាប់ហើយ បុត្ររបស់អញដែលចម្រើនដល់ប្រទេសជាតិ ប្រាកដជានាយសារថីកប់ក្នុងផែនដីហើយ ។ ទាំងពួកសត្រូវ ទាំងពួកអ្នកចង់ពៀរ រមែងត្រេកអរដោយពិត ពេលឮថានាយសារថីបានសម្លាប់បុត្ររបស់អញ" ទើបព្រះនាងត្រាស់សួរទៅសារថីថា ៖

"បុត្ររបស់ខ្ញុំជាមនុស្សគ ជាមនុស្សខ្វិនពិតមែនឬ ? កាលអ្នកកប់បុត្ររបស់ខ្ញុំក្នុងផែនដី តើបុត្ររបស់ខ្ញុំពិលាបដែរឬទេ ? ម្នាលសារថី ចូរអ្នកប្រាប់ខ្ញុំ ។ បើបុត្ររបស់ខ្ញុំជាមនុស្សគ ជាមនុស្សខ្វិនពិតមែន ចុះកាលអ្នកកប់ក្នុងដី តើបុត្ររបស់ខ្ញុំបានកម្រើកដៃជើងខ្លះដែរឬទេ ? នែនាយសារថី ចូរអ្នកប្រាប់ខ្ញុំ" ។

គ្រានោះ សារថីគិតថា "ប្រសិនបើអញប្រាប់ថា បុត្ររបស់ព្រះនាងមិនមែនជាមនុស្សគ មិនមែនជាមនុស្សខ្វិន ទាំងមានព្រះវាចាដ៏

---

[៥២] ភ្នែកទាំងពីរ ឧ. ស្ដេចទតព្រះនេត្រា ឃើញធីតានៃសេដ្ឋី មានរូបឆោមពិសី ព្រះចក្រីប្រតិព័ទ្ធ។

ពីរោះ ដូច្នេះ ព្រះរាជាប្រាកដជាទ្រង់ព្រះពិរោធ[៥៣]ថា ហេតុដូចម្ដេច បានជាឯងមិនយាងបុត្ររបស់អញមកវិញ ហើយទ្រង់នឹងដាក់រាជ-អាជ្ញា[៥៤]ចំពោះអញ ដូច្នេះ អញត្រូវសុំការប្រទានអភ័យអំពីព្រះនាងទេពីជាមុនសិន" រួចក៏ក្រាបទូលថា ៖

"បពិត្រព្រះទេពី បើព្រះនាងប្រទានអភ័យដល់ទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំនឹងទូលថ្វាយព្រះនាងតាមដំណើរពិតរបស់ព្រះរាជបុត្រដែលទូលបង្គំជាខ្ញុំបានឮបានឃើញហើយ ក្រាបទូល" ។

ព្រះនាងទេពីយល់ព្រមនឹងសម្ដីរបស់នាយសារថីថា ៖

"ម្នាលសារថី ខ្ញុំអត់ទោសដល់អ្នក អ្នកចូរប្រាប់នូវហេតុដែលអ្នកបានឮ បានឃើញក្នុងសម្នាក់ព្រះរាជបុត្រមកចុះ កុំព្រួយបារម្ភឡើយ" ។

នាយសារថីក្រាបទូលថា ៖

"បពិត្រព្រះទេពី ព្រះរាជបុត្រ មិនមែនជាមនុស្សគបូខ្វិនទេ ព្រះរាជបុត្រនោះមានព្រះបន្ទូលពីរោះក្បោះក្បាយណាស់ ប៉ុន្តែ

---

[៥៣] កំហឹង, កំហុស, សេចក្ដីស្អប់, ដំណើរឈ្លោះទាស់ទែង, សត្រូវ ។ ខ្មែរច្រើននិយាយផ្សំនឹងពាក្យក្រោធ ឧ. ក្រោធពិរោធ គឺក្រោធខ្លាំង ។

[៥៤] អំណាច, ការបង្គាប់បញ្ជា, ការដាក់ទោស ។

ដោយហេតុតែព្រះអង្គខ្លាចរាជ្យ ទើបទ្រង់ធ្វើពុតជាខ្វិន គ ថ្លង់ យ៉ាងនេះ ។ ព្រះរាជបុត្របានមានព្រះបន្ទូលនឹងទូលព្រះបង្គំថា ព្រះអង្គរឭកឃើញនូវជាតិមុន ជាជាតិដែលទ្រង់បានសោយរាជ្យ (ក្នុងនគរពារាណសីនេះ) លុះសោយរាជ្យបានតែ ២០ ឆ្នាំ បន្ទាប់ពីសោយទិវង្គត បានទៅកើតក្នុងនរកសោយទុក្ខក្នុងទីនោះអស់ ៨០.០០០ ឆ្នាំ ។ ព្រះរាជបុត្រនោះ ទ្រង់ខ្លាចការឡើងគ្រងរាជ្យ ទើបតាំងព្រះរាជហឫទ័យដើម្បីកុំឲ្យព្រះរាជមាតាបិតាអភិសេកព្រះអង្គ ព្រោះហេតុនោះ បានជាព្រះរាជបុត្រមិនមានព្រះបន្ទូលក្នុងសម្នាក់ព្រះមាតាបិតាក្នុងកាលនោះ ។ តាមពិត ព្រះរាជបុត្រនោះ មានអវយវៈតូចធំបរិបូណ៌ពេញលេញ មានកម្ពស់និងទំហំសមសួន ទាំងមានព្រះបន្ទូលពីរោះក្បោះក្បាយ ប្រាជ្ញាឈ្លាសវៃ ឥឡូវនេះព្រះអង្គកំពុងឋិតនៅក្នុងផ្លូវជាទីទៅកាន់ស្ថានសួគ៌ ។ បើព្រះនាងទេពីមានបំណងជួបព្រះរាជបុត្ររបស់ព្រះនាង សូមស្ដេចយាងទៅជាមួយនឹងទូលព្រះបង្គំ ទូលព្រះបង្គំនឹងយាងព្រះនាងទៅជួបនឹងព្រះរាជបុត្រអង្គនោះ” ។

# ជំពូកទី៥

## មហាជនសាងផ្នួសតាមព្រះតេមិយ

### សក្កទេវរាជថ្វាយអាស្រមដល់ព្រះតេមិយ

បន្ទាប់ពីនាយសារថីចេញផុត ព្រះតេមិយពោធិសត្វ ទ្រង់មានព្រះបំណងនឹងសាងព្រះផ្នួស ។

រំពេចនោះ សក្កទេវរាជទ្រង់ជ្រាបនូវព្រះទ័យរបស់ព្រះតេមិយ ហើយទ្រង់ក៏ត្រាស់ប្រើទេវតាមួយអង្គឲ្យទៅហៅវិស្សុកម្មទេវបុត្រចូលគាល់ព្រះអង្គ ហើយត្រាស់បញ្ជាថា ៖

"នែវិស្សុកម្មទេវបុត្រ ឥឡូវនេះ ព្រះតេមិយពោធិសត្វប្រាថ្នាសាងព្រះផ្នួស អ្នកចូរទៅ ហើយប្រើឫទ្ធានុភាពនិម្មិតបណ្ណសាលា[៥៥] និងគ្រឿងបរិក្ខាររបស់បព្វជិតសម្រាប់ព្រះអង្គ រួចចូរត្រឡប់មកវិញចុះ" ។

---

[៥៥] ត្រូវអានថា ប័ន-ណៈសា ល៉ា ឬ ប៉ុន-- បា. ( ន. ) សាលាប្រក់ស្លឹក, រោងប្រក់ស្លឹក ឬតូប, ខ្ទមប្រក់ស្លឹក ។

វិស្សុកម្មទេវបុត្រទទួលព្រះរាជបញ្ជាព្រះឥន្ទហើយ បានចុះមកកាន់ឋានមនុស្សលោកយ៉ាងលឿន ប្រើកម្លាំងឫទ្ធិរបស់ខ្លួននិម្មិតអាស្រម[៥៦] គួរជាទីរីករាយក្នុងដងព្រៃដែលមានទំហំដី ៣ យោជន៍ និងនិម្មិតឲ្យមានរត្តិន្ទិវដ្ឋាន[៥៧] ស្រះបោក្ខរណី អណ្តូង ដើមឈើ ធ្វើឲ្យមានផ្កាផ្លែនិងទីសម្រាប់ដើរចង្ក្រម[៥៨]ប្រវែង ២៤ ហត្ថ នៅក្បែរបណ្ណសាលា ក្រាលគ្រាប់ខ្សាច់ពណ៌ផ្ទេក ៗ ជាទីគាប់ចិត្ត និងនិម្មិតគ្រឿងបរិក្ខារសម្រាប់អ្នកបួសសព្វគ្រប់ រួចធ្លាក់អក្សរជាប់នឹងជញ្ជាំងថា ៖

"ជនណាមួយដែលប្រាថ្នាសាងផ្នួស សូមយកគ្រឿងបរិក្ខារទាំងនេះប្រើប្រាស់ចុះ" ។

---

[៥៦] អានថា អា--ស្រំ សំ.; បា. ( ន. ) (អាគ្រម; អស្សម) កន្លែងនៅសម្រាប់ធ្វើចិត្តឱ្យស្ងប់រំងាប់, លំនៅសម្រាប់រំងាប់រាគាទិក្កិលេស គឺខ្ទមឬកុដិលំនៅរបស់តាបស, ឥសី, យោគី ។ អាស្រមបទ (--ស្រំ-ម៉ៈបត់; សំ. អាគ្រមបទ; បា. អស្សមបទ) ទីអាស្រម, ទីក្បែរឬជុំវិញអាស្រម : តាបសតែងបោសសម្អាតអាស្រមបទតាមពេលកំណត់ពុំដែលខាន ។

[៥៧] ទីសម្រាប់នៅក្នុងពេលយប់និងទីសម្រាប់នៅពេលថ្ងៃ ។

[៥៨] ដំណើរដើរទៅដើរមក, ដំណើរទៅមក ៗ គឺដំណើរទៅហើយដើរមកវិញយឺត ៗ ច្រើនបកច្រើនសា ។

មិនតែប៉ុណ្ណោះ វិស្សុកម្មទេវបុត្រប្រើឫទ្ធានុភាពបណ្តេញហ្វូងម្រឹគនិងបក្សីណាកាច ៗ និងមានសំឡេងមិនជាទីគាប់ចិត្ត ឲ្យចេញឆ្ងាយអំពីព្រៃម្តុំនោះ រួចស្រេចហើយ ទើបវិលទៅលំនៅអាត្មាវិញ ។

## ជីវិតសាងផ្នួសនៃព្រះតេមិយ

ក្នុងខណៈនោះ ព្រះមហាសត្វទតឃើញអាស្រមនោះហើយ ជ្រាបថា សមិទ្ធផលនេះជាអំណោយរបស់ស្តេចសក្កៈថ្វាយព្រះអង្គ ទ្រង់ក៏យាងចូលទៅកាន់បណ្ណសាលាផ្លាស់សម្លៀកបំពាក់គ្រហស្ថចេញ ទ្រង់ស្លៀកសំពត់សំបកឈើ[៥៩] មួយផ្ទាំង ដណ្តប់មួយផ្ទាំង ធៀងស្មាម្ខាងដោយស្បែកខ្លាឥតក្រចក ចងកេសាជាជដាមណ្ឌល[៦០] (ជាភេទអ្នកបួសរស់ក្នុងព្រៃ) ដាក់សម្រែកលើស្មា កាន់ឈើច្រត់ដើរចេញអំពីបណ្ណសាលាកាន់គ្រឿងសិរីសួស្តីរបស់បព្វជិត ដើរចង្ក្រមទៅមក ៗ បន្លឺឧទានថា "សុខអីម៉្លេះហ្ន៎ ! សុខអីម៉្លេះហ្ន៎ !" រួចចូលទៅក្នុងបណ្ណសាលាវិញ អង្គុយលើកម្រាលឧស ចម្រើនកម្មដ្ឋាន[៦១] បានសម្រេចអភិញ្ញា[៦២] ៥ និង

---

[៥៩] សំពត់ដែលធ្វើពីតិណជាតិពួកក្រចៅសម្រាប់ប្រើការជាប់បានយូរ ។

[៦០] របៀបបួងសក់របស់តាបសអ្នកបួសក្នុងព្រៃ ។

[៦១] ធម៌សម្រាប់ធ្វើចិត្តឱ្យស្ងប់ស្ងាត់ឃ្លាតចាកនីវរណធម៌ មាន ២ ប្រភេទ គឺ ប្រភេទ

សមាបត្តិ[៦៣] ៨ ។ លុះសាយណ្ហសម័យ ព្រះអង្គចេញពីបណ្ណសាលា រកបេះស្លឹកឈើនៅព្រៃក្បែរអាស្រម ស្ងោររំងាស់យកទឹកដែលគ្មានជាតិប្រៃ ជូរ ក្រអូប ក្នុងឆ្នាំងដែលសក្កទេវរាជនិម្មិតថ្វាយ ហើយឆាន់ទឹកនោះដែលមានរសដូចរសអមតៈ ទ្រង់រស់នៅចិញ្ចឹមជីវិតបែបនោះក្នុង

ទី១ សមថកម្មដ្ឋាន មាន ៤០ យ៉ាង ចាត់ជា ៧ ពួកគឺ កសិណ ១០, អសុភ ១០, អនុស្សតិ ១០ អប្បមញ្ញា ៤ អាហារប្បដិកូលសញ្ញា ១ ចតុធាតុវវត្ថាន ១ អរូបកម្មដ្ឋាន ៤ រួមជា ៤០។ ប្រភេទទី ២ វិបស្សនាកម្មដ្ឋាន ការពិចារណាឃើញច្បាស់តាមដំណើរនៃសង្ខារធម៌ មាន ១០ យ៉ាងគឺ ៖ សម្មសនញាណ ១  ឧទព្វយញាណ ១ភង្គញាណ ១ ភយញាណ ១  អាទីនវញាណ ១ និព្វិទាញាណ ១ មុញ្ចិតុកាម្យតាញាណ ១ បដិសង្ខាញាណ ១  សង្ខារុបេក្ខាញាណ ១ អនុលោមញាណ ១ ។ អ្នកសិក្សាគប្បីស្រាវជ្រាវសេចក្តីអធិប្បាយនៃគោលធម៌ទាំងនេះផងចុះ ដើម្បីបំពេញការចេះដឹងដែលមានលក្ខណៈជាប្រព័ន្ធ ។

[៦២] សេចក្តីដឹងវិសេសដែលកើតអំពីកម្លាំងនៃឈាន មាន **៦ យ៉ាងគឺ** (១) **ឥទ្ធិវិធា** ឬ **ឥទ្ធិវិធិ** ការសម្តែងឫទ្ធិផ្សេង ៗ បាន, (២) **ទិព្វសោត** ត្រចៀកទិព្វ, (៣) **ចេតោបរិយញ្ញាណ** ការដឹងចិត្តរបស់បុគ្គលដទៃបាន, (៤) **បុព្វេនិវាសានុស្សតិ** ការរឭកដឹងជាតិមុនបាន, (៥) **ទិព្វចក្ខុ** ភ្នែកទិព្វ, (៦) **អាសវក្ខយញ្ញាណ** ញាណធ្វើឱ្យអស់អាសវក្កិលេស ។ អភិញ្ញា ៥ ខាងដើម ជាលោកិយៈ, ១ ខាងចុងជាលោកុត្តរៈ មិនមែនកើតអំពីកម្លាំងនៃឈានទេ គឺកើតអំពីកម្លាំងនៃវិបស្សនា ។

[៦៣] រូបជ្ឈាន ៤ និងអរូបជ្ឈាន ៤ ។

ទីនោះ ដើម្បីអប់រំចម្រើនព្រហ្មវិហារធម៌[៦៤] ៤ ។

## ព្រះបាទកាសិរាជយាងទៅកាន់អាស្រមរបស់បុត្រ

ចំណែកព្រះបាទកាសិរាជ លុះទ្រង់ព្រះសណ្ដាប់ពាក្យរបស់សុនន្ទសារថីហើយ ព្រះអង្គឲ្យហៅលោកមហាសេនគុត្តចូលគាល់ ដើម្បីត្រៀមរៀបចំដំណើរចេញទៅ ដោយត្រាស់បង្គាប់ដូច្នេះ ៖

"នែសារថីទាំងឡាយ ចូរទឹមរទេះសេះ ចូរចងដង្កូន់[៦៥]នាដំរី ចូរផ្លុំស័ង្ខនិងទូងស្គរឲ្យលាន់ឮសំឡេងឡើង ស្គរមានមុខតែម្ខាង ក៏ត្រូវទូងដែរ ។ ស្គរដែលគេពាសល្អហើយ ចូរទូងបន្ទឺសំឡេងឡើង ស្គរមានសំឡេងពីរោះ ក៏ត្រូវដំឲ្យលាន់ឮសំឡេងឡើង ទាំងពួកអ្នកនិគម ចូរហែហាមអមដំណើរទៅជាមួយនឹងយើង យើងនឹងទៅឲ្យឱវាទដល់បុត្ររបស់យើង ។ ពួកស្រីស្នំនិងរាជកុមារ ពួកឈ្មួញនិងពួកព្រាហ្មណ៍ ចូរនាំគ្នាទឹមយានឲ្យឆាប់ ៗ យើងនឹងទៅឲ្យឱវាទដល់បុត្ររបស់យើង ។ ពួកហ្មដំរី ពួកពលសេះ ពួកពលរថ

---

[៦៤] ព្រហ្មវិហារធម៌ ៤ គឺ មេត្តា ការស្រឡាញ់ ការរាប់អាន ដោយការប្រាថ្នាចង់ឲ្យអ្នកដទៃបានសេចក្ដីសុខ ១, ករុណា ការអាណិតអាសូរ ១, មុទិតា ការទោរទន់ ១, ឧបេក្ខា ការស្ថិតនៅជាកណ្ដាល ៗ ។

[៦៥] ខ្សែផ្ដៅវេញទាំងមូលសម្រាប់ចងរឹតកូបប្ញរយាង, ញ៉ែងព័ទ្ធតាមទ្រូងដំរី ។

ពួកពលថ្មើរជើង ចូរនាំគ្នាទឹមយានឲ្យឆាប់ ៗ យើងនឹងទៅឲ្យ ឱវាទដល់បុត្ររបស់យើង ។ ទាំងអ្នកជនបទ ទាំងអ្នកនិគមមក ជួបជុំគ្នាហើយ ចូរទឹមនូវយានឲ្យឆាប់ ៗ យើងនឹងទៅឲ្យឱវាទ ដល់បុត្ររបស់យើង" ។

ឯពួកនាយសារថី បាននាំយកសេះសិន្ធព[៦៦] ទាំងឡាយជាពាហនៈមាន សន្ទុះដ៏លឿន ទឹមបរមកបញ្ឈប់ក្បែររាជទ្វារ ក្រាបបង្គំទូលថា ៖

"បពិត្រព្រះសម្មតិទេព ពួកទូលព្រះបង្គំជាខ្ញុំបាននាំគ្នាទឹមសេះ ត្រៀមរួចរាល់អស់ហើយ ក្រាបទូល" ។

បន្ទាប់អំពីព្រះសណ្ដាប់នូវពាក្យរបស់ពួកនាយសារថីហើយ ព្រះរាជា ត្រាស់បន្ទូថា ៖

"សេះធាត់ ៗ រត់មិនលឿន សេះស្គម ៗ ទ្រោមកម្លាំង" ។

ព្ទដូច្នោះភ្លាម សារថីទាំងឡាយក្រាបទូលថា ៖

"សេះស្គម ៗ និងសេះធាត់ ៗ ពួកទូលបង្គំមិនបានទឹមឡើយ ពួក ទូលបង្គំបានទឹមតែសេះស្វាវ ៗ សម្បុរល្អ សន្ទុះលឿន កម្លាំងខ្លាំង តែប៉ុណ្ណោះ ក្រាបទូល" ។

---

[៦៦] សេះដែលកើតឬមានពូជនាំមកពីដែនសិន្ធវៈ ។

គ្រានោះ ព្រះរាជាមុននឹងស្តេចយាងទៅកាន់សម្នាក់ព្រះរាជបុត្រ ទ្រង់បានកោះហៅវណ្ណៈ[៦៧] ៤ សេនា ១៨ និងពួកពលទាំងអស់ឲ្យមកជួបជុំគ្នា ។ ការប្រជុំនោះបានបន្ទាយពេលអស់ ៣ ថ្ងៃ ទ្រង់បង្គាប់ឲ្យយកស្បៀងល្មមគ្រប់គ្រាន់រួច លុះដល់ថ្ងៃទី ៤ ព្រះរាជាទ្រង់ប្រញាប់ប្រញាល់ឡើងគង់ប្រថាប់លើរាជរថដែលនាយសារថីទឹមហើយស្រេច ទ្រង់ត្រាស់ទៅនឹងស្រីស្នំទាំងឡាយថា ៖

"ស្នំទាំងឡាយ ចូរទៅតាមយើង ពួកនាងចូរប្រដាប់កាយដោយគ្រឿងអលង្ការមាស កាន់ផ្ចិត ម្កុដ ព្រះខាន់ ស្វេតច្ឆត្រ និងស្បែកជើង ឡើងជិះរថមក" ។

---

[៦៧] វណ្ណៈក្នុងទីនេះមានន័យថា ពូជពង្ស ។ តាមលទ្ធិព្រាហ្មណ៍ ចែកពូជរបស់មនុស្សជា ៤ ថ្នាក់គឺ ១- ព្រាហ្មណៈ "ដើមកំណើតដំបូងបំផុត កើតអំពីព្រះឱស្ឋរបស់ព្រហ្ម, ព្រហ្មតម្រូវឲ្យជាម្ចាស់សាសនា មានមុខការខាងបង្រៀនប្រៀនប្រដៅវេទមន្តវិជ្ជាការផ្សេង ៗ" ។ ២- ក្សត្រិយៈ ឬ ខត្តិយៈ "កើតអំពីព្រះពាហារបស់ព្រះព្រហ្ម មានមុខការខាងគ្រប់គ្រងប្រទេស" ។ ៣- វៃស្សៈ ឬ វេស្សៈ "កើតអំពីព្រះឧរុរបស់ព្រះព្រហ្ម មានមុខការខាងធ្វើកិច្ចការជាន់ខ្ពស់ចុះរងពីក្សត្រិយ៍មក ឬកិច្ចការធម្មតា" ។ ៤- សូទ្រៈ ឬ សុទ្ទៈ "កើតអំពីព្រះបាទរបស់ព្រះព្រហ្ម មានមុខការខាងស៊ីឈ្នួល ឬកិច្ចការថយថោកផ្សេង ៗ" ។

បន្ទាប់ពីនោះ ព្រះរាជាបានឲ្យនាយសារថីបររទេះនាំក្បួនពល សេនា ធ្វើដំណើរនាំមុខ ចេញអំពីព្រះនគរ លុះទៅដល់អាស្រមបទ របស់ព្រះតេមិយរាជបុត្រហើយ ទ្រង់មានព្រះទ័យត្រេកអរជាខ្លាំង បានធ្វើសេចក្តីស្និទ្ធស្នាលជាមួយនឹងបុត្ររបស់ព្រះអង្គ ។

## ព្រះតេមិយសំណេះសំណាលជាមួយនឹងព្រះបិតា

តេមិយតាបសបានទតឃើញព្រះបិតារុងរឿងដោយតេជះ មាន ពួកអាមាត្យកាន់ព្រះខាន់ហែហមអមដំណើរយាងមក ពេលទ្រង់មក ដល់ តេមិយតាបសសួរព្រះបិតាថា ៖

"បពិត្រព្រះបិតា ព្រះអង្គមានសេចក្តីសុខសប្បាយទេឬ? បពិត្រ ព្រះបិតា ព្រះអង្គមិនមានអាពាធទេឬ? រាជកញ្ញាទាំងអស់ជា ព្រះមាតារបស់ខ្ញុំព្រះអង្គមិនមានអាពាធទេឬ?"

ព្រះបិតាតបថា ៖

"នៃបុត្រ បិតាសុខសប្បាយទេ នៃបុត្រ បិតាមិនមានអាពាធទេ រាជកញ្ញាទាំងអស់ជាមាតារបស់បុត្រ ក៏មិនមានអាពាធដែរ" ។

តេមិយទូលសួរបន្តថា ៖

"បពិត្រព្រះបិតា ព្រះអង្គមិនសោយទឹកស្រវឹងទេឬ? ទឹកស្រវឹងមិនជាទីគាប់ព្រះទ័យរបស់ព្រះអង្គទេឬ? ចុះព្រះទ័យរបស់ព្រះអង្គ ត្រេកអរក្នុងសច្ចធម៌និងក្នុងការឲ្យទានដែរឬទេ?"

ព្រះបិតាតប ៖

"នែបុត្រ បិតាមិនផឹកទឹកស្រវឹងទេ ម៉្យាងទៀត ទឹកស្រវឹងមិនជាទីគាប់ព្រះទ័យបិតាទេ ព្រះទ័យរបស់បិតា តែងត្រេកអរក្នុងសច្ចធម៌និងក្នុងការឲ្យទាន" ។

តេមិយទូលសួរបន្ត ៖

"យានរបស់ព្រះអង្គមិនខូចទេឬ? ពាហនៈទាំងឡាយរបស់ព្រះអង្គ តែងប្រព្រឹត្តទៅបានស្រួលដែរឬ? តើព្រះអង្គមិនមានរោគាពាធទេឬ?"

ព្រះបិតាតប ៖

"នែបុត្រ យានរបស់បិតាមិនខូចទេ ពាហនៈទាំងឡាយរបស់បិតាក៏ប្រព្រឹត្តទៅបានដោយស្រួលដែរ បិតាមិនមានអាពាធទេ" ។

តេមិយទូលសួរបន្ត ៖

"បពិត្រព្រះបិតា តាមទីជនបទដែលស្ថិតនៅជាយដែនរបស់ព្រះអង្គមានគ្រឿងបរិភោគ គ្រឿងស្លៀកពាក់ និងអាករណៈបរិបូរគ្រប់

គ្រាន់ដែរឬ ? ស្រុកនិងនិគមទាំងមូលរបស់ព្រះអង្គ ដែលតាំងនៅក្នុងដែនដី សម្បូណ៌សប្បាយដែរឬ ? ឃ្លាំងនិងជង្រុករបស់ព្រះអង្គបានតម្កល់ស្បៀងនិងស្រូវអង្ករទុកគ្រប់គ្រាន់ដែរឬ ?"

ព្រះបិតាតប ៖

"នែបុត្រ តាមទីជនបទនៅជាយដែននៃប្រទេសរបស់បិតា មានគ្រឿងឧបភោគនិងបរិភោគ គ្រឿងស្លៀកពាក់និងអាភរណៈបរិបូរគ្រប់គ្រាន់ទេ ស្រុកនិងនិគមទាំងមូលរបស់បិតា ដែលតាំងនៅក្នុងដែនដី សម្បូណ៌សប្បាយទេ ឃ្លាំងនិងជង្រុក បិតាបានតម្កល់ស្បៀងនិងស្រូវអង្ករទុកគ្រប់គ្រាន់ហើយ" ។

តេមិយពោលសរសើរចំពោះការយាងមករបស់បិតាថា ៖

"បពិត្រមហារាជ ព្រះអង្គស្ដេចយាងមកល្អហើយ ព្រះអង្គស្ដេចយាងមកនេះ ជាលាភដ៏ក្រៃលែង ។ រាជបុរសទាំងឡាយ សូមអ្នករៀបចំរាជបល្ល័ង្កថ្វាយព្រះបិតាយើង" ។

ព្រះរាជាមិនហ៊ានប្រថាប់គង់លើបល្ល័ង្កទេ ព្រោះគោរពចំពោះពោធិសត្វ ។

គ្រានោះ ព្រះពោធិសត្វប្រាប់អាមាត្យថា "ប្រសិនបើព្រះរាជាមិនប្រថាប់គង់លើបល្ល័ង្កទេ, ពួកលោកចូរក្រាលស្លឹកឈើ" រួចយាងព្រះរាជាឲ្យគង់លើកម្រាលស្លឹកឈើនោះ ដោយពោលថា ៖

"សូមព្រះអង្គគង់លើកម្រាលស្លឹកឈើដែលគេក្រាលថ្វាយ សូមព្រះអង្គយកទឹកអំពីទីនេះលាងព្រះបាទារបស់ព្រះអង្គចុះ" ។

ព្រះរាជានៅតែមិនគង់លើកម្រាលស្លឹកឈើដដែល ព្រះអង្គបែរជាគង់នៅលើផែនដីដែលគ្មានកម្រាលទៅវិញ ព្រោះសេចក្ដីគោរពចំពោះព្រះតេមិយតាបស ។

គ្រានោះ ព្រះពោធិសត្វចូលទៅខាងក្នុងបណ្ណសាលា ហើយយកនូវបន្លែដែលទ្រង់ស្ងោរនោះ មកថ្វាយព្រះរាជាទ្រង់សោយដោយពោលថា ៖

"បពិត្រព្រះរាជា ស្លឹកឈើដែលអាត្មាភាពស្ងោរហើយនេះ ជារបស់មិនមានរសប្រៃ បពិត្រមហារាជ សូមព្រះអង្គស្ដេចសោយចុះ ព្រោះព្រះអង្គទើបស្ដេចយាងមកដល់ ទុកជាជាភ្ញៀវរបស់អាត្មាភាព" ។

ព្រះបិតាបដិសេធ ៖

“បិតាមិនសោយស្ទឹកឈើនេះទេបុត្រ ! ព្រោះស្ទឹកឈើនេះមិនមែនជាភោជនដែលបិតាគួរសោយឡើយ  បិតាសោយតែបាយដែលគេចម្អិនអំពីស្រូវសាលីជាមួយនឹងម្ហូបដែលមានសាច់ឆ្ងាញ់ ៗ តែប៉ុណ្ណោះ” ។

## ព្រះនាងចន្ទាទេវីសន្លប់បាត់ស្មារតី

ព្រះរាជាពោលសរសើរភោជនជាក្រយាស្ងោយរបស់ព្រះអង្គ តែដោយទ្រង់គោរពចំពោះព្រះពោធិសត្វ ទើបចាប់យកបន្លែស្ងោរបន្តិចដាក់លើបាតព្រះហស្ត រួចមានព្រះបន្ទូលថា ៖

“នែបុត្រ អ្នកតែងតែឆាន់នូវភោជនបែបនេះឬ ?”  ហើយទ្រង់គង់ប្រថាប់សំណេះសំណាលជាមួយនឹងរាជបុត្រដោយពាក្យជាទីរីករាយ ។

ក្នុងមនោះ ព្រះនាងចន្ទាទេវី ក៏បានយាងមកដល់អាស្រមរបស់ព្រះពោធិសត្វ ដែលមានស្រីស្នំហែហមជាបរិវារដ៏ច្រើន គ្រាន់តែទ្រង់បានឃើញព្រះរាជបុត្រជាទីស្រឡាញ់ភ្លាម ព្រះនាងក៏ដួលសន្លប់បាត់ស្មារតីនៅទីនោះមួយរំពេច ។ បន្តិចក្រោយមក ព្រះនាងភ្ញាក់ស្មារតីដឹងព្រះកាយឡើងវិញ មានព្រះទ័យធូរស្បើយអំពីទុក្ខកង្វល់ខ្លះហើយ ព្រះនាងក៏ស្ទុះមកចាប់ព្រះបាទារបស់ព្រះរាជបុត្រយ៉ាងមាំ ទ្រង់ថ្វាយ

បង្គំបណ្តើរ កន្សែងសោយសោកហូរទឹកនេត្រាបណ្តើរ លុះថ្វាយបង្គំរួច ក៏យាងទៅប្រថាប់គង់ក្នុងទីដ៏សមគួរ ។

គ្រានោះ ព្រះរាជាមានព្រះរាជឱង្ការនឹងព្រះរាជអគ្គមហេសីថា ៖ "មហេសីអូន ចូរអូនមើលភោជនជាក្រយាស្ងោយរបស់បុត្រយើងចុះ" ហើយទ្រង់ឈោងចាប់បន្ទៃនោះបន្តិច ហុចទៅឲ្យព្រះអគ្គ-មហេសី រួចទ្រង់ចាប់ហុចបន្តឲ្យទៅឲ្យស្ត្រីផ្សេង ៗ ទៀតម្នាក់បន្តិច ៗ គ្រប់គ្នា ។

ស្ត្រីទាំងនោះលាន់មាត់ថា ៖

"ឱ ! ព្រះរាជបុត្រ ព្រះអង្គសោយភោជនបែបហ្នឹងហ្ន៎" រួចក៏យកបន្ទៃនោះដាក់លើក្បាលរៀង ៗខ្លួន អង្គុយថ្វាយបង្គំទាំងពោលថា "ព្រះរាជបុត្រកំពុងធ្វើនូវអំពើដែលអ្នកដទៃកម្រនឹងធ្វើបានណាស់ !" ។

ព្រះរាជាមានព្រះរាជឱង្ការជាថ្មីថា ៖

"នែបុត្រ ទង្វើនេះ ពិតជាអស្ចារ្យណាស់ចំពោះបិតា កាលបុត្របរិភោគភោជនបែបនេះ តើហេតុដូចម្តេចបានជាសម្បុរស្បែករបស់បុត្រនៅតែភ្លឺថ្លាយ៉ាងនេះ ? សេចក្តីអស្ចារ្យកើតមានប្រាកដដល់បិតា ព្រោះឃើញបុត្រនៅស្ងាត់តែម្នាក់ឯង" ។

គ្រានោះ ព្រះតេមិយពោធិសត្វទូលថ្វាយព្រះរាជបិតាថា ៖

"បពិត្រព្រះបិតា អាត្មាភាពសឹងលើកម្រាលស្លឹកឈើតែម្នាក់ឯង សម្បុរស្បែករបស់អាត្មាភាពក៏ស្រស់ថ្លា ដោយដំណេកតែម្នាក់ឯងហ្នឹង ។ អាត្មាភាពគ្មានអ្នកការពារដូចព្រះរាជាទេ ព្រោះក្នុងចិត្តអាត្មាភាពគ្មានសត្រូវ អាត្មារស់នៅប្រកបដោយសេចក្ដីសុខ ។ បពិត្រព្រះរាជា សម្បុរស្បែករបស់អាត្មាភាពក៏ថ្លាស្រស់បស់ ដោយដំណេកតែម្នាក់ឯងនោះ ព្រោះអាត្មាភាពមិននឹកអាឡោះអាល័យស្ដាយអារម្មណ៍ដែលកន្លងទៅហើយ មិនប្រាថ្នានូវអារម្មណ៍ដែលមិនទាន់មកដល់ ញុាំងចិត្តឲ្យព្រមលម្មតែនឹងរបស់ដែលកំពុងមាន ។ ហេតុនោះ បានជាសម្បុរស្បែករបស់អាត្មាភាពក៏ថ្លាស្រស់បស់ ។ ជនពាលទាំងឡាយតែងមានសម្បុរស្បែកស្ងួតស្រអាប់ ព្រោះប្រាថ្នាចង់បានរបស់ដែលមិនទាន់មកដល់ ដោយសារតែនឹកស្ដាយអាឡោះអាល័យរបស់ដែលកន្លងផុតហើយ ប្រៀបដូចជាដើមបបុសខ្ចី ពេលគេដកហាលថ្ងៃ រមែងស្វិតស្ងួតស្រអាប់ដូច្នោះដែរ" ។

## ព្រះតេមិយតាបសសម្ដែងធម្មកថាបដិសេធរាជសម្បត្តិ

គ្រានោះ ព្រះរាជាទ្រង់មានព្រះតម្រិះថា "អញនឹងអភិសេកតេមិយបុត្ររបស់អញឲ្យគ្រងរាជ្យក្នុងទីនេះ ហើយសឹមយាងរាជបុត្រទៅកាន់នគរ" រួចព្រះអង្គមានព្រះបន្ទូលស្នើសុំព្រះតេមិយរាជបុត្រឲ្យគ្រងរាជ្យដូច្នេះ ៖

"នែបុត្រ បិតានឹងប្រទាននូវពលដំរី ពលរថ ពលសេះពលថ្មើរជើង ពួកជនពាក់គ្រឿងក្រោះ និងរាជនិវេសន៍ទាំងឡាយ ជាទីគាប់ព្រះទ័យដល់បុត្រ ។ លើសពីនេះទៀតបិតានឹងប្រទានស្រីស្នំដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងដល់បុត្រ ។ នែបុត្រ ចូរបុត្រគ្រប់គ្រងនូវស្ត្រីទាំងនោះចុះ ព្រោះបុត្រជាព្រះរាជារបស់យើង ។ ស្ត្រីរបាំទាំងឡាយ ជាអ្នកឈ្លាសប្រសប់ក្នុងការរាំនិងច្រៀង បានសិក្សាក្នុងកិច្ចកលស្ត្រីស្ទាត់ល្អហើយ នឹងធ្វើឲ្យបុត្រត្រេកអររីករាយក្នុងកាម តើបុត្រនឹងនៅក្នុងព្រៃធ្វើអ្វី ? បិតានឹងនាំយករាជកញ្ញាទាំងឡាយដែលប្រដាប់តាក់តែងល្អហើយអំពីពួកព្រះរាជាដទៃមកឲ្យបុត្រ ពេលដែលរាជបុត្របង្កើតបុត្របានច្រើនជាមួយនឹងស្ត្រីទាំងនោះហើយ សឹមបួសជាខាងក្រោយចុះ ។

បុត្រនៅក្មេងកំលោះស្ថិតក្នុងបឋមវ័យ មានសក់ខ្មៅរលើបរលោង ចូរសោយរាជ្យចុះ សេចក្ដីចម្រើននឹងកើតមានដល់បុត្រ ដាក់ជាពុំខាន តើបុត្រនៅក្នុងព្រៃធ្វើអ្វី ?"

ព្រះតេមិយពោធិសត្វបានសម្ដែងធម្មកថាបដិសេធការឡើងគ្រងរាជ្យថា ៖

"បុគ្គលស្ថិតនៅក្នុងភាពជាយុវវ័យ គប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ គួរតែជាយុវវ័យ ព្រោះថា បព្វជ្ជារបស់បុគ្គលនៅជាយុវវ័យនេះ ពួកឥសីទាំងឡាយតែងសរសើរ ។ បុគ្គលស្ថិតនៅក្នុងភាពជាយុវវ័យ គប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ គួរតែជាយុវវ័យ អាត្មាភាពនឹងប្រព្រឹត្តព្រហ្មចរិយធម៌ អាត្មាភាពមិនត្រូវការរាជសម្បត្តិទេ ។ បពិត្រព្រះមាតានិងបិតា អាត្មាភាពឃើញនរជននៅក្មេងទើបនឹងចេះនិយាយ គួរឲ្យស្រឡាញ់ ដែលម្ដាយឪពុកបានមកដោយលំបាក កូននោះក៏ស្លាប់ទៅទាំងមិនទាន់ដល់វ័យចាស់ជរានៅឡើយ ។ អាត្មាភាពឃើញនាងកុមារីមានសម្បុរល្អដូចមាស ត្រូវមច្ចុរាជផ្ដាច់បង់ជីវិតនាងឲ្យក្ស័យទាំងនៅវ័យក្មេង ប្រៀបដូចជាទំពាំងខ្ចីត្រូវគេច្រត់ផ្ដាច់ ។ ដូច្នេះ នរជននិងនាងនារីទាំងឡាយក៏អាចនឹងស្លាប់ទាំងនៅវ័យក្មេងដែរ តើសត្វណាគប្បីទុកចិត្តក្នុង

ជីវិតនោះថា អាត្មាអញនៅក្មេងមិនស្លាប់នោះ ? រាប់តាំងពីបដិសន្ធិ ក្នុងផ្ទៃម្តាយមក យប់ថ្ងៃចេះតែកន្លងទៅ អាយុរបស់សត្វទាំងឡាយ កាន់តែនៅតិចទៅ ៗ ភាពក្មេងក្នុងវ័យនោះ នឹងធ្វើអ្វីកើត ? ដូច ត្រីទាំងឡាយនៅក្នុងថ្លុកមានទឹកតិច ដូច្នោះ ។ សត្វលោកត្រូវ សត្រូវបៀតបៀនជានិច្ចផង ត្រូវសត្រូវរួបរឹតជានិច្ចផង កាលបើ យប់និងថ្ងៃមិនកន្លងទៅទទេ ៗ យ៉ាងនេះ តើព្រះអង្គនឹងអភិសេក អាត្មាភាពឲ្យឡើងសោយរាជ្យធ្វើអ្វី ?"

ស្តេចកាសិរាជត្រាស់សួរថា ៖

"សត្វលោកនេះត្រូវសត្រូវអ្វីបៀតបៀន និងត្រូវសត្រូវអ្វីរួបរឹត ? ធម្មជាតិដូចម្តេចមិនកន្លងទៅទទេ ៗ ចូរបុត្រប្រាប់សេចក្តីនោះ ដល់បិតាមក" ។

ពោធិសត្វតបថា ៖

"សត្វលោកត្រូវមច្ចុបៀតបៀន និងត្រូវជរារួបរឹត រាត្រីទាំងឡាយ រមែងកន្លងទៅមិនទទេទេ គឺស្រូបយកអាយុរបស់សត្វលោកទៅ ជាមួយគ្រប់ពេល, បពិត្រក្សត្រិយ៍ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ ។ ដាងតម្បាញត្បាញសំពត់ដោយសូត្រ កាលត្បាញសំពត់បានវែង សូត្រដែលត្រូវត្បាញបន្តទៀត នៅសល់តិច យ៉ាងណាមិញ ជីវិត

របស់សត្វទាំងឡាយដែលយប់និងថ្ងៃកន្លងអស់ច្រើនហើយ រមែង
នៅសល់តិច ក៏យ៉ាងនោះដែរ ។ ទឹកដែលហូរទៅហើយ រមែង
មិនត្រឡប់ក្រោយវិញ យ៉ាងណាមិញ អាយុរបស់សត្វទាំងឡាយ
កាលកន្លងទៅហើយ រមែងមិនត្រឡប់ក្រោយវិញ ក៏យ៉ាងនោះ
ដែរ ។ កម្លាំងទឹកហូរកួចដ៏ខ្លាំង តែងកួចបន្សាត់នូវដើមឈើទាំង
ឡាយដែលដុះក្បែរច្រាំងទៅជាមួយផង យ៉ាងណាមិញ ជរានិង
មរណៈ ក៏តែងនាំយកទៅនូវអាយុជីវិតរបស់សត្វទាំងអស់ទៅ
ជាមួយ ក៏យ៉ាងនោះដែរ" ។

ព្រះមហាក្សត្រ ទ្រង់ព្រះសណ្ដាប់នូវធម្មកថា[៦៨]របស់ព្រះតេមិយ
ពោធិសត្វហើយ មានព្រះតម្រិះថា ៖

"ការនៅគ្រប់គ្រងរាជសម្បត្តិ គ្មានប្រយោជន៍អ្វីដល់អញទេ" ។
ព្រះអង្គព្រះតម្រិះដូច្នេះហើយ ទ្រង់បែរជាមានព្រះទ័យធុញថប់យ៉ាង
ខ្លាំងក្នុងការគ្រប់គ្រងរាជសម្បត្តិ ទ្រង់មានរាជបំណងសាងព្រះផ្នួសថា ៖

"អញមិនវិលត្រឡប់ទៅព្រះនគរវិញទេ, អញនឹងបួសនៅទីនេះ
ឲ្យខាងតែបាន, តែបើបុត្ររបស់អញត្រឡប់ទៅព្រះនគរវិញ អញ
នឹងថ្វាយស្វេតច្ឆត្រដល់បុត្រឲ្យឡើងសោយរាជ្យ" ។

[៦៨] ការពោលពាក្យប្រកបដោយធម៌, ការលើកយកធម៌មកសម្ដែង ។

បន្ទាប់មក ទ្រង់ទទូចសុំយាងរាជបុត្រឲ្យសោយរាជ្យម្តងទៀតថា ៖

"នែបុត្រ បិតានឹងឲ្យនូវពលដំរី ពលរថ ពលសេះ ពលថ្មើរជើង កងទ័ពពាក់គ្រឿងក្រោះនិងរាជនិវេសន៍[៦៩] ទាំងឡាយជាទីត្រេកអរដល់បុត្រ ។ មួយទៀត បិតាឲ្យនូវស្រីស្នំដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងដល់បុត្រ ។ នែបុត្រ ចូរបុត្រគ្រប់គ្រងនូវស្ត្រីទាំងនោះចុះ បុត្រជាព្រះរាជារបស់យើង ។ ស្ត្រីរបាំជាអ្នកឈ្លាសវៃក្នុងការរាំនិងច្រៀង បានសិក្សាក្នុងកិច្ចកលស្ត្រី នឹងធ្វើឲ្យបុត្រត្រេកអររីករាយក្នុងកាម បុត្រនឹងនៅក្នុងព្រៃធ្វើអ្វី ? បិតានឹងនាំយករាជកញ្ញាដែលប្រដាប់តុបតែងល្អហើយ អំពីពួកស្តេចដទៃមកឲ្យបុត្រ ពេលដែលបុត្របង្កើតកូនបានច្រើនជាមួយនឹងស្ត្រីទាំងនោះហើយ សឹមបួសក្នុងពេលក្រោយចុះ ។ បុត្រនៅក្មេងកំលោះស្ថិតក្នុងបឋមវ័យមានសក់ខ្មៅរលើបរលោង ចូរសោយរាជ្យ សេចក្តីចម្រើននឹងមានដល់បុត្រ បុត្របួសរស់នៅក្នុងព្រៃធ្វើអ្វី ? នែបុត្រ បិតានឹងឲ្យឃ្វាំងជង្រុក ពាហនៈ[៧០] ពលនិងព្រះរាជ

---

[៦៩] លំនៅរបស់ព្រះរាជា, ព្រះរាជមន្ទីរ ឬព្រះរាជវាំង ។

[៧០] គ្រឿងដឹកនាំ, យាន, ជំនិះ, យានជំនិះ ។ គ្រឿងប្រើប្រាស់ជិះ, សម្រាប់ផ្ទុកដឹកនាំដូចជា រថ រទេះ ទូក ជាដើម ហៅថា យាន, យានពាហនៈ ឬយានវាហនៈ ។ សត្វ

និវេសន៍ទាំងឡាយ ជាទីត្រេកអរដល់បុត្រ ។ ពួករាជកញ្ញាមានរូបឆោមស្រស់និងពួកស្ត្រីជាខ្ញុំបម្រើនឹងហែហមចោមរោមបុត្រ ចូរបុត្រសោយរាជ្យចុះ សេចក្តីចម្រើននឹងមានដល់បុត្រ តើការបួសរស់នៅក្នុងព្រៃមានប្រយោជន៍អ្វីដល់បុត្រ ?"

គ្រានោះ ព្រះពោធិសត្វមានព្រះទ័យមិនត្រូវការរាជសម្បត្តិ ទើបទ្រង់ប្រកាសសម្តែងថា ៖

"បពិត្រព្រះបិតា ទ្រព្យសម្បត្តិមានប្រយោជន៍អ្វីដល់អាត្មាភាព ព្រោះទ្រព្យតែងអស់ទៅ ភរិយាមានប្រយោជន៍អ្វី ព្រោះភរិយាក៏គង់ស្លាប់ វ័យដែលត្រូវជរាគ្របសង្កត់ មានប្រយោជន៍អ្វីដល់អាត្មាភាព ។ ក្នុងលោកសន្និវាសនេះ សេចក្តីត្រេកអរ ការលេងសើច ការរីករាយ និងការស្វែងរកទ្រព្យ មានប្រយោជន៍អ្វីដល់អាត្មាភាព អាត្មាភាពត្រូវការប្រពន្ធនិងកូនមកធ្វើអ្វី បពិត្រព្រះរាជា អាត្មាភាពផុតស្រឡះចាកចំណងហើយ ។ អាត្មាភាពដឹងច្បាស់យ៉ាងនេះថា មច្ចុគឺសេចក្តីស្លាប់តែងតាមយាយីរូបយើង ជាប់ជានិច្ច អាត្មាភាពត្រូវសេចក្តីស្លាប់គំរាមយ៉ាងនេះ តើឲ្យអាត្មាភាព

---

បម្រើសម្រាប់ជិះ, ទឹម ដូចជា សេះ ដំរី គោ ក្របី ជាដើម ហៅថា សត្វពាហនៈ, សត្វវាហនៈ ឬពាហនសត្វ, វាហនសត្វ ។

មានសេចក្ដីត្រេកអរនឹងការស្វែងរកទ្រព្យដូចម្ដេចទៅ ? ផ្លែឈើទុំទាំងឡាយ តែងមានភ័យអំពីការជ្រុះជានិច្ច យ៉ាងណាមិញ សត្វទាំងឡាយកើតមកហើយតែងមានភ័យអំពីសេចក្ដីស្លាប់ជានិច្ច យ៉ាងនោះដែរ ។ ជនជាច្រើន ពួកខ្លះដែលគេឃើញក្នុងវេលាព្រឹក តែគេមិនឃើញក្នុងវេលាល្ងាច ជនជាច្រើន ពួកខ្លះដែលគេឃើញក្នុងវេលាល្ងាច តែគេមិនឃើញក្នុងវេលាព្រឹក ។ សេចក្ដីព្យាយាមក្នុងការបំពេញកុសលគឺគេត្រូវធ្វើក្នុងថ្ងៃនេះឯង បុគ្គលណានឹងដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែក ព្រោះថាយើងមិនអាចនិយាយបណ្ដោះបណ្ដោ[៧១] ជាមួយនឹងសេចក្ដីស្លាប់ដែលមានសេនាច្រើននោះបានទេ ។ ពួកចោរទាំងឡាយស៊ូលះបង់ជីវិតព្រោះប្រាថ្នានូវទ្រព្យ បពិត្រព្រះបិតា អាត្មាភាពផុតស្រឡះហើយអំពីចំណង ពោលគឺសេចក្ដីប្រាថ្នានូវទ្រព្យ ។ បពិត្រព្រះបិតា សូមព្រះអង្គលះបង់រាជសម្បត្តិសាងព្រះផ្នួសចុះ សូមព្រះអង្គកុំបង្ខំអាត្មាភាពឲ្យឡើងសោយរាជ្យឡើយ អាត្មាភាពមិនត្រូវការរាជសម្បត្តិនោះទេ" ។

---

[៧១] ពោលពាក្យដោះដៃ បង្អែងបង្អែរវេលា ឧ. បណ្ដោះបណ្ដោថា ថ្ងៃនេះជាថ្ងៃនោះ ស្អែកជាខានស្អែក ។

**មហាជនសាទផ្កស**

បន្ទាប់ពីបានស្តាប់នូវពាក្យដ៏ពីរោះរបស់ព្រះពោធិសត្វហើយ ពួកស្រីស្នំ ១៦.០០០ នាក់ និងអស់លោកនាហ្មឺនសព្វមុខមន្ត្រី ដែលមានព្រះបាទកាសិរាជនិងព្រះនាងចន្ទាទេវីជាប្រធាន ទ្រង់សព្វព្រះទ័យ និងមានបំណងចេញសាងផ្នួសគ្រប់ ៗ គ្នា ។ ព្រះរាជាទ្រង់ចេញព្រះរាជបញ្ជាឲ្យដើរទូងស្គរប្រកាសដំណឹងថា ៖

"ជនទាំងឡាយណាប្រាថ្នាសាងផ្នួសក្នុងសម្នាក់បុត្ររបស់យើង ចូរសាងផ្នួសចុះ" ។

បន្ទាប់មកស្តេចទ្រង់ចេញរាជប្រកាសឲ្យបើកឃ្លាំងមាសទាំងឡាយទូទាំងនគរ និងឲ្យឆ្លាក់អក្សរលើបដាមាស ចងភ្ជាប់នឹងសសរស្តម្ភ[៧២] ធំ ៗ ជាសេចក្តីជូនដំណឹងថា ៖

"នៅឃ្លាំងឯណោះ ៗ មានមាសប្រាក់ជាច្រើនផ្ទាំង, អ្នកណាត្រូវការចូរទៅយកចុះ" ។

អ្នកនគរទាំងឡាយ បើកទ្វារផ្ទះចំហទុកចោល ហាក់ដូចជាផ្សារតាំងលក់សព្វមុខទំនិញ នាំគ្នាចេញទៅកាន់សម្នាក់ព្រះរាជា ដើម្បីសាង

---

[៧២] សសរដែលគេបណ្តុះភ្ជាប់លើធ្នឹមទាបត្រង់ល្វែងបាំងសាចវិហារ ឬសាលា ។

ផ្គូស ។ ព្រះរាជារួមជាមួយនឹងមហាជនដែលមកជួបជុំគ្នាហើយនោះ បានសាងផ្នួសក្នុងសម្នាក់ព្រះតេមិយពោធិសត្វ ។

អាស្រមបទ[៧៣] ទំហំ ៣ យោជន៍ ដែលសក្កទេវរាជបញ្ជាវិស្សកម្មទេវបុត្រឲ្យនិម្មិតថ្វាយព្រះតេមិយពោធិសត្វនោះ បានក្លាយជាទីកន្លែងមានមនុស្សដ៏ច្រើនកុះករ ។

ព្រះពោធិសត្វបានចាត់ចែងជ្រើសរើសបណ្ណសាលាដែលនៅត្រង់កណ្តាលសម្រាប់ស្ត្រីទាំងឡាយ ព្រោះធម្មជាតិជាស្រីតែងមានសេចក្តីភ័យខ្លាចច្រើន រីឯបណ្ណសាលានៅខាង ៗ គឺសម្រាប់ពួកបុរស ៗ ។

សូមបញ្ជាក់ថា បណ្ណសាលាទាំងអស់នោះ ក៏ជានិម្មិតកម្មរបស់វិស្សកម្មទេវបុត្រនោះដែរ ។ មិនតែប៉ុណ្ណោះ វិស្សកម្មទេវបុត្រថែមទាំងបាននិម្មិតឲ្យរុក្ខជាតិទាំងឡាយមានផ្កាផ្លែគ្រប់កាល ។

ជារៀងរាល់ថ្ងៃឧបោសថ ផ្លែឈើទាំងឡាយដែលវិស្សកម្មទេវបុត្រនិម្មិតនោះ តែងជ្រុះមកលើផែនដី ពួកតាបសនិងតាបសិនីទាំងនោះរើសយកមកបរិភោគ រួចនាំគ្នាធ្វើសមណធម៌ ។

បណ្តាអ្នកបួសទាំងនោះ អ្នកណាត្រិះរិះទៅរកកាម អ្នកណាត្រិះរិះទៅរកព្យាបាទ អ្នកណាត្រិះរិះទៅរកវិហឹសា ព្រះពោធិសត្វដឹងនូវ

---

[៧៣] អាស្រម, ទីក្បែរឬជុំវិញអាស្រម, បរិវេណជុំវិញអាស្រម ។

ចិត្តរបស់អ្នកនោះទាំងអស់ កាលដឹងដូច្នេះហើយ ទ្រង់ហោះទៅគង់ឰដ៏អាកាសសម្ដែងធម៌ដ៏ពីរោះ ជនទាំងឡាយនោះ បានស្ដាប់ធម៌ដ៏ពីរោះរបស់ព្រះពោធិសត្វ ក៏មានចិត្តមូលផ្ដុំក្នុងអារម្មណ៍តែមួយ ជាចិត្តខ្ពស់ឯក បានសម្រេចអភិញ្ញានិងសមាបត្តិគ្រប់ ៗ គ្នា ។

## ស្ដេចសាមន្តរាជ ៧ នគរសោយផ្នួសតាមព្រះតេមិយ

គ្រានោះ ស្ដេចសាមន្តរាជ[៧៤] មួយអង្គឮដំណឹងថា "ស្ដេចកាសិរាជនៅដែនកាសី ចេញអំពីនគរពារាណសី ទ្រង់ចូលទៅកាន់ព្រៃសាងព្រះផ្នួស" ហើយស្ដេចអង្គនោះក៏មានបំណងយកក្រុងពារាណសីធ្វើជានគររបស់ខ្លួន រួចស្ដេចយាងដំណើរចេញពីនគររបស់ខ្លួន ដល់ដែនដីនគរពារាណសី ចូលទៅក្នុងនគរ ទតមើលនគរមិនឃើញមានការតុបតែងលម្អ[៧៥] អ្វីសោះ ទ្រង់យាងឡើងទៅរាជនិវេសន៍ បានទតឃើញរតនៈដ៏មានតម្លៃ ៧ ប្រការ ទ្រង់ព្រះចិន្តាថា "ស្ដេចកាសិរាជ ជាក់ជា

---

[៧៤] ព្រះរាជាក្នុងប្រទេសជិតខាង, ប្រទេសរាជ ( ស្ដេចចំណុះគេ ) ។

[៧៥] សេចក្ដីល្អ, ភាវៈល្អ គឺបែបបទ, លំនាំ, សណ្ឋាន ។ យើងសរសេរ " លម្អ " យ៉ាងនេះ ព្រោះមូលសព្ទនៃពាក្យនេះគឺ " ល្អ " ជាព្យាង្គតម្រួត ដូច្នេះ បើមូលសព្ទជាព្យាង្គតម្រួត ពាក្យក្លាយ ក៏ត្រូវសរសេរជាព្យាង្គតម្រួតដែរ ។

មានភ័យអ្វីកើតឡើងដល់ព្រះអង្គ ព្រោះអាស្រ័យទ្រព្យនេះហើយ" ទ្រង់ព្រះចិន្តាដូច្នេះហើយ បានហៅអ្នកប្រមឹកទាំងឡាយមកសួរថា ៖

"តើក្នុងនគរនេះ មានភ័យអ្វីកើតឡើងចំពោះស្តេចរបស់ពួកអ្នកឯងឬ ?"

ពួកអ្នកប្រមឹកក្រាបទូលថា ៖

"បពិត្រព្រះសម្មតិទេព គ្មានភ័យអ្វីកើតឡើងនោះទេ ក្រាបទូល" ។

ព្រះរាជាត្រាស់សួរថា ៖

"បើគ្មានភ័យអ្វីកើតឡើងទេ ចុះហេតុអ្វីបានជាស្តេចរបស់ពួកឯងចេញសាងព្រះផ្នួស ?"

ពួកអ្នកប្រមឹកឆ្លើយក្រាបទូលថា ៖

"បពិត្រព្រះសម្មតិទេព រាជបុត្ររបស់ស្តេចនៃពួកទូលព្រះបង្គំជាខ្ញុំ ព្រះនាមថា តេមិយ ទ្រង់មិនមានបំណងសោយរាជ្យក្នុងនគរពារាណសីទេ ដូច្នោះហើយ ទ្រង់ពុតធ្វើជាខ្វិន គ ថ្លង់ លុះបានឱកាសចេញអំពីនគរចូលទៅកាន់ព្រៃក៏បួសជាឥសី ។ ដំណើរនោះឯងជាហេតុធ្វើឲ្យស្តេចរបស់ពួកទូលព្រះបង្គំជាខ្ញុំរួមជាមួយនឹងពួកមហាជនចេញអំពីនគរទៅកាន់សម្នាក់ព្រះតេមិយតាបស ហើយក៏នាំគ្នាបួសអស់ទៅ" ។

ក្រោយពីបានឮពាក្យរបស់ពួកអ្នកប្រមឹក ស្ដេចសាមន្តរាជទ្រង់មានព្រះទ័យត្រេកអរ ព្រះអង្គមានព្រះតម្រិះថា "អញនឹងបួសដែរ" ហើយសាកសួរពួកគេថា ៖

"នែអស់លោក ស្ដេចកាសិរាជទ្រង់ចេញទៅតាមទ្វារណា ?"

ពួកអ្នកប្រមឹកក្រាបទូលថា ៖

"តាមទ្វារខាងកើត ក្រាបទូល" ។

ស្ដេចសាមន្តរាជអង្គនោះជាមួយនឹងបរិវាររបស់ព្រះអង្គ ចេញដំណើរទៅតាមទ្វារខាងកើតបណ្ដោយឆ្នេរទន្លេ ។

ចំណែកព្រះពោធិសត្វទ្រង់ជ្រាបនូវដំណើរយាងមករបស់ស្ដេចសាមន្តរាជនោះ ព្រះអង្គក៏មកទទួលនៅកណ្ដាលព្រៃ ដោយទ្រង់គង់នៅឰដ៏អាកាសសម្ដែងធម៌ដ៏ពីរោះថ្វាយស្ដេចសាមន្តរាជ ។ ស្ដេចអង្គនោះជាមួយនឹងបរិវារ បានសម្រេចព្រះទ័យបួសក្នុងសម្នាក់ព្រះតេមិយពោធិសត្វ ។

មានស្ដេចនគរផ្សេង ៗ ទៀតចំនួន ៧ អង្គ មួយអង្គ ៗ សុទ្ធតែយាងមកដោយបំណងថានឹងយកនគរពារាណសី មានទំនងដូចស្ដេចមុនដែរ ប៉ុន្តែស្ដេចទាំងនោះសម្រេចព្រះទ័យបោះបង់រាជ្យចោលហើយទៅបួសក្នុងសម្នាក់របស់ព្រះពោធិសត្វដូចគ្នាដែរ ។ ចំណែកដំរីដែល

ធ្លាប់ប្រើជាពាហនៈ ក៏ទៅជាដំរីព្រៃ, សេះក៏ទៅជាសេះព្រៃ, រថក៏បាក់បែកចោលនៅក្នុងព្រៃ ។ កហាបណៈទាំងអស់នៅគ្រប់កណ្ដាគារ[៧៦] មនុស្សទាំងឡាយបាននាំយកមកពោយរាយធ្វើជាគ្រាប់ខ្សាច់នៅក្បែរ ៗ អាស្រមបទ ។ អ្នកដែលបួសជាឥសីទាំងអម្បាលនោះ បានសម្រេចអភិញ្ញានិងសមាបត្តិគ្រប់ ៗ គ្នា ។ នៅទីបំផុតនៃជីវិត ក៏ទៅកើតក្នុងព្រហ្មលោក ។ សូម្បីដំរី សេះ ដែលជាសត្វតិរច្ឆាន បានញ៉ាំងចិត្តឲ្យជ្រះថ្លាចំពោះពួកឥសី ក៏បានកើតនៅក្នុងឆកាមាវចរសួគ៌ដែរ ។

## ព្រះសាស្ដាប្រជុំជាតក

ព្រះសាស្ដានាំធម្មទេសនាមកបរិយាយហើយ ទ្រង់ប្រកាសនូវអរិយសច្ចទាំង ៤ រួចបញ្ជាក់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះទេ សូម្បីពីអតីតជាតិ ក៏តថាគតធ្លាប់លះបង់រាជ្យចេញទៅបួសដែរ" រួចទ្រង់ប្រជុំជាតកដូច្នេះ ៖

- ទេវធីតាអាស្រ័យស្វេតច្ឆត្រគ្រានោះបានមកជាឧប្បលវណ្ណាថេរី
- សុនន្ទសារថី បានមកជាព្រះសារីបុត្រ
- មាតាបិតា បានមកជាមហារាជត្រកូល

---

[៧៦] ឃ្លាំង, ឃ្លាំងសម្រាប់ដាក់ទ្រព្យ ។

- ជនផ្សេង ៗ ទៀត បានមកជាពុទ្ធបរិស័ទ
- បណ្ឌិតខ្ញុំន គ ថ្ងង់ នោះបានមកជាអង្គអញតថាគតសម្មាសម្ពុទ្ធ នេះឯង ។

តេមិយជាតកពិស្តារទី ១ ចប់តែប៉ុណ្ណេះ ។



នេះកាលព្រះតេមិយសម្តែងឫទ្ធិសាកល្បងកម្លាំងរបស់ខ្លួន

ISBN 9789996341052

PUC Press